ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

◆ ឌុច  ប្រាប់អំពីការចាប់ខ្លួននៅក្នុងជួរបក្ស

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩៨  ខែមិថុនា  ឆ្នាំ២០១៦

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩៨ ខែមិថុនា ឆ្នាំ២០១៦

## មាតិកា

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ........................................................ ១

**ផ្នែកឯកសារ**

◆ ហែម សុត ហៅ សៀន ប្រធានខស្សាហកម្ម ........................................................ ២

◆ ឈឹម វ៉ាន់សាត និងផែនការក្បត់អង្គការ ........................................................ ៦

◆ បញ្ហាអនាគតរបស់យុវជន យុវនារីកម្ពុជា ........................................................ ៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........................................................ ២៤

◆ នួន ឆន សមមិត្តនារីកងឈ្លប ........................................................ ២៦

◆ បាត់បងជីដូនមួយក្នុងរបបខ្មែរក្រហម ........................................................ ២៧

◆ ចាប់ពីរបបខ្មែរក្រហម ដល់ខប្បត្តិហេតុ ហាំ បាលី ........................................................ ២៨

◆ អាជីកំបាំងរបស់ ប៉ុល ពត ........................................................ ៣៤

**ផ្នែកច្បាប់**

◆ "អាឃាតករ1" ឌុច ប្រាប់ពីការចាប់ខ្លួននៅក្នុង ........................................................ ៣៩

◆ ការឃោសនា ការធ្វើទារុណកម្ម និងកេរដំណែលពីអាណានិគម ........................................................ ៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការយល់ឃើញចំពោះសាលាក្តីខ្មែរក្រហម ........................................................ ៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ........................................................ ៦



និស្សិតស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចុះសម្ភាសន៍ប្រជជននៅស្រុកអន្លង់វែងពីការតស៊ូក្នុងរបបខ្មែរក្រហម

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ លី សុខឃាង, ចៅ ព្រហស្បតិ៍, ផេង ពង្សរ៉ាស៊ី, កែ ដុកឡូង, អេង កុកថាយ, ទេព ម៉េងឃាន, អាលីស មើហ្គើរ, ប៉ុក ប៉ុនសូម៉ាដ **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ **អ្នកបកប្រែ** ៖ សុភ័ក្ត្រ ភាណា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ អេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ត្រូវបានឧទ្ទិសដល់ការបង្កើតការផ្សះផ្សា និងការកសាងសន្តិភាពនៅកម្ពុជា ។ មជ្ឈមណ្ឌលមានទិសដៅសម្រេចឲ្យបានគោលបំណងទាំងអស់នេះតាមរយៈការសិក្សាអំពីសន្តិភាព និងការអប់រំពីអំពើប្រល័យពូជសាសន៍ ។

ការសិក្សាអំពីសន្តិភាព គឺដើម្បីរកឲ្យឃើញ និងវិភាគពីអាកប្បកិរិយាហិង្សា និងអហិង្សា ក៏ដូចជាអាកប្បកិរិយានានាដែលធ្វើឲ្យកើតជម្លោះ ។ ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺក្នុងគោលដៅបង្កើតកម្មវិធីសិក្សា ដែលស្វែងឲ្យឃើញអំពីសំណួរជាមូលដ្ឋានលើអ្វីដែលបានកើតឡើង និងហេតុអ្វីបានជាវាកើតឡើងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ វិធីសាស្ត្រអប់រំទាំងពីរនេះ ត្រូវបានប្រើប្រាស់ដើម្បីជំរុញសន្តិភាព ការអប់រំ និងការគោរពច្បាប់នៅកម្ពុជា ។ អន្លង់វែង គឺជាតំបន់តស៊ូចុងក្រោយនៃរបបខ្មែរក្រហម ។ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសហគមន៍មូលដ្ឋាន សាលារៀន និងអាជ្ញាធរទេសចរណ៍ មជ្ឈមណ្ឌលផ្តោះទៅតភ្ជាប់នៃការបែងចែករវាងអតីតខ្មែរក្រហមនឹងមនុស្សជំនាន់ក្រោយរបស់កម្ពុជា ។

គោលបំណងរបស់មជ្ឈមណ្ឌល គឺផ្តល់កម្មវិធីអប់រំ និងកម្មវិធីទាក់ទងនឹងទេសចរណ៍ ដើម្បីលើកកម្ពស់ការថែរក្សាប្រវត្តិសាស្ត្រនិយាយផ្ទាល់មាត់ និងប្រវត្តិសាស្ត្រតាមរូបរាងនៃតំបន់ ក៏ដូចជាកសាងសន្តិភាព និងការផ្សះផ្សាពីជំនាន់មួយទៅជំនាន់មួយ និងការបែងចែកឋានៈសង្គម ។ ដោយប្រើប្រាស់កិច្ចការពីមុនៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍ជាគំរូគម្រោងនេះនឹងដឹកនាំសិស្សានុសិស្សក្នុងដំណើរទស្សនកិច្ចអប់រំទៅកាន់ទីកន្លែងមួយចំនួនដែលមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រនៅអន្លង់វែង ។ គោលបំណងគឺជំរុញសិស្សានុសិស្សឲ្យចូលរួមក្នុងសកម្មភាពអប់រំប្រចាំថ្ងៃ ដែលទាមទារឲ្យមានការត្រិះរិះពិចារណាការបង្ហាញមតិផ្ទាល់ខ្លួន និងការតស៊ូមតិ ព្រមទាំងផ្តល់ឱកាសក្នុងការប្រាស្រ័យទាក់ទងពិភាក្សា និងសួរសំណួរទៅកាន់អតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះដែលរស់នៅក្នុងតំបន់នោះ ។

មជ្ឈមណ្ឌលគ្រោងសម្រេចនូវគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីដែលមានមូលដ្ឋានលើការពិភាក្សារួមគ្នា ការធ្វើមគ្គុទ្ទេសក៍ទេសចរណ៍ទៅកាន់ទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់នូវរឿងរ៉ាវផ្ទាល់ខ្លួន ដើម្បីចែករំលែកនូវមេរៀនប្រវត្តិសាស្ត្រ និងមេរៀនសីលធម៌ ។ ដំណើរទស្សនកិច្ចនេះត្រូវបានរៀបចំឡើងដោយសង្ឃឹមថានឹងជួយដល់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ដោយផ្តល់ឲ្យអ្នកទាំងអស់នូវឱកាសក្នុងការឆ្លុះបញ្ចាំង និងចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងសម័យសង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) ដែលកើតមានបន្ទាប់ពីអំឡុងពេលនោះ ។

តាមរយៈកិច្ចពិភាក្សាផ្ទាល់ជាមួយនឹងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម កម្មវិធីនេះនឹងជំរុញឲ្យអ្នកចូលរួមគិតពិចារណាលើករណីទាំងពីរគឺមនុស្សធម៌ និងអមនុស្សធម៌ នៅក្នុងអំឡុងពេលរបត់ផ្លាស់ប្តូរសង្គម ។ រឿងរ៉ាវទាំងនេះលើកកម្ពស់នូវសមាសធាតុជាមូលដ្ឋានបំផុតនៃការកែប្រែជម្លោះ និងជំនាញផ្នែកសង្គម ដូចជាសមត្ថភាពក្នុងការឆ្លុះបញ្ចាំង គិតគូរប្រកបដោយសត្យានុម័តិ និងយោគយល់គ្នាជាមួយអ្នកដទៃ ។ គោលបំណងស្នូលរបស់គម្រោងនេះ គឺការយោគយល់គ្នាបែបប្រវត្តិសាស្ត្រ ហើយសិស្សានុសិស្សដែលចូលរួមក្នុងកម្មវិធីនេះ នឹងដើរតួនាទីចែករំលែកនូវការសិក្សា និងការយល់ដឹងរបស់ខ្លួននៅតាមសាលារៀនក្នុងតំបន់របស់ខ្លួន ។ ការបង្កើតឡើងនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បង្ហាញអំពីចំណុចចាប់ផ្តើមថ្មីមួយ សម្រាប់ការងាររបស់មជ្ឈមណ្ឌលផ្តោះទៅរកគោលបំណងក្នុងការពង្រឹងទៅវិញទៅមករវាងសន្តិភាព ការអប់រំ និងសហគ្រាសដើម្បីប្រយោជន៍សង្គម ។ តាមរយៈគោលបំណងសំខាន់ៗទាំងនេះមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានគោលដៅប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានឈានមុខមួយក្នុងការអភិវឌ្ឍន៍នូវវិធីសាស្ត្រប្រកបដោយនិរន្តរភាព ដើម្បីសម្រេចបាននូវការផ្សះផ្សា និងសន្តិភាពនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ ។ **លី សុខឃាង**

# ហែម សុត ហៅ សៀន ប្រធានឧស្សាហកម្ម ភូមិភាគកណ្តាល

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១២៧០*

ហែម សុត ហៅ សៀន ភេទប្រុស អាយុ២៨ឆ្នាំ កើតនៅភូមិក្របាប់ក្រោម ឃុំពាមមន្ទា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សៀន មានតួនាទីជាប្រធានឧស្សាហកម្ម ភូមិភាគកណ្តាល ។ សៀន ត្រូវបានអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ យើងមិនដឹងថា ចម្លើយសារភាពរបស់ សៀន ដែលសរសេរដោយដៃ មានចំនួន២៩ទំព័រ រៀបរាប់ពីសកម្មភាពរបស់ខ្លួន និងបក្ខពួកធ្វើសកម្មភាពដើម្បីប្រឆាំងនឹងបដិវត្តន៍នោះ ជាចម្លើយពិតប្រាកដណានោះទេ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៅក្នុងចម្លើយសារភាពរបស់សៀន៖

នៅឆ្នាំ១៩៥៨ សៀន បានចូលរៀននៅសាលាក្របាប់ក្រោម ស្ថិតនៅក្នុងភូមិកំណើត លុះដល់ឆ្នាំ១៩៦៨ បានចូលរៀននៅវិទ្យាល័យព្រៃវែង ។ ចាប់ពីពេលនោះមក សៀន ត្រូវបានឈ្មោះ សួន ជាសិស្សរៀននៅថ្នាក់ទី១ អប់រំដោយបាននិយាយថា យើងធ្វើនេះ មិនមែនធ្វើទៅរកកុម្មុយនីស្តទេ គឺយើងធ្វើដើម្បីរបបលោកសេរី ដែលមានអ្នកដឹកនាំជាសាស្ត្រាចារ្យឈ្មោះ ថាច់ចាន់ និងឈ្មោះ ដឿន នៅកំពង់ចាម ។ យើងខិតខំកសាងកម្លាំង គឺយើងប្រមូលអ្នកណាដែលគេចង់សប្បាយ អ្នកណាដែលគេចង់ធ្វើបដិវត្តន៍ក៏យើងប្រមូលយកដែរ ។ តែមុនដំបូង ត្រូវអប់រំឲ្យគេយល់ពីនយោបាយបដិវត្តន៍សិន ដល់ពេលគេជឿយើងហើយ សឹមនាំគេឲ្យរួមសកម្មភាពប្រឆាំងបដិវត្តន៍ជាមួយយើង ។ ក្រោយមក សួន បានប្រាប់ សៀន ឲ្យស្គាល់ខ្សែឈ្មោះ សោ នៅកំពង់ចាម ។ បន្ទាប់មក សួន ក៏បាននាំ សៀន ទៅភូមិជ្រោយថ្ម ក្រុងកំពង់ចាម ដើម្បីជួបជាមួយឈ្មោះ ឈឿន និង លាន ដែលជាខ្សែរបស់ខ្លួន ។ ឆ្នាំ១៩៦៩ ឈឿន និង លាន បានបញ្ចូល សៀន ជា សេ.អ៊ី.អា


កម្មករបដិវត្តន៍ នៅរោងចក្រផលិតឥដ្ឋ ក្បឿង នៅតាខ្មៅ កំពុងដឹកជញ្ជូនឥដ្ឋសម្រាប់សាងសង់រោងចក្រ និងគ្រឿងសំណង់ផ្សេងៗ

នៅផ្ទះរបស់ ឈឿន នៅភូមិជ្រោយថ្ម ជាយក្រុងកំពង់ចាម ហើយបានប្រគល់ភារកិច្ចឲ្យ សៀន ធ្វើគឺ៖

១) នាំសំបុត្រពី ឈឿន ទៅ ស្រេង ទៅភូមិព្រៃទទឹង ក្នុងស្រុកព្រៃឈរ និងទៅ សួន នៅវាលវង់កំពង់ចាម ។

២) ការពារ ឈឿន និង លាន តាមរូបភាពជាអ្នករៀននៅវិទ្យាល័យកំពង់ចាម ។ ក្រោយមក ឈឿន បានចាត់តាំង សៀន ឲ្យទៅដាំស្ពៃជាមួយ លឿន នៅជាយក្រុងក្រចេះ ។

ឆ្នាំ១៩៧០ ឈ្មោះ ជឿន បានចាត់តាំង សៀន ឲ្យដើរកាណូតពីក្រចេះមកភ្នំពេញ និងពីក្រចេះទៅទន្លេសាប និងបានខទ្វេសនាមឲ្យស្គាល់ ណៃ ងាយស្រួលធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ជាមួយគ្នា ។ នៅពេលដើរកាណូត សៀន និង ណៃ បានបំផ្លាញការរកស៊ីមិនឲ្យចំណេញ ហើយឆ្លៀតពេលនោះ សៀន កសាងកម្លាំងក្បត់បានបីនាក់នៅកោះខកញ៉ាតី មានឈ្មោះ អ៊ែល, កៅ និង ផាត ។ ក្រោយមកអ្នកទាំងពីរបានលក់កាណូតចោលតាមបញ្ជារបស់ ជឿន ហើយបានមកតំបន់រំដោះនៅភូមិគៀនជ្រៃ (កំពង់ចាម) វិញ ។

ខែកញ្ញា ឆ្នាំ១៩៧០ ណៃ បានចាត់តាំង សៀន ឲ្យមកនៅជាមួយ ឃួន នៅមន្ទីក-២៥ នៅព្រៃអូរទឹកថ្លា ។ ពេលនោះ សៀន បានទទួលការងារខាងពេទ្យ ហើយក៏ជាអ្នកបម្រើ ឃួន ដែរ គឺនៅពេលដែលមាននារីស្អាតៗ សៀន តែងតែនាំទៅប្រគល់ឲ្យ ឃួន ជាប្រចាំ ។ បន្ទាប់មក ឃួន បានខទ្វេសនាមឲ្យ សៀន មកនៅក្រោមការគ្រប់គ្រងរបស់ អឿន ប្រធានមន្ទីរភូមិភាគឧត្តរ និងឈ្មោះ យានអនុប្រធានមន្ទីរភូមិភាគ ដែលជាខ្សែក្បត់របស់ខ្លួនផ្ទាល់ និងបានណែនាំឲ្យ សៀន រួមសកម្មភាពជាមួយ សួរ សមាជិកមន្ទីរភូមិភាគ, វ៉ាត សមាជិកមន្ទីរភូមិភាគ, នួរ (នារី) , ស៊ីម (នារី) , ធា (នារី) , ខន (នារី) (នារីដែលមានរាយឈ្មោះខាងលើ បានខុសសីលធម៌ជាមួយ ឃួន ហើយត្រូវបាន ឃួន កសាងចូលក្នុងកម្លាំងក្បត់បាន) ។

ខែមករា ឆ្នាំ១៩៧១ ឃួន បានចាត់តាំង សៀន ឲ្យទៅធ្វើសកម្មភាពជាមួយឈ្មោះ ងួន លេខាស្រុក១៣០ ។ ប្រាំថ្ងៃក្រោយមក ងួន បានចាត់តាំង សៀន ឲ្យធ្វើជាប្រធានពាណិជ្ជកម្មស្រុក១៣០ ។ ជារៀងរាល់ខែ សៀន បានចូលរួមប្រជុំសរុបសកម្មភាពក្បត់ដែលដឹកនាំដោយឈ្មោះ ងួន ចំនួន១១ដង ដើម្បីពិនិត្យសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ដែលអ្នកចូលរួមមានឈ្មោះ ងួន លេខាស្រុក១៣០ , ងិន អនុលេខាស្រុក១៣០ , ស៊ីម សមាជិកស្រុក១៣០ , ឈុន (នារី) សមាជិកស្រុក ។ នៅក្នុងអង្គប្រជុំសមាជិកទាំងអស់បានធ្វើសេចក្តីរាយការណ៍ពីសកម្មភាពដែលខ្លួនបានធ្វើកន្លងមកជូនទៅអង្គប្រជុំ ។ នៅពេលបានស្តាប់សេចក្តីរាយការណ៍រួចមក ងួន បានដាក់ផែនការថ្មី ដែលមានខ្លឹមសារដូចជា៖

១) នៅខាងមូលដ្ឋាន ត្រូវបន្តសកម្មភាពកសាងកម្មាភិបាលដោយរើសពួកដែលមានសមាសភាពមិនល្អឲ្យក្តាប់មូលដ្ឋាន ងាយស្រួលអប់រំឲ្យប្រឆាំងបដិវត្តន៍ទៅថ្ងៃក្រោយ ។

២) បំផុសយុទ្ធជនមិនឲ្យចូលធ្វើទ័ព ។

៣) ផ្នែកពាណិជ្ជកម្ម គឺគាបប្រជាជនលក់សម្ភារឲ្យប្រជាជនយកចំណេញលើសការកំណត់របស់បក្ស ។

៤) ពេលអង្គការចែកសម្ភារអ្វីក៏ដោយ គឺត្រូវលាក់ទុកមួយចំនួន ។ បន្ទាប់មក នៅឆ្នាំ១៩៧១ដដែល ងួន បានប្រគល់កម្លាំងក្បត់ពីរនាក់មកឲ្យ សៀន ក្តោបក្តាប់មានឈ្មោះ សេក និង ធឹម ។

ឆ្នាំ១៩៧២ ឃួន បានដក ងួន ឲ្យទៅមើលការខុសត្រូវនៅស្រុកបារាយណ៍ ហើយចាត់តាំង ងិន ជាលេខាស្រុក១៣០ និងនារី ស៊ីម ជាសមាជិក ហើយបានរួមសកម្មភាពជាមួយ សៀន បំផុសយុទ្ធជនមិនឲ្យចូលរួមក្នុងសមូហភាព ។ លុះដល់ឆ្នាំ១៩៧៣ ឃួន បានដក ងិន ចេញពីលេខាស្រុក១៣០ ដោយបានដាក់ នារីស៊ីម ជំនួសវិញ ។ នៅពេលនោះដែរ សៀន បានធ្វើសកម្មភាពលក់សម្ភារកេងយកចំណេញច្រើនពីប្រជាជនលើសពីការកំណត់របស់អង្គការ បំផុសប្រជាជនមិនឲ្យចូលក្នុងសហករណ៍ និងបំផុសប្រជាជនឲ្យធ្វើទុកលក់ ដែលជាការផ្ទុយពីទិសរបស់អង្គការ គឺឲ្យប្រជាជនធ្វើស្រែដើម្បីដោះស្រាយជីវភាព ។

ឆ្នាំ១៩៧៤ សៀន បានឡើងជាប្រធានពាណិជ្ជកម្មតំបន់៣៣ ភូមិភាគឧត្តរ ។ បន្ទាប់មក សៀន បានចូលរួមប្រជុំជាមួយ អ៊ុន លេខាតំបន់៣៣, ចែក លេខាស្រុកព្រែកប្រសព្វ តំបន់៣៣, នារី ឈុន ប្រធាននារី តំបន់៣៣, នារីវ៉ែន លេខាស្រុក១៣០ ។ នៅពេលនោះ អ៊ុន បានធ្វើការណែនាំដល់សមាជិកក្រុមទាំងអស់ ឲ្យបន្តធ្វើសកម្មភាពទៀត ហើយត្រូវរក្សាការសម្ងាត់ ដើម្បីការពារកម្លាំងក្បត់របស់យើង ។ បន្ទាប់មក អ៊ុន បានដាក់ផែនការបីចំណុចឲ្យបក្ខពួករបស់ខ្លួនអនុវត្តគឺ៖

១) ត្រូវខិតខំកសាងកម្លាំងក្បត់ ដើម្បីងាយស្រួលប្រឆាំងអង្គការនៅថ្ងៃក្រោយ ។

២) បក្សបានឲ្យណែនាំយុទ្ធជន និងយុទ្ធនារីឲ្យយល់ពីនយោបាយបដិវត្តន៍ តែពេលអនុវត្តធ្វើយ៉ាងណាកុំឲ្យយុទ្ធជន និងយុទ្ធនារីយល់ពីនយោបាយបដិវត្តន៍ បើគេយល់នាំឲ្យយើងមានការលំបាកក្នុងការប្រមូលកម្លាំងក្បត់ ។

៣) បំផុសយុទ្ធជន និងយុទ្ធនារី មិនឲ្យចូលជួរបដិវត្តន៍ ដើម្បីបំផ្លាញផែនការបក្សក្នុងការប្រមូលកងទ័ព ។ ក្រោយពេលប្រជុំចប់ សៀន បានអនុវត្តតាមផែនការដោយកសាងកម្លាំងក្បត់បានចំនួន៨នាក់ ។ នៅខែឧសភា ឆ្នាំដដែល អ៊ុន ត្រូវបានអង្គការដកឲ្យទៅទទួលអនុតំបន់៤៣ ។ ពេលនោះ ឃួន បានចាត់តាំង ឈឿន ឲ្យទទួលជាលេខាតំបន់៣៣វិញ ។ ក្រោយពីបានទទួលជាលេខាហើយ ឈឿន បានណែនាំ សៀន ថា ឥឡូវ អំបិល ថ្នាំពេទ្យ និងក្រណាត់ អង្គការបានបញ្ជូនមកញឹកញាប់ហើយច្រើនណាស់ ។ ត្រូវចែកឲ្យប្រជាជនតិចតួច សល់ប៉ុន្មានត្រូវលាក់ទុក ។ ស្មើមិត្តធ្វើយ៉ាងម៉េចកុំឲ្យបែកការណ៍ឲ្យសោះ ត្រូវចាត់តាំងកម្លាំងដែលកសាងបានឲ្យក្តាប់ឃ្លាំងដែលលាក់សម្ភារទាំងនេះ ហើយធ្វើបញ្ជីសម្ភារដែលនៅសល់ឲ្យខ្ញុំ ។ បន្ទាប់មកទៀត សៀន កសាងកម្លាំងក្បត់បានចំនួន១១នាក់ ។

ខែមករា ឆ្នាំ១៩៧៥ សៀន បានចូលរួមប្រជុំនៅមន្ទីរតំបន់បែកអន្លង់ ។ នៅក្នុងអង្គប្រជុំ ឈឿន បានលើកឡើងថា បច្ចុប្បន្ននេះ ទិសអង្គការគឺវាយផ្តាច់ព្រ័ត្ររំដោះទូទាំងប្រទេស ដូច្នេះយើងត្រូវបង្អាក់ផែនការនេះ ៖

១) ចំពោះកម្លាំងទ័ពដែលអង្គការត្រូវការ គឺយើងខបត្តម្ភចំនួនតិចតួចបានហើយ បញ្ហាស្បៀងក៏ដូចគ្នាដែរ ។

២) បង្កើតចលនាចោរព្រៃ សំខាន់រើសពួកអ្នកដែលរត់ចោលជួរ និងអ្នកដែលមានសមាសភាពមិនល្អ ឲ្យរត់ចូលព្រៃដើម្បីធ្វើសកម្មភាពនៅសមរភូមិក្រោយ ធ្វើយ៉ាងណាឲ្យអង្គការមានការពិបាកដោះស្រាយស្មុគស្មាញ ។

៣) ស្រុកនីមួយៗត្រូវលាក់អង្ករ ត្រីងៀត អំបិល ទុកសម្រាប់ផ្តល់ឲ្យអ្នកនៅក្នុងព្រៃ ក្រោយពីទទួលផែនការហើយ សៀន បានចាត់តាំងឈ្មោះ សរ អនុពាណិជ្ជកម្មតំបន់៣៣ ឲ្យយកអង្ករទៅឲ្យឈ្មោះ លី ប្រធានសង្កាត់ឈើទើ ដើម្បីផ្តល់បន្តទៅឲ្យពួកចោរព្រៃចំនួនបួនបាវ ។

ក្រោយរំដោះទូទាំងប្រទេសបានមួយខែ ឈ្មោះ គុល បានចាត់តាំង សៀន ឲ្យធ្វើជាប្រធានសិប្បកម្មតំបន់៤២ ។ បន្ទាប់មក គុល បានហៅបក្ខពួកក្បត់ក្នុងតំបន់៤២ ឲ្យមកប្រជុំនៅស្រែវាលដែលមានសមាជិកចូលរួមចំនួន៨នាក់ ។ នៅក្នុងអង្គប្រជុំ គុល បាននិយាយថា បច្ចុប្បន្ន ពួកលន់ នល់ ចាញ់ហើយ ដូច្នេះយើងត្រូវបន្តសកម្មភាពរបស់យើងបន្តទៀត ។ ប្រជាជនមានទំនាស់ជាមួយរបបសម្ភូហភាព ដែលអង្គការលើកឡើង ដូច្នេះយើងត្រូវស្រាវជ្រាវរកខ្សែចាស់របស់យើងដែលកសាងបានតាំងពីសម័យសង្គ្រាម ដើម្បីឲ្យពួកនេះបន្តធ្វើសកម្មភាពប្រឆាំងបដិវត្តន៍បន្តទៀត ។ ក្រោយចេញពីប្រជុំ សៀន បានកសាងកម្លាំងថ្មីចំនួនពីរនាក់ និងរួមធ្វើសកម្មភាពជាមួយ គុល ដឹកអំបិល ក្រណាត់ ថ្នាំពេទ្យរបស់អង្គការពីតំបន់៣៣ចាស់ មកលាក់ទុកនៅបន្ទាយជ័យស្ថិតនៅក្នុងឃុំស្តី ស្រុកចម្ការលើដែលមានអ្នកទទួលខុសត្រូវឈ្មោះ ព្រាប ប្រធានមន្ទីរតំបន់៤២ ។

ក្រោយមក គុល បានចាត់តាំង សៀន និង ហ៊ាង ឲ្យទៅមើលព្រៃសភាស និងព្រៃសោះខ្យល់ ដើម្បីក្តាប់ភូមិសាស្ត្រកន្លែងនេះឲ្យបានច្បាស់លាស់ ហើយបានចាត់តាំងឈ្មោះ រិត ប្រធានឡផ្សូង ឲ្យបញ្ជូនកម្លាំងចំនួន៣០នាក់ ទៅកន្លែងនោះកាប់ឈើធ្វើផ្សូងនេះគ្រាន់តែជារូបភាពខាងក្រៅទេ ឯការសម្ងាត់វិញ គុល បានដឹកអង្ករ៦០បាវ ត្រីងៀតកន្លះឡាន អំបិលមួយឡាន យកទៅលាក់ទុកនៅព្រៃសភាស ដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅថ្ងៃក្រោយ ។ គុល បានចាត់តាំង សៀន និង ហ៊ាង ឲ្យដឹកអាវុធរាប់រយដើម យកទៅលាក់ទុកនៅព្រៃខាងកើតបុសខ្នុរ ដឹកប្រេងម៉ាស៊ូត និងសាំង ចំនួន២១ធុងធំៗ យកទៅទុកនៅព្រៃអូរទឹកថ្លា និងដឹកអង្ករចំនួន៥០បាវ អំបិល និងត្រីងៀតមួយឡានធំទៀត យកទៅលាក់ទុកនៅព្រៃសោះខ្យល់ ។ គុល បានប្រគល់លិខិតមួយច្បាប់ទៅ សៀន ឲ្យយកទៅឲ្យ ឈឿន នៅភ្នំពេញ ហើយបានរាយការណ៍ប្រាប់ឲ្យដឹងពីកម្លាំងក្បត់មួយចំនួន ។

ខែមករា ឆ្នាំ១៩៧៦ សៀន បានចូលរួមប្រជុំជាមួយ គុល នៅមន្ទីរតំបន់ថ្នល់បែកដែលមានសមាជិកចំនួន១៥នាក់ចូលរួម ។ ខ្លឹមសារនៃអង្គប្រជុំ គឺផ្តោតទៅលើសភាពការណ៍កសាងកម្លាំងក្បត់ និងសភាពការណ៍ទំនាស់រវាងឯកជន និងសម្ភូហភាព ។ គុល បានបន្ថែមថា ពេលនេះជារដូវប្រមូលផលស្រូវ ហើយស្រុកនីមួយៗ

ត្រូវបង្កើនការប្រមូលផលស្រូវឲ្យបានដាច់ទៅ ដើម្បីត្រៀមសម្រាប់ផែនការរបស់យើង ។ ហេតុនេះ ស្មើមិត្តទាំងអស់គ្នា បង្កើនស្មារតីប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ថែមទៀត ។ នៅខែមេសា សៀន បានទាក់ទងឈ្មោះ ឈឿន ម្តងទៀតនៅផ្សារថ្មី (ភ្នំពេញ) ដើម្បីរាយការណ៍ប្រាប់ពីកម្លាំង និងអាវុធ ដែលបានរៀបចំរួចរាល់ហើយ ។

ខែកញ្ញា ឆ្នាំ១៩៧៦ គុល បានហៅបក្ខពួកក្បត់ទៅប្រជុំម្តងទៀតនៅមន្ទីរតំបន់៤២ មានសមាជិកចំនួន១៧នាក់ចូលរួម ។ នៅក្នុងអង្គប្រជុំ គុល បានលើកពីគម្រោងផែនការវាយបដិវត្តន៍នៅទូទាំងប្រទេស ក្នុងខែតុលា ឆ្នាំ១៩៧៦ ។ គុល បាននិយាយថា «ដោយឡែក នៅភូមិភាគរបស់យើង គឺមានកម្លាំងច្រើន ដូចជាតំបន់៤១ មានឈ្មោះ តាំង ជាលេខា, តំបន់៤៣ មានឈ្មោះ ង៉ិន ជាលេខា និងឧត្តរមានជ័យ មានឈ្មោះ សុត ជាលេខា ។ កម្លាំងបដិវត្តន៍តិចជាងកម្លាំងរបស់យើងខ្លាំងណាស់ ដូច្នេះយើងពិតជាជណ្តើមបានជ័យជម្នះមិនខាន» ។ នៅពេលនោះ គុល ក៏បានលើកទិសដៅកំណត់ផែនការ និងភារកិច្ចសម្រាប់ផ្នែកនីមួយៗអនុវត្តដូចជា ៖

១) ផ្នែកមូលដ្ឋានស្រុកនីមួយៗ ត្រូវរៀបចំកងស្រុកឲ្យហើយ ទាំងកម្លាំងមនុស្ស ទាំងអាវុធ ហើយគណៈស្រុកនីមួយៗ ត្រូវចុះបញ្ជាដោយផ្ទាល់ ។

២) ផ្នែកក្រសួង-មន្ទីរ សំខាន់ការពារកន្លែងនីមួយៗឲ្យជាប់ ហើយអ្នកបញ្ជារួមមានឈ្មោះ ស្រេង ដូច្នេះស្មើមិត្តទាំងអស់ ត្រូវរៀបចំគ្រាប់ដាក់ក្នុងឡាំងឲ្យបានស្រេចដើម្បីត្រៀមលក្ខណៈសម្បត្តិឲ្យហើយ សម្រាប់អនុវត្តផែនការរបស់យើង ។ ស្តាប់ការណែនាំរបស់ គុល ហើយអង្គប្រជុំក៏បានបិទ រួចបំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។

ខែតុលា ឈ្មោះ រិត ជានីរសាររបស់ ដឿន បានយកសំបុត្រមកឲ្យ គុល ហើយបានឱ្យប្រាប់ សៀន ថា អង្គការបានចាប់ខ្លួនមិត្តឃួន ហើយ ។ដូច្នេះ ផែនការវាយរំលំបដិវត្តន៍នៅទូទាំងប្រទេសក្នុងខែតុលា ឆ្នាំ១៩៧៦ នេះ ត្រូវផ្អាកសកម្មភាព ។ ហេតុនេះ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ១៩៧៧ សៀន និងបក្ខពួកត្រូវផ្អាក ព្រោះអង្គការចាប់ក្បាលម៉ាស៊ីនដឹកនាំក្បត់ និងបក្ខពួកអស់ហើយ ។

ខែកក្កដា ឆ្នាំ១៩៧៧ សៀន បានធ្វើការទាក់ទងជាមួយឈ្មោះ សោ ឡើងវិញ ដើម្បីបន្តសកម្មភាពក្បត់ទៀត ។ នៅខែសីហា សៀន បានជួបប្រជុំជាមួយឈ្មោះ រាប, លី និង សោ នៅភ័ស្តុភារកងពលភូមិភាគកណ្តាល ។ ឈ្មោះ រាប បាននិយាយថា «ពីមុនអង្គការមានការទុកចិត្តមកលើខ្ញុំខ្លាំងណាស់ តែបច្ចុប្បន្ន ខ្ញុំត្រូវបានអង្គការតាមដាន ។ កងទ័ពឥឡូវ អង្គការបានឲ្យមកនៅក្នុងភូមិវិញហើយ តែបានដកកាំភ្លើងទាំងអស់ មិនឲ្យកាន់ទេ» ។ នៅពេលនោះឈ្មោះ សោ ក៏បានបន្តថា «បច្ចុប្បន្ន អង្គការក៏តាមដានខ្ញុំដែរ ព្រោះអង្គការបានចាប់ឈ្មោះ រិន ដែលជាសាស្ត្រាចារ្យសកលវិទ្យាល័យបច្ចេកទេសកំពង់ចាម ជាអ្នកឧបជ្ឈាខ្ញុំ ដូចនេះ ចង់មិនចង់ ឈ្មោះ រិន ពិតជាឆ្លើយដាក់ខ្ញុំហើយ ដូច្នេះធ្វើក៏ងាប់ មិនធ្វើក៏ងាប់ដែរ» ។ បន្ទាប់មក រាប និង សោ បានសម្រេចចិត្តព្រមគ្នា លើកជាទិសដៅមួយ គឺត្រូវបាញ់សម្លាប់ឈ្មោះ អាន ចោល នៅពេលឱកាសល្អហុចឲ្យ ដោយមិនចាំបាច់កំណត់ពេលវេលាជាក់លាក់ទេ ។ ពេលស្របមតិគ្នាហើយ ក៏បំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។

ក្រោយមក សៀន បានទៅប្រជុំនៅកន្លែងដដែលមានសមាជិកចូលរួមចំនួន៦នាក់ ។ នៅក្នុងអង្គប្រជុំ ឈ្មោះ រាប បានលើកឡើងថា «ឥឡូវនេះ អង្គការបានចាប់ខ្លួនអ្នកដឹកនាំយើងអស់ហើយ ដូច្នេះ យើងត្រូវតែបន្តសកម្មភាពទៀត យើងត្រូវកម្ទេចឃ្លាំងគ្រាប់ និងកាំភ្លើងនៅកំពង់ចាមឲ្យបាននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយកម្លាំងដែលត្រូវអនុវត្តភារកិច្ចនេះ គឺកម្លាំងនៅភ័ស្តុភារដែលមានឈ្មោះ លី ជាអ្នកបញ្ជាផ្ទាល់» ។

លុះដល់ខែកញ្ញា សៀន បានទៅចូលរួមប្រជុំម្តងទៀត នៅភ្នំប្រុសភ្នំស្រី ។ រាប បានលើកឡើងថា តាមការណែនាំរបស់ឈ្មោះ ចន ឲ្យយើងពិភាក្សាគ្នា ដើម្បីរៀបចំផែនការវាយកំពង់ចាមនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយកម្លាំងដែលត្រូវវាយ គឺយកកម្លាំងវរសេនាធំ៦០១ ចំណែកកម្លាំងដឹកជញ្ជូនគ្រាប់ និងស្បៀង ត្រូវយកកម្លាំងមកពីក្រសួង-មន្ទីរ ។ អង្គប្រជុំបានយល់ស្របតាមការលើកឡើងរបស់ រាប ហើយអង្គប្រជុំបានបិទ សមាជិកទាំងអស់ក៏បានបំបែកគ្នាទៅកន្លែងវិញ ។

យោងតាមចម្លើយសារភាព សៀន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧ ។ ឯកសារចម្លើយសារភាពរបស់ សៀន ត្រូវបានធ្វើចប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧ ដែល សៀន បានចុះហត្ថលេខាដោយផ្ទាល់ និងមានចុះហត្ថលេខាមួយផ្សេងទៀត របស់អ្នកសួរចម្លើយឈ្មោះ ឈុន ។ **ឆេង ខ៊េង**

# ឈឹម វ៉ាន់សាត និងផែនការក្បត់អង្គការ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ៤៦១ បបគខ*

ឈឹម វ៉ាន់សាត ភេទប្រុស មានអាយុ៣៨ឆ្នាំ ជាជនជាតិខ្មែរ និងមានស្រុកកំណើតនៅភូមិល្វា ឃុំល្វា ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ វ៉ាន់សាត មានប្រពន្ធឈ្មោះប៉ែន សាគុំ អាយុ២៨ឆ្នាំ មានលំនៅដើមនៅភូមិវាលស្បូវ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ហើយបច្ចុប្បន្ន នៅក្នុងអង្គភាពកសិកម្ម ស្រុកកោះធំ ទទួលជាអនុប្រធាន ។ អ្នកទាំងពីរមានកូន០៤នាក់ (ស្រីទាំងអស់) មានឈ្មោះ សាត ជី អាយុ០៨ឆ្នាំ បច្ចុប្បន្ននៅមន្ទីរកុមារតំបន់២៤, សាត ថា អាយុ ០៤ឆ្នាំ បច្ចុប្បន្ននៅមន្ទីរកុមារតំបន់២៤, សាត ធា អាយុ០៣ឆ្នាំ បច្ចុប្បន្ននៅជាមួយម្តាយ និងសាត ធន អាយុ០៦ខែ បច្ចុប្បន្ននៅជាមួយម្តាយ ។ វ៉ាន់សាត មានឪពុកឈ្មោះ ឈឹម សុត អាយុ ៦៥ឆ្នាំ បច្ចុប្បន្ននៅសហករណ៍ភូមិសំបួរ ឃុំដង្កោ ខេត្តកណ្តាល និងម្តាយឈ្មោះអិល អាយុ៥៩ឆ្នាំ បច្ចុប្បន្ននៅមន្ទីរកុមារក្រុងភ្នំពេញ ។ វ៉ាន់សាត មានបងប្អូន ០៥នាក់ ប្រុស០៣នាក់ (ស្រី០២នាក់) មានឈ្មោះឈឹម វុថាន់ (ភេទប្រុស) អាយុ៣៣ឆ្នាំ ជាទាហាន, ឈឹម តេង (ភេទប្រុស) អាយុ២០ឆ្នាំ នៅចម្ការដូង ឃុំដង្កោ, ឈឹម វ៉ាន់ (ភេទស្រី) អាយុ២៨ឆ្នាំ នៅមន្ទីរកុមារក្រុង, ឈឹម ពៅ (ភេទស្រី) អាយុ២៥ឆ្នាំ នៅមន្ទីរតំបន់២៣ ។ បច្ចុប្បន្ន មករស់នៅក្នុងអង្គភាពមន្ទីរតំបន់២៤ ។

វ៉ាន់សាត បានរៀនដល់ថ្នាក់ទី៧ នៅសាលាចាក់អង្រែ ។ ឆ្នាំ១៩៥២ គាត់បានផ្លាស់មកចូលរៀននៅសាលាមីស ។ នៅឆ្នាំ១៩៥៥ វ៉ាន់សាត បានផ្លាស់មករស់នៅភ្នំពេញ និងចូលរៀនបន្តនៅសាលាកម្ពុជបុត្រ ។ អំឡុងពេលរៀន វ៉ាន់សាត បានស្គាល់គ្រូ



អតីតមន្ទីរសន្តិសុខ នៅខេត្តកណ្តាល

មួយចំនួនដូចជា មី ម៉ាន់ ជាចាងហ្វាងសាលា, ខៀវ កុមារ ជាគ្រូបង្រៀន, ខាំ ខាន់ណន ជាគ្រូបង្រៀន, ប៉ែន ជាលេខាធិការសាលា ។

ឆ្នាំ១៩៥៨ វ៉ាន់សាត បានឈប់រៀននៅសាលាកម្ពុបុត្រ ដោយផ្លាស់មករៀននៅសាលាខេមរាវិញ ។ រៀននៅសាលាខេមរាដល់ថ្នាក់ទី៤ វ៉ាន់សាត ក៏ឈប់រៀន ។ វ៉ាន់សាត បានចូលបដិវត្តន៍តាមរយៈ ឈ្មោះ គីម ហុង ធ្វើការនៅពាណិជ្ជកម្ម តំបន់២០ ។ បន្ទាប់ពីចូលបដិវត្តន៍ហើយ វ៉ាន់សាត បានចាកចេញពីភ្នំពេញមកនៅភូមិស្វាយទង ឃុំស្វាយជ្រុំ ស្រុកបាភ្នំ ខេត្តព្រៃវែងវិញ ។

ខែកញ្ញា ឆ្នាំ១៩៥៨ដដែល វ៉ាន់សាត បានមកធ្វើការនៅសហករណ៍ ដែលការចូលសហករណ៍នេះ មិនមានការចាត់តាំងរបស់បក្សទេ គឺចូលដោយចិត្តឯង ។ នៅឆ្នាំ១៩៦០ វ៉ាន់សាត បានមកធ្វើការនៅការដ្ឋានជីកធ្យូងថ្ម នៅខាងសៀមប៉ាង ខេត្តស្ទឹងត្រែងវិញ ។ រយៈកាលណោះ វ៉ាន់សាត បានផ្អាកសកម្មភាពបដិវត្តន៍ហើយក៏ដាច់ខ្សែរយៈតាំងពីពេលនោះមក ។ នៅខែសីហា ឆ្នាំ១៩៦០ វ៉ាន់សាត ឈប់ពីការងារជីកធ្យូងថ្ម ហើយត្រឡប់មកភ្នំពេញវិញ ។ នៅឆ្នាំ១៩៦១ វ៉ាន់សាត បានចូលធ្វើការជាកម្មកររោងចក្រជាងដែក ហើយនៅឆ្នាំ១៩៦២ វ៉ាន់សាត ក៏ផ្លាស់ទៅធ្វើការនៅរោងពុម្ពកាសែត មានឈ្មោះ យុវមិត្ត ដែលមាននាទីជាចាងហ្វាង ។ ឈ្មោះ នៃ សារ៉ាង ហៅអាចារ្យ សៀង ជាអ្នកចាត់ វ៉ាន់សាត ឲ្យធ្វើកាសែតនេះ ។ អំឡុងពេលធ្វើជាចាងហ្វាងកាសែត វ៉ាន់សាត បានសរសេរអត្ថបទមួយចំនួនដែលមានន័យបម្រើនយោបាយបក្ស ហើយបីខែក្រោយមក វ៉ាន់សាត ក៏ត្រូវប៉ូលីសគិញចាប់ និងឃុំខ្លួន ។ អំឡុងពេលជាប់ឃុំឃាំងក្នុងគុក វ៉ាន់សាត បានជួបនឹងបង១ថ្នាក់លើរួមមាន ៖ ជូ ជេត, ជ័យ សួន (បច្ចុប្បន្ននៅកសិកម្ម) , អ៊ី ហៅ ចាន់ សេង (គណៈស្រុកត្បូងឃ្មុំ) , ហោ (គណៈស្រុកតំបែរ) , តាក់ (ក្តាប់មិនបាន) , តាលន់ នៅអង្គភាពសហករណ៍ស្រុកក្រូចឆ្មារ និង តា ថាន (គណៈស្រុកក្រូចឆ្មារ) ។ ក្រោយដោះលែងនៅឆ្នាំ១៩៦៤ វ៉ាន់សាត ក៏មានសតិអារម្មណ៍ ថ្នាំងថ្នាក់ជាមួយនឹងបក្ស មូលហេតុដោយសារបង១ យើងមួយចំនួនលែងទុកចិត្តលើខ្លួន ។

នៅឆ្នាំ១៩៦៦ វ៉ាន់សាត បានរៀបចំគ្រួសារ ដែលជានិស្សិតសាលាចម្រើនវិជ្ជា និងមានបងប្អូនធ្វើទាហាន៥ នាក់ គឺ៖

- ◆ ប៉ែន ឌឹម ពាក់សក្តិ១ ពេទ្យខាងលិចវត្តភ្នំ
- ◆ ប៉ែន ឌឿក ពាក់សក្តិ១ ជាងជួសជុលយន្តហោះ
- ◆ ប៉ែន ឌិន កាប៉ូរ៉ាល់សែហ្វ នៅគិរីរម្យ
- ◆ ប៉ែន ឌឿន កាប៉ូរ៉ាល់សែហ្វ នៅគិរីរម្យ
- ◆ ប៉ែន ដឿន កាប៉ូរ៉ាល់សែហ្វ នៅគិរីរម្យ

ក្រោយមក ម៉ិល ការិន ត្រូវបែកចេញទៅជនបទ ហើយ វ៉ាន់សាត បានភ្ជាប់ខ្សែជាមួយ សួស វិញ ។ ដល់ឆ្នាំ១៩៦៨ សួស បានចេញទៅជនបទទៀត និងបានជួបជាមួយឈ្មោះ ចំរើន បច្ចុប្បន្ននៅក្រសួងឃោសនាការរបស់មជ្ឈិម ផ្នែកខាងនិពន្ធ ។

ខែតុលា ឆ្នាំ១៩៧០ វ៉ាន់សាត បានចេញពីភ្នំពេញ មកសំណាក់នៅភូមិស្វាយទង ឃុំស្វាយទង ស្រុកមេសាង ខេត្តព្រៃវែង ។ ដល់ខែវិច្ឆិកា ឆ្នាំ១៩៧០ ឈ្មោះ ធុច បានយក វ៉ាន់សាត មកធ្វើការនៅអង្គភាពយោធា ដោយមាននាទីជាប្រធានសេដ្ឋកិច្ច “គ-៩៣” យោធាតំបន់២៤ ក្រោមការចាត់តាំងរបស់ឈ្មោះ ឈូក ។

ថ្ងៃ១៨ ខែមករា ឆ្នាំ១៩៧១ អង្គការចាត់តាំងឲ្យ វ៉ាន់សាត ទៅរៀនវគ្គយោធាភូមិភាគបូព៌ា រយៈពេល៣ខែកន្លះ ទើបចេញមកវិញ ទៅទទួលជាគណៈបញ្ជាការកងអនុសេនាធំរបស់ស្រុកត្របែក ។ ក្រោយមក វ៉ាន់សាត បានមកទទួលនាទីជាអនុស្នងការនយោបាយកងវរសេនាតូចលេខ៣ តំបន់២៤ ហើយក្រោយមកទទួលជាអនុស្នងការនយោបាយ “ង-២៥” របស់តំបន់២៤ ។ មកដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៥ ឈ្មោះ ឈូក បានចាត់តាំង វ៉ាន់សាត ធ្វើជាប្រធានមន្ទីរតំបន់២៤ រហូតដល់បច្ចុប្បន្ន ។

វ៉ាន់សាត មកកាន់ជាប្រធានមន្ទីរតំបន់២៤ ក្រោមការចាត់តាំងរបស់ឈ្មោះ ម៉ែន ដែលជាលេខាតំបន់២៤ ។ ម៉ែន បានហៅ វ៉ាន់សាត មកប្រជុំជាមួយគាត់ជារៀងរាល់ខែ និងមានការចូលរួមពីអ្នកផ្សេងទៀតមានដូចជាៈ ចាន់ ចក្រី (អនុប្រធានទទួលផ្នែកយោធា) , លី ផែន (សមាជិកទទួលបង្ហាត់យោធាភូមិភាគ) , រស់ ភួន (សមាជិកទទួលបន្ទុកផ្នែកយោធា) , លី សុផាន (សមាជិកទទួលបន្ទុកផ្នែកយោធា) , ឈឹម (សមាជិកទទួលបន្ទុកផ្នែកប្រតិភូ) ។ ចលនាក្បត់របស់ក្រុម វ៉ាន់សាត នេះ គឺមានបរទេសមួយចំនួនដែលជួយគាំទ្រផ្នែកសព្វាវុធ និងសម្ភារ មានដូចជាប្រទេសសូវៀត ឈ្មោះ ប្រែស ស៊ីនូវ ពាក់ផ្កាយ៤ , ភុស ស៊ីម៉ូវ ពាក់ផ្កាយ២ , នី កូវ ពាក់ផ្កាយ២ , ឡេង យ៉ាំងង៉ី ពាក់ផ្កាយ១ , ង៉ិកយុង ពាក់ផ្កាយ១ , ឡេ

យាំងបាយ ។ សម្ភារទាំងអស់នេះ យកទៅលាក់នៅខាងកើត ភូមិគគីរសោម មួយចំនួន, នៅខាងលិចភូមិចន្ទ្រា មួយចំនួន និងខាងខ្សែរបស់ វ៉ាន់សាត ពីរនាក់ទៀតមានឈ្មោះ ជន និងផុន ដែលអ្នកទាំងពីរចូលពីដីវៀតណាម មកនៅចាំយាម ។ ចំណែកនៅភូមិឈើទាលស្លា មានអ្នកយាមបីនាក់ ដែលមានឈ្មោះ សារិន, ម៉ៅ និងឈឿន ។ នៅភូមិកគោ គឺលាក់នៅក្នុងបន្ទាយចក្រី មានអ្នកយាមឈ្មោះ សួស និងគ្រឹម ដែលពីរនាក់នេះ សម្រាកនៅលើផ្ទះ ឈ្មោះសាយ ។ សម្ភារទាំងអស់គឺនៅក្នុងដីវៀតណាម ដែលមានបងប្អូនខ្មែរជាអ្នកទទួលខុសត្រូវនៅកន្លែងនោះ ហើយបញ្ហាយន្តហោះ រថក្រោះ ឡាន គឺផ្ញើទុកនៅវៀតណាម ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ ក្រុមរបស់ វ៉ាន់សាត បានទៅទទួលយកអាវុធ និងសម្ភារពីវៀតណាម នៅក្អមសំណរ ហើយបន្តទៅទទួលយកជំនួយពីសូវៀតទៀត ។ ពេលនោះ ម៉ែន បានហៅទាំងអស់គ្នាមកប្រជុំ ដោយលើកថា «បញ្ហានេះ ស្នើមិត្តទាំងអស់គ្នាត្រូវរក្សាការណ៍សម្ងាត់ឲ្យបានស្ងាត់ល្អ តែបើបែកការណ៍ត្រូវគ្រោះថ្នាក់ទាំងអស់គ្នា ។ ចំពោះបញ្ហាភារកិច្ចគឺចុះចលនារៀងៗខ្លួន ។ ចលនាក្បត់នេះ មានកម្លាំងនយោបាយប្រើរបៀបស្របច្បាប់ជាមួយបដិវត្តន៍ដែរ មិនខុសពីមាគ៌ាបក្សទេ ហើយកម្លាំងយោធាមួយ ចំណែកសូវៀតបានជួយទាំងសម្ភារ និងកម្លាំង ។ កម្លាំងដែលសូវៀត ជួយមានចំនួនមួយម៉ឺននាក់, វៀតណាមប្រាំពាន់នាក់ និងសៀមមួយម៉ឺននាក់ ដោយមានអាវុធជាប់នឹងខ្លួនស្រាប់» ។

ក្រោយពីការប្រជុំនេះ ម៉ែន បានសរសេរលិខិតមួយទៅឈ្មោះ សំ សមាជិកគណៈ អ.ប.ត តំបន់៥ និងឈ្មោះម្នាក់ទៀត មិនស្គាល់ឈ្មោះ ដែលមាននាទីជាលេខាស្រុកសេរីសោភណ្ឌ ឲ្យមកប្រជុំនៅតំបន់២៨ និងដើម្បីទទួលយកជំនួយពីសូវៀត ។ បន្ទាប់ពីការប្រជុំមក ម៉ែន បានឲ្យអ្នកនៅខាងពាយ័ព្យចាំរៀបចំ និងត្រៀមទទួលមិត្តខាងសៀម ហើយច្រកដែលដឹកនាំអាវុធចូលមកក្នុងប្រទេស គឺមកតាមច្រកឈូងសមុទ្រកំពង់សោម ដោយយកកូនកាណូតចល័តតាមសមុទ្រសៀម រួចហើយឆៀងចូល មកឈូងសមុទ្រកម្ពុជាយើងវិញ រួចក៏ឆៀងចូលទៅស្រុកយួនវិញ ទើបចូលមកដីខ្មែរ ។ ចំពោះផែនការរបស់ ម៉ែន គឺមានទិសវាយផ្តួលរំលំរបបបដិវត្តន៍ ១៧ មេសា ១៩៧៥ ហើយ កសាងរបបសង្គមសេរីនិយម ដែលមានសហភាពសូវៀតដឹកនាំ ។

តាមគម្រោងផែនការនេះ គឺនឹងធ្វើនៅខែមេសា ឆ្នាំ១៩៧៦ ឲ្យអស់របបបដិវត្តន៍ក្នុងរយៈពេល ១៥ នាទី មិនឲ្យមាននៅសល់ ។ ទិសដៅដែលកំណត់ឲ្យបរទេសចូលតាមច្រកដូចតទៅ ៖ ខាងសូវៀត ចូលតាមច្រកបន្ទាយចក្រី ក្អមសំណរលើ តាមទន្លេមេគង្គ តាមច្រកកោះធំ ស្អាង, ខាងវៀតណាម ចូលតាមច្រក ភ្នំដិន ទន្លាប់ គិរីវង្ស ខាងស្នួល តាមច្រកស្នាច់, ច្រកមេមត់ និងខាងសៀម ចូលតាមច្រកគោប អំពិល០៥ ដើម, ខាងប៉ោយប៉ែត អូរជ្រៅ និងអារញ្ញ ។ នេះជាទិសយុទ្ធសាស្ត្រដែលបានគ្រោងទុក ហើយបញ្ហាគម្រោងនេះ គឺបានពិភាក្សាជាមួយសូវៀត វៀតណាម និងសៀម បានដឹងច្បាស់លាស់អស់ហើយ ជាមួយនេះគឺបានឲ្យផែនទីសម្រាប់មើលផង ។

**ចៅ ព្រហស្បតិ៍**


# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# បញ្ហាអនាគតរបស់យុវជន យុវនារីកម្ពុជាដែលគេ បានសន្ទនារបស់បក្ស ក្នុងសាលាអប់រំយុវជន យុវនារីនៅចុងខែមករា ឆ្នាំ១៩៧៤

*ដកស្រង់ចេញពីឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ២ ខែកុម្ភៈ ១៩៧៤ (D២១៣៧៩)*

***សំណូមពរ***

គឺដើម្បីឲ្យមិត្តយុវជន យុវនារីទាំងអស់ឃើញអនាគតនៃជាតិ ប្រជាជន និងយុវជនយុវនារីយើង តើយ៉ាងម៉េច? ហើយយុវជន យុវនារីយើងម្នាក់ៗ ត្រូវកសាងខ្លួនយ៉ាងម៉េច ដើម្បីធានាអះអាង អនាគតនៃជាតិ ប្រជាជន បដិវត្តន៍ និងបក្សយើង?

***១) ក្នុងរបបសក្តិភូមិ នាយទុន តើអនាគតរបស់យុវជន យុវនារីយើងយ៉ាងម៉េច?***

ក្នុងរបបសក្តិភូមិ នាយទុន វណ្ណៈដែលកាន់កាប់រដ្ឋអំណាច គឺសក្តិភូមិ នាយទុន ដែលជាវណ្ណៈជិះជាន់ ។ ឯអ្នកដែលត្រូវគេគ្រប់គ្រងជិះជាន់ គឺប្រជាជន កម្មករ កសិករ អនុធន បញ្ញាជន ក្នុងនេះមានយុវជនយុវនារីមួយភាគសំខាន់ណាស់ ។

វណ្ណៈសក្តិភូមិ នាយទុន វាមានផលប្រយោជន៍វណ្ណៈរបស់វា ផ្ទុយពីផលប្រយោជន៍វណ្ណៈកម្មករ កសិករ អនុធន ។ ហេតុនេះដើម្បីរក្សានឹមជិះជាន់របស់វាយូរអង្វែងតទៅទៀត វណ្ណៈសក្តិភូមិ នាយទុន វាបង្កើតរបបអប់រំ ប្រតិកិរិយាជាខ្សែសង្វាក់សំដៅទៅបម្រើផលប្រយោជន៍របបវា ។ គឺវាអប់រំយុវជន យុវនារីយើងគិតគូរតែបុគ្គលខ្លួន គ្មានទឹកគិតដល់អនាគតរបស់ប្រទេសជាតិ និងប្រជាជនសោះ ។

**ឧទាហរណ៍:** យុវជន យុវនារីជាកសិករ គិតតែធ្វើស្រែចម្ការ យកស្រូវហូប ។ ដល់ពេលរយរកគ្រួសារ ក៏សម្លឹងមើលកូនគេអ្នកគ្រាន់បើ មានដីធ្លី មានគោក្របី រទេះសាឡី ដើម្បីខ្លួនមានជីវភាពគ្រាន់



សិស្សសាលានៅក្នុងរបបខ្មែរក្រហម

បើនឹងគេដែរ ។

**ឧទាហរណ៍៖** យុវជន យុវនារីជាអនុធនសិស្ស និងបញ្ញាជន គិតតែពីខំរៀនឲ្យជាប់សញ្ញាប័ត្រធំ ឬឲ្យបានចេញទៅរៀននៅបរទេស ដើម្បីត្រឡប់មកវិញបានធ្វើធំ មានប្រាក់ខែច្រើន មានមុខមាត់ មានគ្រួសារល្អស្អាត ជាកូនអ្នកមាន ឬកូនអ្នកធំ ។

រីឯឪពុកម្តាយទៀតសោត ក៏គិតតែធ្វើយ៉ាងម៉េចឲ្យកូនចៅខ្លួន បានរៀនសូត្រច្រើន និងបានធ្វើធំ ។ ត្រូវលក់គោក្របីក៏លក់ ។ ត្រូវលក់ស្រែចម្ការក៏លក់ ។ ឪពុកម្តាយខ្លះទៀត ខំសម្លឹងមើលអ្នកមានបណ្តាសក្តិធំ មានប្រាក់ខែច្រើន ដើម្បីហៅកូនស្រី ដើម្បីឲ្យកូនស្រីខ្លួនបានស្រួល មានមុខមានមាត់ខ្ពង់ខ្ពស់នឹងគេ ។

នេះគឺមកពីពួកសក្តិភូមិ នាយទុន វាអប់រំប្រជាជន និងយុវជនយើងទាំងមូលឲ្យរត់តាមតែផលប្រយោជន៍បុគ្គលខ្លួន កុំឲ្យគិតដល់ផលប្រយោជន៍ប្រទេសជាតិ ។ ចង់ប្រទេសជាតិត្រូវចក្រពត្តិឈ្លានពានយ៉ាងម៉េច ក៏ឈ្លានពានទៅ ។ ចង់កសិករក្រខ្សត់អត់ឃ្លានលំបាកវេទនាយ៉ាងម៉េចក៏លំបាកទៅ ។ គឺថាអនាគតរបស់យុវជនយុវនារីយើងដាច់ស្រឡះចេញពីអនាគតជាតិ ប្រជាជន និងបដិវត្តន៍ ។

ក្នុងលក្ខណៈសម្បត្តិនេះ យុវជន យុវនារីយើងវង្វេងមិនដឹងជាទៅខាងណា មកខាងណាទេ ។ មិនដឹងធ្វើស្រែដើម្បីអី មិនដឹងរៀនដើម្បីអី ។ យុវជនកសិករខំធ្វើស្រែសឹងស្លាប់ មួយឆ្នាំពេញមួយឆ្នាំគ្មានដែលទំនេរដៃទេ សម្រេចសម្រួចទៅបានត្រឹមតែឆ្អែតព្រឹក ខ្វះល្ងាចប៉ុណ្ណោះ ។ យុជនសិស្សខ្លះ ខំរៀនទាល់តែស្គាំងស្គមខ្លួន ខំទន្ទេញភាសាបរទេសដូចសេកទម្រាំបានប្រឡងជាប់ ខូចខ្លួនល្មម ខ្លះសុខភាពចុះខ្សោយរហូត ខ្លះទៅជារបេងរីងរៃ ខ្លះទៅជាខូច ឬខ្សោយសរសៃប្រសាទ ។ល ។ ឬដល់បានការងារធ្វើហើយ ក៏ជាការងារបម្រើពួក



កម្មករបដិវត្តន៍នៅរោងចក្រកំពុងជួសជុលបំពង់បូមទឹក

វណ្ណៈជិះជាន់ដែរ ។

ក្នុងក្របខណ្ឌនៃរបបសក្តិភូមិ នាយទុន ទោះជាយុវជន យុវនារីកសិករ និងយុវជន យុវនារីសិស្សយើង ខំប្រឹងយ៉ាងម៉េចក៏គេចមិនផុតពីការជិះជាន់ដែរ ។ យ៉ាងច្រើនណាស់ បានត្រឹមតែរួចខ្លួនប៉ុណ្ណោះ ។ រីឯរបបសក្តិភូមិ នាយទុនវិញ វាកាន់តែពង្រឹងខ្លួនវាឡើង ។ នេះជាសភាពពិត និងជាខ្លឹមសារនៃរបបសក្តិភូមិ នាយទុន ។

តែមានយុវជន យុវនារីយើងខ្លះ ភាន់ច្រឡំទៅតាមរូបភាពប្រជាភិថុតិរបស់វា ឃើញរបបវាហាក់ដូចជាសប្បាយ ព្រោះមានការស៊ីផឹក រាំរែក ពុករលួយ ចម្រៀង កុនល្ខោន ពាលាអាវ៉ាសែ ។ ឃើញដូចជាអនាគតខ្លួនភ្លឺស្វាង ។ តែតាមពិតនេះ គឺជាសកម្មភាពពិសពុលរបស់វណ្ណៈសក្តិភូមិ នាយទុនដែលវាពង្រក់ បំពុលយុវជន យុវនារីយើង ឲ្យវិងស៊ុង ដើម្បីវាងាយយកកម្លាំងយុវជន យុវនារីយើងទៅប្រើប្រាស់សម្រាប់ការពាររបបវា ។

នៅភ្នំពេញសព្វថ្ងៃពួកអាក្បត់លន់នល់, សិរិមតៈ, សឺងង៉ុកថាញ់, អ៊ិនតាំ ដែលជាតំណាងសក្តិភូមិ នាយទុនប្រតិកិរិយា បរិវារចក្រពត្តិអាមេរិក វាលុបបំបាត់អស់ហើយ លក្ខណៈជាតិជាយុវជនកម្ពុជា ។ វាបញ្ចូលវប្បធម៌ចក្រពត្តិជាខ្សែសង្វាក់ ដើម្បីបំពុលយុវជន យុវនារីយើង និងចាប់យុវជន យុវនារីយើងធ្វើជីវពល នារីក្លាហានកងស្ម័យគ្រាណ កុម្ម៉ង់ដូ ទាហាន ឲ្យការពារក្បាល និងរបបក្បត់របស់វា ។ យុវជន យុវនារីខ្លះស្លៀកខោជើងធំដូចស្លឹកត្រចៀកដំរី ខ្លះទុកសក់ប្រាសស្នាដូចស្វា មិនដឹងនរណាប្រុស នរណាស្រីទេ ។

នៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្ននៃអាសាធារណរដ្ឋក្បត់ អនាគតរបស់យុវជន យុវនារីត្រូវធ្លាក់ទៅក្នុងរណ្តៅងងឹតសូន្យសុង ។ ខ្មាំងវាកំពុងត្រូវកងទ័ព និងប្រជាជនយើង វាយសម្រុកពីគ្រប់



ទិសទី ។ តែវាចាប់យុវជន យុវនារីយើងធ្វើជាសាច់ទ័ពរុញឲ្យទៅងាប់ការពារក្បាល និងរបបក្បត់វាទៅវិញ ។ យុវជន យុវនារីយើងនៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្ដោះអាសន្ន គ្មានអនាគតរបស់ខ្លួនទេ ។ អនាគតរបស់យុវជន យុវនារីយើង គឺគ្រាន់តែសម្រាប់បម្រើផលប្រយោជន៍ចក្រពត្តិអាមេរិក និងសក្តិភូមិ នាយទុនប្រតិកិរិយាតែប៉ុណ្ណោះ ។

**២) ក្នុងសម័យបដិវត្តន៍យើងនេះ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា តើអនាគតយុវជន យុវនារីយើងយ៉ាងម៉េច?**

ទស្សនៈ និងគោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជា គឺចាត់ទុកយុវជនយុវនារីយើងជាម្ចាស់នៃអនាគតប្រទេសជាតិ ។ ដូច្នេះក្នុងសម័យបដិវត្តន៍ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា យុវជន យុវនារីយើង មានតម្លៃខត្តង់ខត្តម ហើយមានអនាគតភ្លឺចែងចាំង ផ្ទុយស្រឡះពីរបបសក្តិភូមិ នាយទុន ខុសគ្នាដូចមេឃ និងដីដូចថ្ងៃ និងយប់ ។ (ទះដៃយ៉ាងយូរ) ។

ដើម្បីមើលឃើញការយកចិត្តទុកដាក់របស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះអនាគតយុវជន យុវនារីយើង សូមសមមិត្តពិនិត្យការជាក់ស្តែងមួយចំនួនដូចតទៅៈ

១) បក្សកុម្មុយនីស្តកម្ពុជា ដឹកនាំជាតិ ប្រជាជន វាយបណ្តេញចក្រពត្តិអាមេរិក និងរំលំបនអាក្បត់ជាសក្តិភូមិ នាយទុនប្រតិកិរិយា រំដោះប្រជាជាតិ ប្រជាជន ក្នុងនោះមានយុវជន យុវនារីយើងផងដែរ ។ បក្សពុំអាចបណ្តោយឲ្យយុវជន យុវនារីយើង ធ្លាប់ទៅជាខ្ញុំកញ្ជះចក្រពត្តិអាមេរិក និងពួកអាក្បត់បានទេ ។ ទោះជាមានការលំបាកយ៉ាងណា ក៏បក្សកុម្មុយនីស្តកម្ពុជាពុះពាររំដោះជាតិ ប្រជាជន និងយុវជន យុវនារីយើងដាច់ខាត ។ យើងរំដោះជាតិ ប្រជាជន និងយុវជនយុវនារីយើង បានជាងកៅសិបភាគរយហើយ ។ យើងកំពុងបន្តវាយខ្មាំងយ៉ាងខ្លាំងក្លាបំផុត ដើម្បីឈានទៅរំដោះជាតិ ប្រជាជន និងយុវជន យុវនារីយើងឲ្យបានទាំងស្រុង ។ (ទះដៃយ៉ាងយូរ) ។

២) បក្សកុម្មុយនីស្តកម្ពុជា រៀបចំមូលដ្ឋានរំដោះ ឲ្យមានលក្ខណៈប្រជាធិបតេយ្យ (គឺប្រជាធិបតេយ្យរបស់ប្រជាជនមិនមែនប្រជាធិបតេយ្យរបស់សក្តិភូមិ នាយទុនទេ) ។

◆ **រដ្ឋអំណាចៈ** ក៏បក្សប្រគល់ឲ្យកសិករក្រ និងកណ្តាលថ្នាក់ក្រោម និងយុវជន យុវនារីយើងកាន់កាប់ ដើម្បីបម្រើផលប្រយោជន៍ប្រជាជន និងយុវជន យុវនារីយើង ។

◆ **ខាងសេដ្ឋកិច្ចៈ** ក៏បក្សចាត់តាំងសហករណ៍ផលិតកម្មកម្រិតទាប កម្រិតខ្ពស់ស្អេកស្កះ ។ នេះគឺដើម្បីរំដោះប្រជាជន និងយុវជន យុវនារីយើងឲ្យផុតពីការជិះជាន់របស់សក្តិភូមិ នាយទុន ។

ក្នុងសង្គមចាស់ ប្រជាជនកសិករយើង វេទនាខ្លាំងណាស់ ។ នេះគឺមកពីខ្មាំងវាជិះជាន់ ។

**ឧទាហរណ៍ៈ** នៅរដូវច្រូតម្តងៗ កសិករយើងគ្រាន់តែបោកបែនរោយស្រូវហើយភ្លាម ពួកអាសក្តិភូមិ នាយទុន ប្រតិកិរិយា វាប្រដែងគ្នាដណ្តើមកើបវាល់ស្រូវប្រមូលយកអស់រលីងភ្លាម ។ ម្ល៉ោះហើយប្តីប្រពន្ធនាំគ្នាមូរកន្ទេលទទេទូលទៅផ្ទះវិញទាំងទឹកភ្នែកកំហឹង ។

◆ បក្សកុម្មុយនីស្តកម្ពុជា ខំអប់រំយុវជន យុវនារីយើង ឲ្យយល់ពីបញ្ហាជាតិ បញ្ហាវណ្ណៈ មាគ៌ានយោបាយរបស់បក្ស លោកទស្សនៈបដិវត្តន៍ សីលធម៌បដិវត្តន៍ និងភារកិច្ចរបស់យុវជន យុវនារី ដើម្បីឲ្យយុវជនយុវនារីយើងចូលរួមក្នុងចលនាបដិវត្តន៍ និងត្រៀមរៀបចំខ្លួនតាំងពីពេលនេះទៅ ដើម្បីធ្វើជាម្ចាស់លើវាសនាជាតិខ្លួន និងធ្វើជាម្ចាស់លើវាសនាខ្លួនទៅអនាគត ។

លុះសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យហើយ បក្សនៅតែបន្តបេសកកម្មខ្លួនតទៅទៀត ។ បក្សមិនបណ្តោយឲ្យកេរដំណែលរបស់បក្ស ចំពោះយុវជនធ្លាក់ទៅក្នុងដៃវណ្ណៈណាដាច់ខាត ។ គឺបក្សកុម្មុយនីស្តកម្ពុជា បន្តដឹកនាំប្រជាជន និងយុវជនយុវនារីយើងកសាងសង្គម សង្គមនិយម និងកុម្មុយនីស្តនិយមតទៅទៀត ដែលជាសង្គមគ្មានមនុស្សជិះជាន់មនុស្ស (ទះដៃវែង) ។

សរុបមក ក្នុងសម័យបដិវត្តន៍ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា អនាគតរបស់យុវជន យុវនារីយើងផ្សារភ្ជាប់គ្នាជាសាច់មួយបេះមិនដាច់ពីអនាគតរបស់ជាតិ ប្រជាជន បដិវត្តន៍ និងបក្ស ។ ដូច្នេះ វាខុសគ្នាមេឃនឹងដី ពីក្នុងរបបសក្តិភូមិ នាយទុនដែលអនាគតយុវជន យុវនារីយើង នៅជាប់ជំពាក់តែនឹងផលប្រយោជន៍បុគ្គល ដាច់ពីផលប្រយោជន៍ប្រទេសជាតិ ហើយធ្លាក់ទៅក្នុងរណ្តៅងងឹតសូន្យសុង ។

ឃើញទស្សនៈ គោលជំហរ និងសកម្មភាពរបស់បក្សចំពោះយុវជនយុវនារីយើងដូច្នេះហើយ តើយុវជនយុវនារីយើងត្រូវមានភារកិច្ចអ្វីខ្លះ ដើម្បីធ្វើម្ចាស់លើវាសនាជាតិខ្លួន និងលើវាសនាខ្លួន ។

**៣) តើយុវជន យុវនារីយើង ត្រូវកសាងខ្លួនយ៉ាងម៉េច ដើម្បីធ្វើម្ចាស់លើវាសនាប្រទេសជាតិខ្លួន?**

ក្នុងតំបន់រំដោះ យើងវាយកម្ទេចខ្មាំង កម្ចាត់ការទាក់ទងផលិតកម្មចាស់ ជិះជាន់អស់ជាមូលដ្ឋានហើយ ។ យើងបានបំផុសវប្បធម៌ សង្គមកិច្ចបដិវត្តន៍ស្អាតស្អំពាសពេញ ។ នេះជាទិដ្ឋភាពមួយ ។ ក៏ប៉ុន្តែ ទិដ្ឋភាពមួយទៀត យើងត្រូវឃើញថា ទស្សនៈចាស់ គោលជំហរសតិអារម្មណ៍ចាស់ ទម្លាប់ចាស់ របស់សក្តិភូមិ នាយទុន វានៅមានអនុភាពនៅឡើយ នៅក្នុងតំបន់រំដោះយើង ជាពិសេស គឺនៅមានក្នុងស្រទាប់លើអ្នករដ្ឋការចាស់ឱនថយ និងយុវជន យុវនារីឱនថយ មិនទាន់បដិវត្តន៍ ។

**ឧទាហរណ៍៖** ក្នុងទីប្រជុំជនខ្លះ របៀបរបបរស់នៅរបស់យុវជន យុវនារីយើង មិនទាន់ស្អាតស្អំ តាំងពីសីលធម៌ ប៉ុកពារ ស្លៀកពាក់ និយាយស្តី លេងសើចឡើងទៅ ។

**ឧទាហរណ៍៖** សូម្បីតែនៅក្នុងជួរបដិវត្តន៍យើងហើយ ក៏នៅមានទស្សនៈគោលជំហរ និងលោកទស្សនៈចាស់របៀបនេះដែរ ។

នេះជាសភាពធម្មតានៃវត្ថុធាតុ ទៅតាមសម្ភារនិយមបដិច្ចសមុប្បាទទេ ។ យើងកុំភ្ញាក់ផ្អើល។ សមមិត្តមើល ក្រោយភ្លៀងម្តងៗ មេឃតែងតែនៅរលឹមស្រិចៗ បង្អិចសិន ។ បន្ទាប់មក ទើបដាច់គ្រាប់ ហើយព្រះអាទិត្យ ក៏រះចែងចាំងឡើង ។ ដូច្នេះ យើងត្រូវឃើញថា សភាពមិនបដិវត្តន៍នេះ នៅមាននៅឡើយ តែវាមិនមែនជាបញ្ហាមូលដ្ឋានទេ ។ បញ្ហាជាមូលដ្ឋានគឺបដិវត្តន៍ ។ ឯសំណល់ជាទម្លាប់ចាស់ សតិអារម្មណ៍ចាស់ទាំងនេះ វាជាបន្ទាប់ទេ ។ វាជាបន្ទាប់ក៏ពិតមែន តែយើងមិនត្រូវអត្តនោម័តិទេ ពីព្រោះវាជាឥទ្ធិពលអាក្រក់តិចច្រើនមកលើយុវជន យុវនារីយើង ។

ដូច្នេះ យុវជន យុវនារីយើងទាំងអស់ បើឃើញអនាគតប្រទេសជាតិ ជាអនាគតរបស់សមមិត្តហើយ សមមិត្តត្រូវបដិវត្តន៍ខ្លួនឯង គឺធ្វើបដិវត្តន៍កម្ចាត់ធាតុមិនបដិវត្តន៍ កម្ចាត់ទម្លាប់ចាស់ ឲ្យជ្រះស្រឡះចេញពីខ្លួន ។ ដើម្បីបដិវត្តន៍ខ្លួនឯងបាន យើងត្រូវមានកម្លាំងបដិវត្តន៍មួយខ្លាំងគ្រប់គ្រាន់នៅក្នុងខ្លួន ។ បក្សខំកសាងសមមិត្តហើយ ។ តែសមមិត្តត្រូវធ្វើជាម្ចាស់លើខ្លួនឯង ។ កុំ«រំពឹងតែលើបងៗ។ ស្រេចតែបងៗ។» ឲ្យសោះ ។ បងៗធ្វើបដិវត្តន៍មុន នៅមានជំហរសតិអារម្មណ៍រឹងប៉ឹង ប៉ុន្តែកម្លាំងវាអន់បន្តិចទៅហើយ ។ បើប្រៀបធៀបទៅនឹងថ្ងៃវិញ គឺវារសៀលជ្រេទៅហើយ រីឯសមមិត្តជាយុវជន យុវនារីវិញ គឺប្រៀបបានទៅនឹងថ្ងៃដែលកំពុងរះ ដូច្នេះ


កម្មករបដិវត្តន៍នៅរោងចក្រតម្បាញ

គឺមានតែសមមិត្តជាយុវជន យុវនារីហ្នឹងហើយ ដែលត្រូវបន្តវេនជ្រោងគ្រវីទង់បដិវត្តន៍យើង ឲ្យខ្ពស់ត្រដែតត្រដឹមតទៅទៀត ។ ការណ៍នេះ ចង់ឬមិនចង់ សមមិត្តចៀសមិនផុតទេ ព្រោះផុតពីបងៗទៅសមមិត្តជាយុវជន យុវនារីត្រូវបន្តវេន ។ ផុតពីសមមិត្តទៅប្អូនៗកុមារខាងក្រោយ ក៏នឹងត្រូវបន្តវេនតទៅទៀត ។ សព្វថ្ងៃកុមារៗ ប្អូនៗជំទង់ កំពុងមើលគំរូសមមិត្តជាយុវជន យុវនារី (ពីអាយុ១៨ ទៅ៣០ឆ្នាំ) ។

ដូច្នេះ យុវជន យុវនារីយើង ត្រូវធ្វើជាគំរូល្អ ជាពុម្ពល្អ ដោយយើងត្រូវបដិវត្តន៍ខ្លួនឯង ។ ពោលគឺត្រូវកម្ចាត់សតិអារម្មណ៍បុគ្គលនិយមចេញឲ្យជ្រះស្រឡះ គឺបុគ្គលនិយម ជាសួនតួ មុខមាត់ បុណ្យស័ក្តិ បុគ្គលនិយម ជាសេរី ឯកចិត្ត បុគ្គលនិយម ជាមោទកភាពខុសឆ្គង ហើយកសាងសតិអារម្មណ៍សមូហភាពនិយម និងលោកទស្សនៈបដិវត្តន៍គ្រប់ផ្នែកជំនួសវិញ ។

បើយុវជន យុវនារីយើងជំនាន់នេះ បដិវត្តន៍ខ្លួនឯង ក្រោមការដឹកនាំរបស់បក្ស ឲ្យទៅជាពុម្ពល្អសម្រាប់យុវជនជំនាន់ក្រោយៗទៀត នោះសីលធម៌ប្រយុទ្ធដាច់ខាត លះបង់ដាច់ខាតរបស់យើង វាបេះតែស្រួចទៅៗពីជំនាន់មួយទៅជំនាន់មួយទៀត វានៅតែក្រហមឆ្អិនឆ្អៅជានិច្ច ពីជំនាន់មួយទៅជំនាន់មួយជាបន្តបន្ទាប់ជាប់មិនដាច់ ។ ក្នុងលក្ខណៈសម្បត្តិនេះ ប្រជាជនយើងអាចបន្តធ្វើសង្គ្រាមបដិវត្តន៍ ដើម្បីកិត្តិយសជាតិ និងអត្តភាពជាតិ ដោយឯករាជ្យម្ចាស់ការ ដប់ឆ្នាំទៀតក៏បាន ម្ភៃឆ្នាំទៀតក៏បាន រហូតដល់១០០ឆ្នាំទៀតក៏បាន ។

ទន្ទឹមនឹងនេះ សមមិត្តត្រូវក្តាប់ធាតុរបស់យុវជន យុវនារីយើងឲ្យជាប់ ។ យុវជន យុវនារីយើងមានធាតុល្អ ត្រង់ឆាប់ទទួលធាតុថ្មីនិងធាតុចម្រើនរហ័សណាស់ ។ តែទន្ទឹមនឹងនេះយុវជនយុវនារីយើង ក៏មានធាតុបុគ្គលខ្ពស់ដែរ ដូចជាវីរភាពបុគ្គលជាដើម ។ យើងត្រូវឃើញចំណុចខ្លាំង និងចំណុចខ្សោយរបស់យុវជនយុវនារីយើង ហើយប្រយុទ្ធកសាងខ្លួន និងកសាងសមមិត្តដទៃ ឲ្យសមស្របទៅតាមធាតុនេះ ។

សមមិត្តត្រូវធ្វើបដិវត្តន៍ខ្លួនឯងជានិច្ច ដាច់ខាត និងជាយុទ្ធសាស្ត្រ ធ្វើឲ្យយុវវ័យរបស់សមមិត្ត នៅតែមានពណ៌ក្រហមឆ្អិនឆ្អៅជានិច្ច កុំឲ្យវាស្រអាប់ ឬទៅជាខ្មៅបាន ។

ពេលស្រួលក្តី ពេលលំបាកក្តី សមមិត្តត្រូវមានជំហរសតិអារម្មណ៍បដិវត្តន៍ឲ្យរឹងជាប់ កុំធ្វេសប្រហែសឲ្យសោះ ពីព្រោះសព្វថ្ងៃការតស៊ូប្រជាជាតិកាន់តែខ្លាំង ការតស៊ូវណ្ណៈកាន់តែមុត ហើយការតស៊ូព្វផ្ទៃក្នុងខ្លួនយើងម្នាក់ៗ ក៏កាន់តែស៊ីជម្រៅឡើង ។ ដូច្នេះសមមិត្តត្រូវកសាងជំហរបដិវត្តន៍ជាយុទ្ធសាស្ត្រ ដើម្បីរំដោះជាតិប្រជាជន និងរំដោះខ្លួនឲ្យបានចាកផុតពីស្លាក "ខ្ញុំគេ" ជារៀងរហូតទៅ ។

### ៤) ពិសោធមួយចំនួន ក្នុងការកសាងគោលជំហរនយោបាយសតិអារម្មណ៍ ចាត់តាំងរបស់យុវជន យុវនារីយើង

សមមិត្តយើងខ្លះ បានចូលរួមបដិវត្តន៍យូរមកហើយ ។ សមមិត្តខ្លះ ទើបនឹងចូលក្រោយរដ្ឋប្រហារ ។ ឯខ្លះទៀតក៏ទើបតែចូលជាបន្តបន្ទាប់ ។

ជារួម យុវជន យុវនារីយើង កសាងខ្លួនបានល្អជាមូលដ្ឋាន ។ ដើម្បីជំរុញការកសាងខ្លួននេះ ឲ្យខ្លាំងក្លាថែមទៀត យើងខ្ញុំសូមលើកពិសោធមួយចំនួនដូចតទៅៈ

**ពិសោធទី១** ត្រូវកសាងខ្លួនពីក្រោមឡើងលើ "ដើម្បីកសាងខ្លួនបានល្អ ត្រូវកសាងខ្លួនចាប់ពីក្រោមឡើងលើ" គឺត្រូវដុតដំខ្លួនតាំងពីក្នុងការងារគ្រប់បែបយ៉ាងឡើងទៅ ដូចជាធ្វើកូនក្រុមយុវកកធ្វើនីរសារ ដឹកជញ្ជូន ដាំបាយ ធ្វើពេទ្យ ធ្វើស្រែចម្ការ បង្កបង្កើនផល ។ល ។ ការងារទាំងនេះ បើមិនយល់ថាជាការងារទាបថោក ។ សមមិត្តខ្លះមិនចង់ធ្វើទេ ចង់ធ្វើកម្មាភិបាលតែម្តង ។ តែការងារទាំងនេះហើយ ដែលកសាងខ្លួនយើងបានល្អ ។

ពីកម្មាភិបាលល្អ ត្រូវឡើងពីក្រោមមក ទើបវាឆ្អិន ។ ហេតុនេះសមមិត្តកុំប្រកាន់ខ្លួន ។ អង្គការប្រគល់ការណាឲ្យធ្វើ ត្រូវខិតខំធ្វើការនោះ ឲ្យអស់ពីចិត្តពីថ្លើម ព្រោះការងារណាក៏ជាការងារបដិវត្តន៍ដែរ ។ តាមពិសោធកន្លងមក សមមិត្តណាដុតដំខ្លួនពីការងារតូចៗឡើងទៅទើបទៅជាកម្មាភិបាលល្អ ព្រោះកម្មាភិបាលបដិវត្តន៍យើង មិនមែនគ្រាន់តែអង្គុយ "ស៊ីញ៉េ" ដូចនាម៉ឺនសក្តិភូមិឯណា ។ ធ្វើកម្មាភិបាលត្រូវដោះស្រាយគ្រប់បញ្ហា តាំងពីខ្វះអំបិល ខ្វះប្រហុក ខ្វះថ្នាំសង្កូវ រហូតដល់ធ្វើការងារនយោបាយសតិអារម្មណ៍ទៀត ។ បើធ្វើប្រធានមន្ទីរបានល្អ ទៅគ្រប់គ្រងភូមិក៏បានល្អ គ្រប់គ្រងឃុំក៏បានល្អ ហើយឡើងទៅដឹកនាំប្រទេសក៏បានល្អ ព្រោះវាមានបទពិសោធគ្រប់ជ្រុង

ជ្រោយតាំងពីការងារតូចតាចឡើងទៅ ។

ពាក្យស្លោករបស់យើងគឺ "ត្រូវយកការងារធ្វើគ្រូ តែកុំធ្វើគ្រូការងារឲ្យសោះ" បើធ្វើគ្រូការងារហើយ មុខតែអត្តនោម័តិហើយ ។ ដាំបាយ នីរសារ ពេទ្យ ពលកម្មបង្កបង្កើនផល នេះសុទ្ធតែជាគ្រូទាំងអស់ ព្រោះការងារទាំងនេះ វាកសាងជីវភាពសតិអារម្មណ៍ និងផ្ដល់ពិសោធឲ្យយើង ។ ហេតុនេះ សមមិត្តត្រូវស្រឡាញ់គ្រូសមមិត្ត គឺត្រូវជិតស្និទ្ធ និងការងាររបស់សមមិត្ត ។

**ឧទាហរណ៍ៈ** វាយខ្មាំងជាគ្រូមួយ ។ តើហ៊ានវាយ ឬមិនហ៊ាន? បើហ៊ានវាយ មុខតែមានពិសោធទាំងខាងសតិអារម្មណ៍នយោបាយ ទាំងខាងបច្ចេកទេសប្រយុទ្ធ ។

សមមិត្តត្រូវញុកញីក្នុងការងារ ។ សមមិត្តមិនចេះអក្សរលេខ ត្រូវតែខំរៀនអក្សរ លេខ ឲ្យចេះឡើង ។ តែការណ៍នេះ មិនជាសំខាន់កំណត់ទេ ។ ការសំខាន់កំណត់ គឺការងារ គឺចលនាបដិវត្តន៍ ។

**ពិសោធទី២** ត្រូវធ្វើម្ចាស់លើខ្លួនឯង កុំមើលអ្នកដទៃ "ដើម្បីកសាងខ្លួនបានល្អ សមមិត្តត្រូវធ្វើម្ចាស់លើខ្លួនឯង ដោយប្រៀបធៀបខ្លួនទៅនឹងជីវភាពមាគ៌ារបស់បក្ស តែកុំប្រៀបធៀបខ្លួនទៅនឹងអ្នកដទៃ ។ អ្នកដទៃជាធម្មតាទេ តែងតែមានចំណុចល្អ និងចំណុចខ្វះខាត ព្រោះសុទ្ធតែចេញមកពីសង្គមចាស់ដូចគ្នា ។ សំខាន់គឺសមមិត្តត្រូវធ្វើម្ចាស់លើខ្លួនឯងឲ្យបានរឹងមាំ ។

**ឧទាហរណ៍ៈ** សមមិត្តខ្លះនៅកន្លែងលំបាករឹង ។ ដល់ប្ដូរទៅនៅកន្លែងស្រួលដួល ព្រោះរវាតពីគោលជីវភាពបដិវត្តន៍ ព្រោះមិនម្ចាស់ការលើខ្លួនឯង ជាហេតុនាំឲ្យសភាពសត្យានុម័តិដែលមិនបដិវត្តន៍ វាអូសទាញបាន ។

ដូច្នេះ ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ យើងត្រូវទទួលខុសត្រូវលើខ្លួនយើង និងលើភារកិច្ចយើង ចំពោះជាតិ ប្រជាជន បដិវត្តន៍ និងបក្សជានិច្ច ។

**ពិសោធទី៣** ត្រូវអប់រំកសាងខ្លួនឲ្យជាប់ជានិច្ច "ដើម្បីកសាងខ្លួនបានល្អ សមមិត្តត្រូវអប់រំ កសាងខ្លួនដោយខ្លួនឯងឲ្យជាប់ជានិច្ច កុំចាំតែវគ្គ ចាំតែប្រជុំ ។ ត្រូវកសាងខ្លួនដើម្បីធ្វើបដិវត្តន៍ មិនមែនសម្រាប់គ្រាន់តែធ្វើជីវទស្សន៍បដិវត្តន៍ប៉ុណ្ណោះទេ" ត្រូវមានគោលជីវភាពកសាងខ្លួនជាប្រចាំរៀងរាល់ថ្ងៃ ។ ត្រូវទុកការងារកសាងខ្លួនដូចជាបាយព្រឹកបាយល្ងាចអីចឹង ។ កសាងបែបហ្នឹង បានវាមុត ។ កុំចាំមួយឆ្នាំ ទើបមកដុតដំខ្លួន ក្នុងជីវទស្សន៍បដិវត្តន៍ម្ដង ដូចគេដុតដំកាំបិត គឺទាល់តែកាំបិតឆែបបានដុតដំ ។ ធ្វើដូច្នេះ មិនបានទេ ។ ត្រូវសំលៀងជីវភាពបដិវត្តន៍យើងរាល់ថ្ងៃទើបវាស្រួច ។ គឺដូចជាហូបបាយអីចឹង ។ ត្រូវហូបរាល់ថ្ងៃ ទើបមានកម្លាំង ។ ឯការកសាងគោលជីវភាពបដិវត្តន៍ក៏ត្រូវកសាងរាល់ថ្ងៃដែរ ទើបមានកម្លាំងបដិវត្តន៍គ្រប់គ្រាន់សម្រាប់ទប់ទល់កម្ចាត់កម្លាំងមិនបដិវត្តន៍ ។ បើខានកសាងខ្លួនមួយថ្ងៃ ធាតុមិនបដិវត្តន៍វាឡើង វាទន្ទ្រានទៅលើធាតុបដិវត្តន៍ ។ ដូច្នេះ យូរៗទៅ ធាតុបដិវត្តន៍ត្រូវចុះខ្សោយ ហើយសារភាពធាតុមិនបដិវត្តន៍ ។

បើយើងកសាងខ្លួនជាប្រចាំរាល់ថ្ងៃ សន្សំៗពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ សមមិត្តមុខតែមានកម្លាំងបដិវត្តន៍គ្រប់គ្រាន់ ដើម្បីបដិវត្តន៍ខ្លួនឯង ទៅជាយុវជន យុវនារីល្អ សមឋានៈជាយុវជន យុវនារីរបស់បក្សកុម្មុយនីស្តកម្ពុជាជាប្រាកដ។ (ទះដៃវែង) ។

កសាងខ្លួននេះ ត្រូវកសាងខ្លួនក្នុងការងារ ក្នុងចលនាតស៊ូ មិនមែនកសាងខ្លួនតាមសម្មាធិក្នុងបន្ទប់ទេ ។ បើកសាងខ្លួនដោយអង្គុយសង្រ្គមតាមសម្មាធិនោះ គឺកសាងមិនបានទេ ។

**៥) សេចក្ដីសន្និដ្ឋាន**

បក្សយើងដឹកនាំជាតិ ប្រជាជន និងយុវជន យុវនារីយើង ធ្វើបដិវត្តន៍ជាបន្តបន្ទាប់ យូរអង្វែងទៅទៀត ។ ដូច្នេះ ក្នុងឋានៈសមមិត្តជាយុវជន យុវនារីកម្ពុជា ដែលត្រូវធានាអះអាងអនាគតជាតិ ប្រជាជន និងបដិវត្តន៍ទៅអនាគត ក្នុងឋានៈសមមិត្តជាអ្នកបន្តវេនជ្រោងគ្រវីទង់បដិវត្តន៍កម្ពុជាឲ្យខ្ពស់ត្រដែតទៅអនាគត សមមិត្តត្រូវកសាងខ្លួន ឲ្យមានជីវភាពបដិវត្តន៍រឹងប៉ឹង ឲ្យឈ្នះជាដរាប គឺឈ្នះទាំងខ្មាំងជាចក្រពត្តិអាមេរិក និងពួកអាក្សត់ ឈ្នះទាំងធម្មជាតិ ឈ្នះទាំងការងារ ឈ្នះទាំងការលំបាក និងឈ្នះលើខ្លួនឯងទៀត ។

បើសមមិត្តមានធាតុប្រយុទ្ធដាច់ខាត ឈ្នះគ្រប់យ៉ាង ហ្នឹងហើយ សមមិត្តនឹងដើរតាមទាន់ដំណើរវិវត្តនៃបដិវត្តន៍ ក្រោមការដឹកនាំដ៏ឈ្លាសវៃ នៃបក្សកុម្មុយនីស្តកម្ពុជាដ៏ភ្លឺស្វាងជាប្រាកដ។

សូមជូនពរសមមិត្តទាំងអស់ មានសុខភាពល្អ ហើយមានជីវភាពប្រយុទ្ធដាច់ខាត (ទះដៃយ៉ាងវែង) ។

**ឆេង ម៉េង**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















*កាលបរិច្ឆេទបញ្ចាំង៖ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ ៖ ០០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

លោក ម៉ែន ពិចិត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរស័ព្ទលេខ ០២៣ ២១៨ ០០៩

អ៊ីម៉ែលៈ truthmpechet@dccam.org

គេហទំព័រៈ www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «គុកឥតជញ្ជាំង» ដោយទូរទស្សន៍ ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ការផ្សារសម្ងាត់នៅមន្ទីរស-២១» ដោយ ដេវីត អូកូហ្វូណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ឋាននរក៩ជាន់» ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ប្រាសាទអង្គរវត្តដែលកំបាំង» ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៈ ការស្លាប់ និង ការចាប់កំណើត» ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «អង្គការ» ដោយ Germany ក្នុងឆ្នាំ ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «សង្គ្រាមក្នុងព្រៃ» ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «រវាងសន្តិភាព និងយុត្តិធម៌ ៈ រឿងកន្ទួងហួសទៅសូមឲ្យកន្ទួងហួសទៅចុះ» ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ជីវិ២ (ជីវិជនភៀសខ្លួន) » ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត ៈ ការសម្លាប់» ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

**ខែកក្កដា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “សាក្សីកម្ពុជា” បណ្ណសាររបស់ ដេវីត ហក (David Hawk Archives) (១១១.២នាទី)

◆ ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង “សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក” ដោយ FPD ក្នុងឆ្នាំ១៩៩៨

◆ ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “ព្រះអាទិទេពចុងក្រោយ” ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)

◆ ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “តំបន់អន្ទង់វែង (តាម៉ុក)” ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៨.៥៧នាទី)

◆ ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង “កម្ពុជា ៣បូក៤ ឆ្នាំទីសូន្យ និងឆ្នាំទី១” ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)

**ខែសីហា ឆ្នាំ២០១៦**

◆ ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង “ស្រមោលអតីតកាល : រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា” ដោយ Express TV (១២០នាទី)

◆ ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ :១៥ រសៀល បញ្ចាំងរឿង “ស្រមោលរបស់ ប៉ុល ពត” ដោយ អាមេនដា ផៃក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)

◆ ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “ក្តីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត” ដោយ ធារ៉ា ដេលហ្គាដូ (Tiara Delgado) (៣៨នាទី)

◆ ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង “ទម្លាយភាពស្ងប់ស្ងាត់” ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)

**ខែកញ្ញា ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “បទសម្ភាសន៍ជាមួយ ប៉ុល ពត” ដោយ ភីធើ ហ្វ្រូបឹក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)

◆ ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “ប៉ុល ពត : ដំណើរទៅកាន់វាលពិឃាត” ដោយ ជេន ចនស្តុន (Jane Johnston) (៥០នាទី)

◆ ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “យុត្តិធម៌ដែលបានពន្យាពេល និងយុត្តិធម៌ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)” ក្នុងឆ្នាំ២០០៥ (៥៤.២៤នាទី)

◆ ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង “រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម” (៧០នាទី)

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "នៅក្រោយជញ្ជាំងមន្ទីរស-២១" ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០ នាទី)

◆ ថ្ងៃទី១៤ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដំណើរទៅកាន់វាលពិឃាត" ដោយ ជេន ចនស្តុន (Jane Jonhston) (៥០ នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដល់ពេលស្វែងរកយុត្តិធម៌" ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០ នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "មើលទៅមុខ មើលទៅក្រោយ" ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០ នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការរាំទៅរកការស្លាប់ : សត្វស្វា មន្តអាគម និងភាពវិលវល់របស់កម្ពុជា" ដោយ ចេនេត ហ្គាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧" ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "៣ឆ្នាំ ៨ខែ ២០ថ្ងៃ" ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦ នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្មេងសម្រាប់ដាក់លក់" ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣ នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "វិប្បដិសារី" ក្នុងឆ្នាំ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កងទ័ពខ្មែរក្រហម" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សេន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥ នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ពេលព្រះអាទិត្យអស្តង្គត" ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់" ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧ នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្បង់ទឹកទន្លេ" ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣ នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truththida.s@dccam.org ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthmpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អ្នកការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈដែរ ។

សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូ សវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់ សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខុក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញ ដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេ ដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។ **វ៉ាន់ថាន់ ពៅដារ៉ា**

# ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជា

## ពិធីសម្ពោធផ្ទាំងពាក្យស្លោករំឭកពីការចងចាំ និង ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និង ពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

វិទ្យាស្ថានស្លឹករឹតដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជា អចិន្ត្រៃយ៍ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនដំណឹងស្តីពីកម្មវិធីសម្ពោធពាក្យស្លោករំឭកពីការចងចាំ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ព្រមទាំងកម្មវិធីចែកសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅក្នុងបរិវេណវិទ្យាល័យ ហេង សំរិន ព្រៃល្វា ស្ថិតក្នុងភូមិព្រៃល្វាលិច ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ នៅវេលាម៉ោង៨ព្រឹក ដោយមានការចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ពីសំណាក់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងតំណាងមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ ។ កម្មវិធីនេះ គឺជាផ្នែកមួយរបស់ការអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលមានគោលបំណងផ្សារភ្ជាប់ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅកម្ពុជា ទៅនឹងចំណេះដឹងរបស់ប្រជាជននៅតាមមូលដ្ឋានពីអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ក្នុងចន្លោះ





ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩ ។ ពាក្យស្លោកទាំងពីរប្រយោគនេះ មានអត្ថន័យដូចតទៅ៖

១) និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱនអធ្យាស្រ័យគ្នា ។

២) រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

ប្រយោគទាំងពីរនេះឆ្លាក់នៅលើផ្ទាំងថ្មម៉ាប និងត្រូវបានដំឡើង បង្ហាញនៅក្នុងទីតាំងលេចធ្លោដែលអាចទាក់ទាញចំណាប់អារម្មណ៍សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងប្រជាជនមូលដ្ឋានឲ្យមកមើលបានគ្រប់ពេលវេលា ។ អត្ថន័យរបស់ពាក្យស្លោកទាំងពីរប្រយោគ គឺដើម្បីរំឭកឡើងវិញនូវអំពើឃោរឃៅនៃរបបខ្មែរក្រហម ក៏ដូចជាសារសំខាន់នៃការចងចាំ ការអប់រំ និងការកសាងសន្តិភាពនៅក្នុងសង្គមកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ពាក្យស្លោកទាំងពីប្រយោគនេះ បានជួយបណ្ដុះគំនិតសិស្សានុសិស្សឲ្យស្វែងយល់ពីធាតុពិតនៃការអត់ឱនអធ្យាស្រ័យគ្នា មិនរើសអើងគ្នា និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

ការអប់រំក្នុងរបបខ្មែរក្រហម ត្រូវបានបិទ ហើយជំនួសមកវិញនូវការឃោសនាដែលពោរពេញទៅដោយមនោគមវិជ្ជាផ្សេងៗពីលទ្ធិម៉ាក្សនិយមផង លទ្ធិកុម្មុយនីស្តចិនផង និងគំនិតផ្ទាល់ខ្លួនរបស់អ្នកដឹកនាំខ្មែរក្រហមទៅលើជាតិសាសន៍ និងជាតិនិយមផង ។ ការជាប់គាំងក្នុងវិស័យអប់រំនេះ នៅតែបន្តរហូតមកដល់ប្រទេសកម្ពុជាក្រោយពេលរំដោះឆ្នាំ១៩៧៩ភ្លាមៗ ហើយការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក៏បានជួបប្រទះការលំបាកយ៉ាងខ្លាំងដែរ ។ ប្រយោគក្នុងពាក្យស្លោកទាំងពីរនេះ គឺបង្ហាញឲ្យឃើញពីដំណោះស្រាយនៃភាពជាប់គាំងនៃវិស័យអប់រំ ព្រមទាំងបង្ហាញពីការយកចិត្តទុកដាក់លើការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។

ផ្ទាំងពាក្យស្លោកនេះ កំពុងស្ថិតក្នុងបរិវេណវិទ្យាល័យ ហេង សំរិន ព្រៃល្វា ក្រោមជំនួយឧបត្ថម្ភពីមូលនិធិ ស៊ីណូ ស៊ីនេហ្គា (Chino Cienega Foundation) តាមរយៈបុគ្គលិកមូលនិធិម្នាក់ឈ្មោះ សាលី ប៊េនសុន (Sally Benson) ។ មកដល់បច្ចុប្បន្ននេះ វិទ្យាល័យ ហេង សំរិន ព្រៃល្វា គឺជាទីតាំងទី១៩ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានដំឡើងពាក្យស្លោករំឭកពីការចងចាំ ព្រមទាំងកម្មវិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។ **ផេង ពង្សរ៉ាស៊ី**

# នួន ឆន សមមិត្តនារីកងឈ្លប

នួន ឆន បច្ចុប្បន្នមានអាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅភូមិតាកួន សង្កាត់ខ្វែង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ កាលពីតូច ឆន មិនបានចូលរៀនទេ គឺគាត់នៅមើលថែប្អូនតូចៗនៅផ្ទះ ព្រោះម្តាយមេម៉ាយ ហើយត្រូវធ្វើស្រែដើម្បីចិញ្ចឹមកូន ។ ក្រោយមក ក៏មានព្រឹត្តិការណ៍យន្តហោះមកទម្លាក់គ្រាប់បែក ប៉ុន្តែមិនត្រូវចំភូមិរបស់ ឆន រស់នៅទេ គឺត្រូវចំផ្ទះប្រជាជននៅភូមិរកាជួរ ក្នុងស្រុកសណ្តាន់ ។ បន្ទាប់ពីហេតុការណ៍នេះ ខ្មែរក្រហមបានចូលមកឃោសនាប្រជាជនក្នុងភូមិឲ្យងើបឡើងប្រឆាំងទៅនឹងការទម្លាក់ និងរបប លន់ នល់ ។ ឆន និងក្មេងៗនៅក្នុងភូមិជាច្រើននាក់ត្រូវបានខ្មែរក្រហមប្រមូលឲ្យចូលក្នុងកងកុមារ ។ មួយរយៈក្រោយមក អង្គការបានចាត់តាំង ឆន ឲ្យចូលទៅនៅក្នុងកងចល័តនារី ដែលសមាជិកសរុបទាំងអស់ប្រមាណជា៦០នាក់ ដោយមាននារី យិត ជាប្រធាន និងត្រូវបានបំបែកឲ្យរស់នៅបែកពីឪពុកម្តាយ ។ ចំណែកការងាររបស់ ឆន នៅពេលនោះ គឺលើកទំនប់ ជីកប្រឡាយ និងរែកដី ។

ឆន ធ្វើការនៅកងចល័តបានរយៈពេលប្រមាណ៦ខែ ក៏ត្រូវអង្គការផ្លាស់ឲ្យទៅធ្វើជាកងឈ្លប នៅសង្កាត់ខ្វែង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ ការងាររបស់ ឆន គឺដើរស៊ើបការណ៍ និងល្បាតពេលយប់នៅក្នុងភូមិ ក្នុងសង្កាត់ខ្វែង នៅពេលដែលអង្គការសង្ស័យថា មានគិញចូលមកបង្កចលាចល ។ បន្ទាប់មក ឆន បានយកព័ត៌មានដែលគាត់ប្រមូលទៅរាយការណ៍ជូនប្រធានឈ្លបឈ្មោះ ព្រាប ដើម្បីមានវិធានការបន្តទៀត ។ នៅពេលនោះដែរ ឆន ក៏មានភារកិច្ចចុះទៅអប់រំប្រជាជនណាដែលគាត់សង្កេតឃើញថា បាននិយាយប៉ះពាល់ដល់ចលនាបដិវត្តន៍ ហើយបើគាត់អប់រំរយៈពេលបីលើកហើយ នៅតែមិនស្តាប់ កងរបស់ ឆន និងមានវិធានការបន្ថែមទៀត ។ រហូតដល់ឆ្នាំ១៩៧៩ ដោយសារពាក្យការឃោសនាថា កងទ័ពវៀតណាមសម្លាប់ និងរំលោភ ឆន និងមីងរបស់គាត់ម្នាក់ទៀតបានរត់គេចចេញពីភូមិទៅតាមយោធាខ្មែរក្រហម ។ នៅតាមផ្លូវ ឆន បានជួបការលំបាកយ៉ាងខ្លាំង ព្រោះគាត់មិនមានអង្ករសម្រាប់ដាំបាយ និងទឹកសម្រាប់ផឹក ។ នៅពេលនោះ មានអ្នកជម្លៀសជាច្រើនបានស្លាប់ដោយសារអត់អាហារ និងទឹក ។ នៅពេលខ្វះខាតខ្លាំង ទើបកងយោធាខ្មែរក្រហមចូលទៅសុំអង្ករពីប្រជាជននៅក្នុងភូមិយកមកដាំបាយ និងចែកគ្នាហូប ។ ឆន បានដើរកាត់ព្រៃរយៈពេលប្រមាណបីខែ សំដៅទៅជួរភ្នំដងរែក ។ ពេលខ្លះ ឆន ត្រូវគោងវល្លិឡើងលើភ្នំ ចំណែកអ្នកដែលជួបការលំបាកខ្លាំងនៅខណៈនោះ គឺអ្នកជម្លៀសដែលមានកូនតូចៗនៅជាមួយដែលត្រូវបីពីមុខ និងស្ពាយពីក្រោយឡើងភ្នំ ។ ពេលយប់ ឆន ត្រូវដេកផ្ទាល់ដី ដោយគ្មានភួយដណ្តប់ ថែមទាំងមិនហ៊ានដុតភ្លើងសម្រាប់កម្តៅខ្លួន និងការពារនូវការយាយីពីសត្វសាហាវផង ព្រោះខ្លាចកងទ័ពវៀតណាមប្រទះឃើញ ។

នៅឆ្នាំ១៩៨០ ខ្មែរក្រហមបានរៀបចំកងទ័ពឡើងវិញ និងបានចាត់តាំងឲ្យ ឆន ចូលក្នុងកងនារីដឹកជញ្ជូន ។ ឆន ធ្វើការរហូតដល់ឆ្នាំ១៩៨៥ ទើបខ្មែរក្រហមបានរៀបចំឲ្យគាត់មានប្តីធ្វើជាយោធា ។ បន្ទាប់ពីរៀបការរួច ប្តីរបស់ ឆន ត្រូវចេញទៅច្បាំងនៅសមរភូមិមុខ ចំណែក ឆន ដែលមិនទាន់មានកូនត្រូវធ្វើការនៅក្នុងកងដឹកជញ្ជូនដដែល ដោយត្រូវជញ្ជូនស្បៀងអាហារ និងគ្រាប់រំសេវចេញពីឃ្លាំងនៅលើភ្នំដងរែក យកទៅផ្តល់ឲ្យយោធានៅសមរភូមិមុខ ដែលពេលនោះដឹកនាំដោយ តាសារឿន ប្រធានកងពលលេខ១២ ។

ក្រោយពីការងារដឹកជញ្ជូន ឆន ត្រូវបិទចម្រូងបន្ថែមទៀត ដើម្បីផ្តល់ទៅឲ្យអង្គភាពទ័ពយកទៅដាក់ការពារកុំឲ្យកងទ័ពវៀតណាមជ្រៀតចូលមកតំបន់ខ្លួន ។

រហូតដល់យោធាខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល នៅឆ្នាំ១៩៩៩ ទើប ឆន និងគ្រួសារចុះពីលើភ្នំមករស់នៅឃុំលំទង ស្រុកអន្លង់វែងវិញ ដោយប្រកបរបរធ្វើស្រែ និងចម្ការរហូតមកដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# បាត់ប្អូនជីដូនមួយក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ កែ ដុកឡុង បានបាត់បងប្អូនជីដូនមួយឈ្មោះ ឡូ អ៊ី ហួយ ហៅ នាវ នាវ (ស្រី) កើតនៅឆ្នាំ១៩៦៦ ក្នុងទីក្រុងភ្នំពេញ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៨-១៩៧៩ នាងមានអាយុប្រហែល ១២ ឬ១៣ឆ្នាំ ។ ឪពុករបស់នាងគឺជាបងប្រុសធំទីពីររបស់ម្ដាយខ្ញុំ ។

នៅឆ្នាំ១៩៧៨ ឪពុករបស់ នាវ ឈ្មោះ ឡូ ស៊ីវ ពីង ត្រូវខ្មែរក្រហមសម្លាប់នៅការដ្ឋានការងារមួយ ដោយសារតែគាត់បានលួចមាន់យកមកឲ្យគ្រួសារហូប ។ ចំណែកម្ដាយរបស់ នាវ ឈ្មោះ ឡូ ពី អ៊ីន បានធ្វើអត្តឃាតក្រោយពេលបានដឹងពីការស្លាប់របស់ប្ដី ។ មុននឹងធ្វើអត្តឃាត ម្ដាយរបស់ នាវ បានយក នាវ ទៅផ្ញើប្អូនស្រីរបស់គាត់ នេះបើតាមសម្ដីមិត្តភក្តិរបស់ម្ដាយ នាវ ដែលធ្លាប់រស់នៅជាមួយគ្នាប្រាប់ ។ មិត្តភក្តិម្ដាយរបស់ នាវ បានឲ្យដឹងទៀតថា ក្រោយពីការស្លាប់របស់ឪពុកម្ដាយ នាវ បានស្ពាយកាបូបមួយដែលមានមាសមួយចំនួនដែលឪពុកម្ដាយរបស់នាងបន្សល់ទុកឲ្យ ។

នៅអំឡុងឆ្នាំ១៩៧៨-៧៩ នាវ និងម្ដាយមីង ប្អូនស្រីខាងម្ដាយរបស់ (នាវ) បានចេញដំណើរទៅព្រំដែនថៃ ដោយពេលនោះម្ដាយមីងរបស់ នាវ បានយកកាបូបពី នាវ រួចហើយទុកឲ្យ នាវ រស់នៅតែម្នាក់ឯង ។

ប្រសិនបើបងប្អូនណាបានឮ ឬស្គាល់ឈ្មោះនាង សូមទាក់ទងមកខ្ញុំបាទតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។


គ្រួសារ នាវ នាវ ថតឆ្នាំ១៩៧០ ។ ជួរខាងមុខ រូបទីពីររាប់ពីឆ្វេង នាវ នាវ ។

ឪពុក នាវ កាលពីក្មេង

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី  : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

***ជំពូក៨***

***សេចក្តីសន្និដ្ឋានៈ ការកសាងឡើងវិញនូវអត្តសញ្ញាណស្នូល និងជាយ***

*សៀវភៅនេះបានព្យាយាមបកស្រាយអត្តសញ្ញាណចាម ដោយប្រើប្រាស់រូបមន្តស្នូល និងជាយ ។ អត្តសញ្ញាណស្នូលពិបាក និងប្រើប្រាស់រយៈពេលយូរសម្រាប់ប្រើប្រាស់ ។ អត្តសញ្ញាណជាយ មានអាយុកាលខ្លី និងងាយផ្លាស់ប្តូរ ហើយកំណត់រូបរាងដោយអត្តសញ្ញាណស្នូល ។ អត្តសញ្ញាណប្រភេទនេះត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌអត្តសញ្ញាណស្នូល តែអត្តសញ្ញាណទាំងពីរតែងតែប្រឆាំងនឹងគ្នា ប៉ុន្តែក៏សម្របសម្រួលជាមួយគ្នាដែរក្នុងអំឡុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្លីមួយដែរ ។ ដំណើរការនៃភាពចម្រុងចម្រាសនេះកើតឡើងក្នុងជាយដែលអត្តសញ្ញាណស្នូលមួយចំនួនមានអាទិភាព និងសារសំខាន់ជាងអត្តសញ្ញាណស្នូលដទៃទៀត ។*

*ក្នុងសម័យអន្តរកាល អត្តសញ្ញាណស្នូលមួយចំនួនពុំសូវមានសារសំខាន់ដូចអត្តសញ្ញាណស្នូលដទៃទៀតក្នុងពេលជាមួយគ្នានេះ អត្តសញ្ញាណជាយមានការផ្លាស់ប្តូរទៅវិញ ។ នៅក្នុងសៀវភៅនេះ អត្តសញ្ញាណចាមត្រូវបានបកស្រាយនៅក្នុងក្របខណ្ឌស្នូល និងជាយ ដើម្បីជៀសវាងការបញ្ចូលអត្តសញ្ញាណចាមដ៏ស្មុគស្មាញជាច្រើនឲ្យទៅជាអត្តសញ្ញាណតែមួយដែលគ្មានចលនា ប៉ុន្តែក៏ផ្លាស់ប្តូរច្រើន*



*ខ្មែរ-អ៊ិស្លាមចូលរួមស្តាប់សវនាការនៅតុលាការខ្មែរក្រហម*

ក្នុងពេលជាមួយគ្នា សណ្ឋានជាច្រើនស្របពេលជាមួយគ្នាទៅវិញ ហើយនេះដូចទៅនឹងអ្វីដែល លោក ហល (**Hall**) ថ្លែងនៅក្នុងការបង្កើតទ្រឹស្តីទាក់ទងអត្តសញ្ញាណវប្បធម៌របស់គាត់ថា "អត្តសញ្ញាណវប្បធម៌គឺជាបញ្ហាទាក់ទងនឹងការប្រែក្លាយ និងការក្លាយជាបុគ្គលម្នាក់ ។" លោក ហល ក៏យល់ឃើញថាអត្តសញ្ញាណទូទៅ មានលក្ខណៈដូចជា "ផលិតកម្មមួយដែលមិនចប់" ។ អត្តសញ្ញាណជាយចាមស្របយ៉ាងល្អទៅតាមទស្សនៈរបស់លោក ហស៍ ដែលយល់ថាអត្តសញ្ញាណគឺជាដំណើរផលិតកម្ម ។

អត្តសញ្ញាណពីរដ៏សំខាន់របស់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាមានដូចជា ពួកគេគឺជាបច្ចាញាតិនៃប្រទេសចម្ប៉ា និងជាអ្នកគោរពប្រណិប័តន៍សាសនាអ៊ីស្លាម ។ បិរបទប្រវត្តិសាស្ត្របានបង្ហាញថា ចាប់តាំងពីមានការផ្លាស់ប្តូរសាសនាទៅជាអ៊ីស្លាម ជនជាតិចាមកំណត់អត្តសញ្ញាណខ្លួនឯងជាមួយប្រទេសចម្ប៉ាដែលបានរលាយសាបសូន្យ និងសាសនាអ៊ីស្លាម ។ អត្តសញ្ញាណជាយទាក់ទងទៅនឹងកត្តាមួយចំនួនដូចជា និកាយអ៊ីស្លាម ការស្រោចស្រង់អ៊ីស្លាម និន្នាការនយោបាយ អំពើប្រល័យពូជសាសន៍ ការស្រោចស្រង់ និងការកសាងឡើងវិញនូវវប្បធម៌ សាសនា និងការអប់រំបែបវិទ្យាសាស្ត្រ (ដូចដែលបានបកស្រាយបន្ទាប់មកទៀត) ។ អត្តសញ្ញាជាយត្រូវបានបែងចែកចេញជាបីក្រុមសំខាន់ៗ មានដូចជា និកាយ នយោបាយ និងសេដ្ឋកិច្ច ។

ទស្សនៈរបស់ជនជាតិចាមគឺការចាត់ទុកខ្លួនជាពលរដ្ឋក្នុងតំបន់ និងសកល ខុសពីទស្សនៈរបស់ប្រជាជនខ្មែរជាច្រើន ដែលយល់ថាខ្លួនមានទំនាក់ទំនងទីតាំងភូមិសាស្ត្រជាមួយប្រទេសកម្ពុជា ។ ដោយសារតែខ្លួនជាអ្នកគោរពប្រណិប័តន៍សាសនាអ៊ីស្លាម និងជាជនអន្តោប្រវេសន៍ជនជាតិចាម ចាត់ទុកខ្លួនឯងមិនគ្រាន់តែជាប្រជាជនកម្ពុជា (ឬខ្មែរដែលជាពាក្យសំដៅទៅប្រជាជនខ្មែរទូទៅ) ប៉ុន្តែក៏ជាសមាជិកនៃសហគមន៍អ៊ីស្លាមនៅទូទាំងពិភពលោកដែរ ។

### ១) អត្តសញ្ញាណសាសនា

នៅក្នុងសៀវភៅនេះ ជនជាតិចាមមានអត្តសញ្ញាណស្នូលពីរ គឺអត្តសញ្ញាណសាសនា និងអត្តសញ្ញាណជាតិពន្ធុ ។ អត្តសញ្ញាណស្នូលទាំងពីរបានផ្តាច់ពួកគេចេញពីក្រុមជនជាតិដើមភាគតិច នៅកម្ពុជាជាពិសេសគឺជនជាតិខ្មែរ ។ ដោយហេតុតែជនជាតិខ្មែរមានប្រជាជនច្រើនជាងគេ អត្តសញ្ញាណស្នូលទាំងពីររបស់ជនជាតិចាមត្រូវបានប្រៀបធៀបជាមួយនឹងសាសនា និងអត្តសញ្ញាណជាតិពន្ធុរបស់ជនជាតិខ្មែរ ។ អត្តសញ្ញាណសាសនារបស់ជនជាតិចាមគឺអ៊ីស្លាម ខណៈពេលអត្តសញ្ញាណជាតិពន្ធុគឺ ចាម ដែលជាបច្ចាញាតិរបស់នគរសាបសូន្យចម្ប៉ា ។

សៀវភៅនេះក៏បានអះអាងថា ខុសប្លែកពីទស្សនៈបែបពិភាក្សាដែលកំណត់ថាអត្តសញ្ញាណជាដំណើរការមួយកំពុងតែបន្តជាជាងអ្វីតែងតែនៅស្ថិតថេរមិនផ្លាស់ប្តូរអត្តសញ្ញាណចាមមានអត្តសញ្ញាណស្នូល និងអត្តសញ្ញាណជាយ ។ នៅពេលដែលអត្តសញ្ញាណជាយចាមចំណាយពេលច្រើនទសវត្សរ៍សម្រាប់ប្តូរអត្តសញ្ញាណស្នូលវិញ ត្រូវការរយៈពេលដល់ទៅច្រើនសតវត្សឯណោះ ។ សៀវភៅនេះយល់ស្របទៅតាមទស្សនៈដែលយល់ឃើញថាអត្តសញ្ញាណអ៊ីស្លាមគឺជាកត្តាមួយក្នុងការកំណត់ព្រំប្រទល់ខណ្ឌចែករវាងជនជាតិចាម និងខ្មែរ ។ ទោះបីជាជនជាតិចាមគោរពនិកាយផ្សេងៗពីគ្នានៅក្នុងសាសនាអ៊ីស្លាមក៏ដោយពួកគេនៅតែជាមូស្លីម ។ អត្តសញ្ញាណអ៊ីស្លាមខុសគ្នាពីអត្តសញ្ញាណនិកាយ (ដូចដែលបានបង្ហាញបន្ទាប់មកទៀត) ពីព្រោះអត្តសញ្ញាណទាំងពីរត្រូវបានយកមកប្រៀបធៀបជាមួយអត្តសញ្ញាណព្រះពុទ្ធសាសនាដែលគោរពប្រណិប័តន៍ដោយជនជាតិខ្មែរភាគច្រើន ។ នេះគឺជាព្រំដែនខណ្ឌចែករវាងជនជាតិទាំងពីរដែលមិនអាចកែប្រែបាន ទោះបីជាមានការផ្លាស់ប្តូរនៅក្នុងសាសនាអ៊ីស្លាមក៏ដោយ ។ អត្តសញ្ញាណនិកាយកើតមានឡើងដោយសារតែមានការបែកចែកនិកាយនៅក្នុងសាសនាអ៊ីស្លាម អ្នកគោរពប្រតិបត្តិនិកាយផ្សេងៗគ្នានេះមានអត្តសញ្ញាណអនុសាសន៍អ៊ីស្លាមផ្ទាល់ខ្លួន ។ អត្តសញ្ញាណអនុសាសនាអ៊ីស្លាមទាំងអស់នេះត្រូវបាន ចាត់ទុកជាអត្តសញ្ញាណជាយ ដែលកំពុងតែផ្លាស់ប្តូរជាពិសេសក្នុងសតវត្សនេះ ។

ជនជាតិចាមបានទទួលយកអត្តសញ្ញាណសាសនាអ៊ីស្លាម ចាប់តាំងពីមានការប្តូរសាសនាពីហិណ្ឌូទៅអ៊ីស្លាម នៅក្នុងដំណាក់កាលដំបូងនៃការភៀសខ្លួនរបស់ពួកគេមកកាន់ប្រទេសកម្ពុជា ក្នុងសតវត្សទី១៥ ។ សាសនាអ៊ីស្លាមបានបំបែកជនជាតិចាមចេញពីខ្មែរក្នុងទម្រង់មួយយ៉ាងច្បាស់លាស់ ។ ភាពខុសប្លែកគ្នាយ៉ាងខ្លាំងនេះបណ្តាលឲ្យការផ្សារភ្ជាប់គ្នារវាងជនជាតិចាម និងជនជាតិខ្មែរ កម្រ

នឹងកើតមានឡើង ។ ការរៀបការឆ្លងសាសន៍គឺជាវិធីតែមួយគត់ដែលអាចមានការផ្លាស់ប្តូររវាងជាតិសាសន៍ទាំងពីរបាន ។ ជនជាតិចាមសំយ៉ាំងទៅដល់ព្រះតែមួយគត់របស់ពួកគេគឺព្រះអល់ឡោះ និងជឿលើសាររបស់ព្រះអល់ឡោះ ដែលបានបកស្រាយដោយមូហាម៉ាត ប៉ុន្តែជនជាតិខ្មែរគោរពប្រតិបត្តិតាមការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធដែលបានត្រាស់ដឹងតាមរយៈការធ្វើសម្មាធិ ការបង្អត់អាហារ និងការហូបបួស ។ នៅក្នុងព្រះពុទ្ធសាសនា ពុទ្ធសាសនិកតម្រូវឲ្យយល់សេចក្តីនៅក្នុងត្រៃបិដកអំពីការចូលនិពាន្ត និងសង្គមមនុស្ស ។ មូស្លីមគោរពប្រណិប័តន៍យ៉ាងខ្ជាប់ខ្ជួនតាមពាក្យទូន្មានរបស់ព្រះអល់ឡោះ ដែលផ្សាយបន្តតាមរយៈ ទេពីហ្គេប្រឹល ទៅកាន់មូហាម៉ាត់ ។ គោលបំណងសំខាន់ក្នុងព្រះពុទ្ធសាសនាគឺការឈានទៅដល់ការត្រាស់ដឹង ក៏ប៉ុន្តែ សាសនាអ៊ីស្លាមសង្កត់ធ្ងន់លើការសូត្រធម៌ និងចងចាំថានរណាជាព្រះច្រើនជាងនៅក្នុងព្រះពុទ្ធសាសនា ។ ពុទ្ធសាសនិកយល់ថាការគោរពយ៉ាងខ្ជាប់ខ្ជួនទៅលើព្រះតែមួយអង្គដូចមូស្លីមបែបនេះមានលក្ខណៈចំឡែក ។ ពួកគេមិនត្រឹមតែអាចគោរពប្រណិប័តន៍ទៅតាមការទូន្មានរបស់ព្រះពុទ្ធនោះទេ ពួកគេក៏អាចជឿលើអ្នកតា និងព្រះដទៃទៀតបានដែរ ។ ពុទ្ធសាសនិកមិនចាំបាច់ចាំថានរណាជាព្រះពុទ្ធ ឬអវតារទាំងអស់របស់ព្រះពុទ្ធនោះទេ ។ ពុទ្ធសាសនិកបើកចំហក្នុងការទទួលយកជំនឿចម្រុះសាសនាជាងជនជាតិចាម ដែលកំពុងតែបន្សុទ្ធ និងលុបបំបាត់ចោលដានជំនឿចម្រុះសាសនាទាំងអស់ពីការប្រណិប័តន៍របស់ខ្លួន ។

ជនជាតិខ្មែរទៅវត្ត ចំណែកឯជនជាតិចាមទៅវិហារ ។ ខណៈពេលខ្មែរបន់ស្រន់រូបចម្លាក់ព្រះពុទ្ធ និងព្រះអាទិទេពដទៃទៀត ដោយមិនខ្វល់ខ្វាយពីទិសតំបន់ក្នុងការបួងសួង ជនជាតិចាមសំយ៉ាំងបែរទៅទិសនៃទីក្រុងម៉ាកាស ។ ក្នុងទីវត្តអារាមខ្មែរពោរពេញទៅដោយរូបសំណាក គំនូរ និងរូបចម្លាក់ដ៏ប្រណិត ប៉ុន្តែវិហាររបស់ជនជាតិចាមពុំមានការតុបតែងលំអបែបនោះឡើយ ។ ទីវត្តអារាមគឺជាទីកន្លែងដែលសម្បូរទៅដោយរូបសំណាក និងសិល្បៈ ចំណែកឯព្រះវិហារចាម ជាទីកន្លែងនិមិត្តរូបសម្រាប់មូស្លីមប្រមូលផ្តុំគ្នាគោរពសំយ៉ាំងរួមគ្នា ។ ជនជាតិខ្មែរមួយចំនួនតូចប៉ុណ្ណោះដែលដឹងពីមូលហេតុសាសនាអ៊ីស្លាមត្រូវអនុវត្តដូច្នេះ ។

វាជារឿងមួយគួរឲ្យចាប់អារម្មណ៍ ដែលជនជាតិខ្មែរមានលក្ខណៈបើកចំហចំពោះការគោរពសាសនាដទៃទៀត ដូចជាសាសនាហិណ្ឌូ និងវិញ្ញាណនិយម ប៉ុន្តែមិនមែនសាសនាអ៊ីស្លាមនោះទេ ។ ពេលខ្លះ ជនជាតិខ្មែរគិតថាសាសនាអ៊ីស្លាមគឺជាសាសនាពិបាកយល់ និងចាត់ទុកជនជាតិចាមជាក្រុមសម្ងាត់មួយដែលពួកគេពិបាកយល់ និងខ្លាចការធ្វើអំពើធ្មប់របស់ក្រុមជាតិសាសន៍មួយនេះ ប៉ុន្តែការខ្លាចនេះមិនមានភស្តុតាងច្បាស់លាស់នោះទេ ។

ព្រះពុទ្ធសាសនាអនុញ្ញាតឲ្យមានការរៀបការឆ្លងសាសន៍និងការប្តូរសាសនា ប៉ុន្តែសាសនាអ៊ីស្លាមអនុញ្ញាតឲ្យមានការរៀបការឆ្លងសាសន៍លុះត្រាតែអ្នកដែលមិនមែនមូស្លីមប្តូរសាសនាជាអ៊ីស្លាម ។ នេះជាមូលហេតុនៃការមិនពេញចិត្តមួយពីសំណាក់ពុទ្ធសាសនិកមួយចំនួន ដោយយល់ថាទង្វើបែបនេះអយុត្តិធម៌សម្រាប់ក្រុមជាតិពន្ធុខ្មែរ រួមទាំងមានការភ័យខ្លាចពីការគ្រួតត្រាសាសនាអ៊ីស្លាមមកលើប្រទេសកម្ពុជានាថ្ងៃខាងមុខ ។

ជនជាតិចាមមានការភ្ជាប់ទំនាក់ទំនងជាមួយបរទេសនៅប្រទេស ដែលខ្មែរមិនសូវមានទំនាក់ទំនង ។ ជនជាតិចាមពឹងពាក់មូស្លីមម៉ាឡេស៊ីក្នុងសម័យខ្មែរក្រហម ។ បន្ទាប់មកទៀត ពួកគេរកជំនួយពីអង្គការនៃបណ្តាប្រទេសអ៊ីស្លាមនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ។ ពួកគេទទួលបានជំនួញពីបណ្តាប្រទេសឈូងសមុទ្រអារ៉ាប់សម្រាប់ការស្រោចស្រង់សាសនា ការសិក្សា និងការអភិវឌ្ឍសហគមន៍ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ និងពេលបច្ចុប្បន្ន ។ សូម្បីតែនៅដើមពាក់កណ្តាលទសវត្សទី២០ ជនជាតិចាមតែងតែរកជំនួយពីប្រទេសមូស្លីមទាំងនេះ សម្រាប់ការសិក្សា និងការអភិវឌ្ឍសង្គម ។ ប៉ុន្តែជនជាតិខ្មែរកម្រទាក់ទង ឬអំពាវនាវសុំជំនួញពីប្រទេសទាំងអស់នោះ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈចាំបាច់យ៉ាងណាក៏ដោយ ។

ការធ្វើធម្មយាត្រាទៅទីក្រុងម៉ាកាសប្រចាំឆ្នាំ គឺជាទំនៀមទម្លាប់តឹងរ៉ឹងរបស់សាសនាអ៊ីស្លាម ដែលបណ្តាលឲ្យមានគន្លាតរវាងខ្មែរ និងចាម ។ ជនជាតិចាមត្រូវធ្វើធម្មយាត្រាទៅកាន់ទីកន្លែងកំណើតរបស់សាសនាអ៊ីស្លាមទីក្រុងម៉ាកាសក្នុងប្រទេសអារ៉ាប៊ីសាអូឌីដ ។ ជនជាតិខ្មែរដឹងថាទីកន្លែងកំណើតនៃសាសនារបស់ខ្លួនស្ថិតនៅក្នុងប្រទេសនេប៉ាល់ ដែលធ្លាប់ជាតំបន់គ្រួតត្រាដោយប្រទេសឥណ្ឌា ប៉ុន្តែពុទ្ធសាសនិកពុំមានកាតព្វកិច្ចរៀបចំពិធីសាសនានៅក្នុងប្រទេសនេប៉ាល ឬប្រទេសឥណ្ឌា ដែលជាទីកន្លែងពួកគេទទួលបាន

ការសិក្សាខាងផ្នែកសាសនា និងសង្គម ។ នាពេលបច្ចុប្បន្ន ពុទ្ធសាសនិក ដែលមានទ្រព្យស្តុកស្តម្ភមួយចំនួន បានកសាងវត្តអារាមនៅក្នុងប្រទេសឥណ្ឌា តែការសាងសង់នេះមិនមែនជាកាតព្វកិច្ចនោះទេ ។

ជនជាតិខ្មែរជាពុទ្ធសាសនិកបានកម្ចីពាក្យពីភាសាបាលី និងសំស្ក្រឹត ដែលជាភាសាដើមនៃគម្ពីរព្រះពុទ្ធសាសនា នៅពេលដែលជនជាតិចាមប្រើភាសាចាម និងអារ៉ាបក្នុងគម្ពីរសាសនា និងការប្រាស្រ័យទាក់ទងគ្នារបស់ពួកគេ ។ មុនពេលកម្មវិធី ខេមរភាវូបនីយកម្មរបស់សម្តេចព្រះសីហនុ ចាប់ផ្តើមជនជាតិចាមយ៉ាងច្រើនពុំសូវនិយាយភាសាខ្មែរនេះ តែកម្មវិធីមួយនេះត្រូវបានរិះគន់ពីសំណាក់ថ្នាក់ដឹកនាំចាមយ៉ាងខ្លាំង ។ បន្ទាប់ពីកម្មវិធីនេះមក ជនជាតិចាមនិយាយភាសាខ្មែរច្រើនជាងមុន លើកលែងតែចាមរស់នៅតាមជនបទ និងសហគមន៍ដាច់ស្រយាល ដែលនៅទីនោះ ស្ត្រី និងក្មេងៗចាមនិយាយភាសាខ្មែរបានតិចតួចប៉ុណ្ណោះ ។ រាល់ពេលជនជាតិចាមសំយ៉ាំងជាភាសាអារ៉ាប ជនជាតិខ្មែរតែងតែនិយាយថាពួកកំពុងតែ“លូ” ។ របៀបបន្លឺសំឡេងក្នុងការធ្វើសំយ៉ាំងមានលក្ខណៈស្រទន់ និងព្រឺព្រួចសម្រាប់ជនជាតិខ្មែរជាអ្នកស្តាប់ ។

សរុបសេចក្តីមក ក្នុងចំណោមក្រុមជនជាតិភាគតិចទាំងអស់នៅក្នុងប្រទេសកម្ពុជា ជនជាតិចាម គឺជាជនជាតិមួយដែលមានសាសនាខុសប្លែកខ្លាំងពីជនជាតិខ្មែរ ។ វាគឺជារឿងមួយចម្លែកដែលក្រុមជនជាតិទាំងពីរអាចរស់នៅជាមួយអស់រយៈពេលជាច្រើនរយឆ្នាំដោយគ្មានជម្លោះសាសនាធ្ងន់ ទោះបីជាជនជាតិចាមខុសប្លែកយ៉ាងខ្លាំងពីខ្មែរ ។ អត្តសញ្ញាណសាសនារបស់ជនជាតិចាមមានលក្ខណៈខ្លាំង រឹងមាំ ទោះបីជាខ្មែរក្រហមប៉ុនប៉ងលុបបំបាត់សាសនាអ៊ីស្លាម ដោយហាមឃាត់មិនឲ្យសំយ៉ាំង កម្ទេចវិហារ ដុតគម្ពីរគួរអាន និងឯកសារសាសនា សម្លាប់អ្នកដឹកនាំសាសនា រួមទាំងអ្នកកាន់សាសនាមូស្លីមក៏ដោយ ជនជាតិចាមនៅតែគោរពប្រណិប័តន៍សាសនាអ៊ីស្លាម បន្ទាប់ពីអំពើប្រល័យពូជសាសន៍បានបញ្ចប់ ។ ពុំមានការប្តូរសាសនាណាកើតឡើងទៀតក្រោយពីសម័យខ្មែរក្រហមទេ ហើយចំនួនប្រជាជនចាមក៏កើនឡើងជាបណ្តើរៗ ចាប់តាំងពីសម័យខ្មែរក្រហមដែរ ។

## ២) អត្តសញ្ញាណជាតិពន្ធុ

អត្តសញ្ញាណស្នូលពីរផ្សេងទៀតរបស់ជនជាតិចាម គឺពួកគេជាបច្ចាជនរបស់អាណាចក្រចម្ប៉ា និងនិយាយភាសាចាម ។ លក្ខណៈសម្បត្តិទាំងពីរនេះបានផ្តាច់ជនជាតិចាមចេញពីជនជាតិខ្មែរ និងក្រុមជាតិពន្ធុដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។ អត្តសញ្ញាណជាតិពន្ធុរបស់ចាមមានដើមកំណើតនៅក្នុងអតីតនគរចម្ប៉ា និងការផ្លាស់លំនៅជាលើកដំបូងរបស់ជនជាតិចាមមកកាន់ប្រទេសកម្ពុជានៅចុងសតវត្សទី១៥ ។ អត្តសញ្ញាណនេះបានបង្ហាញកាន់តែច្បាស់តាមរយៈរូបចម្លាក់ និងអក្សរចារឹកនៅតាមជញ្ជាំងប្រាសាទបាយ័ន ពីការលួចប្លន់ និងបំផ្លិចបំផ្លាញទីក្រុងអង្គរពីសំណាក់ជនជាតិចាមក្នុងឆ្នាំ១១៧៧ ។ អត្តសញ្ញាណជាតិពន្ធុរបស់ជនជាតិចាមត្រូវបានកំណត់ដោយប្រវត្តិសាស្ត្ររបស់ពួកគេ ហើយអត្តសញ្ញាណជាតិពន្ធុបានផ្តាច់ជនជាតិចាមចេញពីជនជាតិខ្មែរ និងក្រុមជាតិពន្ធុដទៃទៀត ។ ដោយសារតែប្រទេសចម្ប៉ាធ្លាប់មានទំនាក់ទំនងជាមួយអាណាចក្រខ្មែរ អត្តសញ្ញាណជាតិពន្ធុ នៅតែជាអត្តសញ្ញាណស្នូលដ៏រឹងមាំមួយនាពេលបច្ចុប្បន្ន ។

ជនជាតិភាគតិចចាមតែងតែត្រូវបានចាត់ទុកជាបច្ចាជននៃអតីតនគរចម្ប៉ា ដែលសព្វថ្ងៃជាតំបន់វៀតណាមកណ្តាល ។ នាពេលបច្ចុប្បន្នបច្ចាជនទាំងអស់នេះរស់នៅពាសពេញឥណ្ឌូចិន ភាគច្រើននៅក្នុងប្រទេសកម្ពុជា ។ ខណៈដែលជនជាតិចាមត្រូវបានគេជឿជាក់ថាជាញាតិសន្តាននឹងក្រុមជនជាតិម៉ាឡាយូប៉ូលីនេស៊ី ជនជាតិខ្មែរជាក្រុមជនជាតិដើមអម្បូរអូស្ត្រូនេស៊ី ។ ភាសាចាមមានលក្ខណៈប្រហាក់ប្រហែលទៅ និងភាសាម៉ាឡេជ្វា និងក្រុមជនជាតិដទៃទៀតនៅប្រជុំកោះអាស៊ីអាគ្នេយ៍ (ក្រុមអម្បូរអូស្ត្រូនេស៊ី) ។ ភាសាខ្មែរមានប្រភពចេញពីក្រុមអម្បូរអូស្ត្រូនេស៊ី និងត្រូវបាននិយាយដោយក្រុមជនជាតិជាច្រើន នៅអាស៊ីអាគ្នេយ៍ដីគោក ។

ជនជាតិចាម និងខ្មែរចាប់កំណើតនៅតំបន់ឧបទ្វីបឥណ្ឌូចិនដូចគ្នា ដូច្នេះក្រុមជនជាតិទាំងពីរទទួលឥទ្ធិពលពីវប្បធម៌ និងសាសនាឥណ្ឌា ។ សព្វថ្ងៃនេះ មានប្រាសាទហិណ្ឌូយ៉ាងច្រើននៅពាសពេញភូមិភាគកណ្តាល និងភាគខាងត្បូងប្រទេសវៀតណាមដែលប្រាសាទទាំងអស់នេះបានកសាងដោយស្តេចចាមដើម្បីគោរពប្រណិប័តន៍សាសនាហិណ្ឌូ ។ ខណៈពេលជាមួយគ្នា ជនជាតិខ្មែរក៏គោរពប្រណិប័តន៍សាសនាហិណ្ឌូ និងបានកសាងប្រាសាទធំៗដើម្បីឧទ្ទិសទៅដល់ព្រះហិណ្ឌូ ។ គ្រាដែលជនជាតិខ្មែរនៅតែបន្តគោរពប្រណិប័តន៍

សាសនាហិណ្ឌូ ជនជាតិចាមបាត់បង់ទឹកដីរបស់ខ្លួនទៅប្រទេសវៀតណាម រួមទាំងវប្បធម៌របស់ខ្លួន បន្ទាប់ពីពួកគេភៀសខ្លួនមករស់នៅក្នុងប្រទេសកម្ពុជា ។ ក្នុងស្ថានភាពដ៏ទន់ខ្សោយនេះ ជនជាតិចាមបានផ្លាស់ប្តូរអត្តសញ្ញាណសាសនាពីហិណ្ឌូទៅអ៊ីស្លាម ។ ជាលទ្ធផល សាសនាអ៊ីស្លាមបានបង្កើតរបាំងការពារជនជាតិចាមមិនឲ្យរួមបញ្ចូលជាមួយក្រុមជនជាតិខ្មែរ ហេតុដូច្នេះ អត្តសញ្ញាណជាតិពន្ធុរបស់ជនជាតិចាមត្រូវបានការពារ ។

សម្រាប់ទីតាំងភូមិសាស្ត្រ ក្រុមជនជាតិភាគតិចចាមជាញឹកញាប់រស់នៅក្នុងតំបន់ផ្សេងពីខ្មែរ ។ ជនជាតិចាមភាគច្រើនរស់នៅតាមដងទន្លេមេគង្គ និងនៅជុំវិញបឹងទន្លេសាប ប៉ុន្តែជនជាតិខ្មែររស់នៅតំបន់ទំនាបកណ្តាល ។ មុខរបររវាងជនជាតិទាំងពីរក៏ខុសគ្នាដែរ ភាគច្រើនប្រជាជនខ្មែរធ្វើស្រែ នៅពេលដែលជនជាតិចាមនេសាទ ធ្វើកសិកម្មរយៈពេលខ្លីនៅតាមច្រាំងទន្លេ លក់សាច់គោ និងផលិតផលសាច់គោផ្សេងៗ ។ ភាពខុសគ្នាខាងផ្នែកមុខរបរ និងទីតាំងភូមិសាស្ត្របានបណ្តាលឲ្យជនជាតិចាមក្លាយជាក្រុមជាតិពន្ធុដាច់ដោយឡែកពីគេ ។

ក្រុមចាមមួយក្រុម ដែលមានឈ្មោះថាក្រុមអ៊ីម៉ាមសាន់បានចាត់ទុកខ្លួនឯងជាអ្នកការពារ និងថែរក្សាអត្តសញ្ញាណជាតិពន្ធុចាម ។ ក្រុមចាមមួយនេះគោរពប្រតិបត្តិនិកាយមួយនៅក្នុងសាសនាអ៊ីស្លាម ដែលផ្តោតសំខាន់លើជំនឿចំរុះសាសនា និងការប្រណិប័តន៍វប្បធម៌ចម្រុះ ។ ក្រុមមួយនេះ ក៏ព្យាយាមថែរក្សាភាសា និងប្រវត្តិសាស្ត្រចាមឲ្យបានគង់វង្ស ។ ពួកគេព្យាយាមថែរក្សាភាសាចាមតាមរយៈគម្រោងបង្កើតវចនានុក្រមភាសាចាម និងចងក្រងរាល់ភ័ស្តុតាងនៃប្រវត្តិសាស្ត្ររបស់ប្រទេសចម្ប៉ា ។ ការប្រណិប័តន៍សាសនាអ៊ីស្លាមរបស់ក្រុមមួយនេះមានភាពខុសគ្នាពីជនជាតិចាមដទៃទៀត និងចំណុចដែលគួរឲ្យកត់សម្គាល់នោះគឺការសំយ៉ាំងតែម្តងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។

ភាសាចាម គឺជាការចង្អុលបង្ហាញភាពរឹងមាំនៃអត្តសញ្ញាណជាតិពន្ធុចាម ។ នេះគឺជាភាសាមួយដែលដាស់តឿនទាំងជនជាតិខ្មែរ និងចាមពីប្រភពដើមនៃប្រជាជនចាមនៅក្នុងប្រទេសចម្ប៉ាដែលជាអាណាចក្រមួយដាច់ដោយឡែកពីប្រទេសកម្ពុជា ដែលមានកងទ័ព និងវប្បធម៌រីកចម្រើន ។ បច្ចុប្បន្ន ជនជាតិចាមនៅតែនិយាយភាសារបស់ពួកគេដែលជាមធ្យោបាយមួយយ៉ាងល្អក្នុងការថែរក្សាអត្តសញ្ញាណជាតិពន្ធុ ។ ប៉ុន្តែការប្រើប្រាស់ភាសាចាមនៅក្នុងប្រទេសកម្ពុជាមិនបាននាំមកនូវឱកាសការងារសម្រាប់យុវវ័យចាម ឬអត្ថប្រយោជន៍សេដ្ឋកិច្ចដល់សហគមន៍ចាមជាទូទៅ ។ យោងទៅតាមបទសម្ភាសន៍របស់អ្នកនិពន្ធជាមួយនិស្សិតចាមបរិញ្ញាបត្រ ភាសាចម្បងរបស់ពួកគេនៅកន្លែងការងារ គឺភាសាអង់គ្លេស និងភាសាអារ៉ាប់ ។ ភាសាអង់គ្លេសជួយឲ្យពួកគេរកបានការងារនៅក្នុងទីផ្សារសេរី និងមានឱកាសប្រកួតប្រជែងជាមួយនិស្សិតខ្មែរ ។ ភាសាអារ៉ាប់អនុញ្ញាតឲ្យពួកគេរកបានការងារនៅបណ្តាប្រទេសឈូងសមុទ្រ ក៏ដូចជាអង្គការអារ៉ាប់ជាច្រើនទៀត ។ យុវវ័យចាមជំនាន់ក្រោយនិយាយភាសាចាមនៅតែក្នុងសហគមន៍របស់ពួកគេប៉ុណ្ណោះ ដើម្បីថែរក្សាអត្តសញ្ញាណជាតិពន្ធុ និងពូជពង្សរបស់ពួកគេ ។

ប្រជាជនខ្មែរជាច្រើនចងចាំថា ជនជាតិចាមជាមនុស្សមួយក្រុម ដែលធ្លាប់ឈ្លានពានអាណាចក្រខ្មែរ ។ ការចងចាំបែបនេះ បានផ្តាច់ជនជាតិចាមចេញពីជនជាតិខ្មែរ ។ ជនជាតិខ្មែរតែងតែភ្ជាប់ខ្លួនឯងទៅនឹងភាពរុងរឿងរបស់ចក្រភពអង្គរ ក្នុងនាមជាអ្នកដែលបានកសាងប្រាសាទប្រសើរក្រៃលែងជាច្រើន និងធ្លាប់មានអំណាចខ្លាំងក្លា ដែលមានគ្រាមួយអាណាចក្រខ្មែរបានលាតសន្ធឹងដល់ភាគខាងត្បូងប្រទេសថៃ ។ យោងទៅតាមការចងចាំប្រវត្តិសាស្ត្រជារួម ជនជាតិចាមបានឈ្លានពានអង្គរនៅក្នុងឆ្នាំ១១៧៧ និងត្រួតត្រាទីក្រុងអង្គរនេះអស់រយៈពេលពីរទៅបីឆ្នាំ ។ ភាពជោគជ័យរបស់ជនជាតិចាមកើតឡើងមុនការឈ្លានពានរបស់ថៃ និងមុនពេលនៃការធ្លាក់ចុះបន្តិចម្តងៗរបស់ទីក្រុងអង្គរ ។ ការវាយឈ្លានពាននេះត្រូវបានឆ្លាក់នៅតាមជញ្ជាំងប្រាសាទបាយ័ន ដែលបន្សល់ជាភ័ស្តុតាងច្បាស់លាស់មួយក្នុងការខណ្ឌចែកជនជាតិចាមពីជនជាតិខ្មែរ ។

កត្តាមួយទៀត ដែលនៅក្នុងសតិសម្បជញ្ញៈជាតិពន្ធុរបស់ជនជាតិចាម គឺទេពកោសល្យក្នុងការធ្វើសឹកសង្គ្រាមរបស់ពួកគេ ។ ដូចគ្នាទៅនឹងប្រជាជនខ្មែរគោរពស្រលាញ់ព្រះបាទជ័យវរ្ម័នទី៧ជាវីរៈស្តេចរបស់ពួកគេ ជនជាតិចាមគោរពស្រលាញ់ស្តេចវីរៈបុរស ឆេ បុង ង៉ា ដែលបានបំភិតបំភ័យវៀតណាមអស់កាល៣០ឆ្នាំ ចាប់តាំងពីការឡើងគ្រងរាជ្យរបស់ព្រះអង្គរហូតដល់សោយទិវង្គតក្នុងឆ្នាំ១៣៩០ ។ ឆេ បុង ង៉ា ជាស្តេច និងមេទ័ពដែលមានជំនាញយ៉ាង

ប៉ិនប្រសប់ខាងផ្នែកយុទ្ធសាស្ត្រ និងមានគុណសម្បត្តិជាអ្នកដឹកនាំ ។ ទោះបីជាមានកងទ័ពតិចក៏ដោយ រេ បុង ង៉ា អាចយកឈ្នះកងទ័ពវៀតណាមជាច្រើនលើកជាច្រើនសា ។ ប្រសិនបើគ្មានការដឹកនាំប្រកបដោយទសពិធរាជធម៌របស់ព្រះអង្គនោះទេ ប្រទេសចម្ប៉ាប្រាកដជាចុះអន់ថយយ៉ាងលឿននៅក្រោយកណ្ដាប់ដៃរបស់ជនជាតិវៀតណាម ។ ជនជាតិចាមមានទេពកោសល្យអស្ចារ្យក្នុងការធ្វើសឹកសង្គ្រាម ។ ការឈ្លានពានទីក្រុងអង្គរតាមទន្លេពិតជាទទួលបានជោគជ័យយ៉ាងខ្លាំងខាងផ្នែកយោធា ។ លើសពីនេះ កងទ័ពសៀមបានប្រើប្រាស់ប្រជាជនចាមជាទ័ពជំនួយ ។ រង្វាន់សម្រាប់ភាពក្លាហាន និងជំនាញយោធារបស់ពួកគេ គឺការទទួលបានដីមួយចំណែកនៅទីក្រុងបាងកក ។ សព្វថ្ងៃសហគមន៍នេះមានឈ្មោះថា «បានគ្រួ» *(Ban Krua)* ។ នៅប្រទេសកម្ពុជា ជនជាតិចាមបានប្រើប្រាស់សមត្ថភាពរបស់ពួកគេក្នុងការផ្ដល់ជំនួយយុទ្ធសាស្ត្រពេលមានសង្គ្រាម ដើម្បីបញ្ចុះបញ្ចូលស្ដេចខ្មែរអនុញ្ញាតឲ្យពួកគេរស់នៅក្នុងប្រទេសខ្មែរ ។ ការឡើងគ្រងរាជ្យរបស់ស្ដេចរាមាធិបតីទី២ ក៏បានទទួលការជ្រោមជ្រែងដោយជនជាតិចាម ដែលបានកម្ចាត់សត្រូវ និងដណ្ដើមអំណាចរាជបល្ល័ង្កជូនព្រះអង្គ ។

## ទំនាក់ទំនងរវាងអត្តសញ្ញាណស្នូលទាំងពីរ

អត្តសញ្ញាណជាតិពន្ធុរបស់ជនជាតិចាមមានលក្ខណៈរឹងមាំស្ទើរតែការប៉ុនប៉ងរបស់ខ្មែរក្រហម ក្នុងការកម្ចាត់ជនជាតិចាមដោយសម្លាប់យ៉ាងរង្គាល បំបែកឲ្យរស់នៅបញ្ចូលជនជាតិចាមជាមួយក្រុមជាតិសាសន៍ដទៃទៀត និងហាមឃាត់មិនឲ្យនិយាយភាសាចាម ការខិតខំប្រឹងប្រែងទាំងនេះ មិនទទួលបានជោគជ័យនោះទេ ។ អំពើប្រល័យពូជសាសន៍នេះមានផលប៉ះពាល់ទៅលើអត្តសញ្ញាណជាយរបស់ចាមជាង អត្តសញ្ញាណស្នូល ។ អ៊ីសា ឧស្មាន់ បានរកឃើញថា បន្ទាប់ពីរបបខ្មែរក្រហមចំនួនយុវជនចាមដែលអាចនិយាយភាសាចាមមានចំនួនតិចជាងមុន ។ ដោយសារតែបញ្ញវន្តចាមជាច្រើនស្លាប់ក្នុងរបបខ្មែរក្រហម អត្តសញ្ញាណនិកាយរបស់ពួកគេត្រូវបានកសាងឡើងវិញ បន្ទាប់ពីរបបនេះរលំ ។

អត្តសញ្ញាណស្នូលទាំងពីរបានបំបែកជនជាតិចាមចេញពីក្រុមជាតិពន្ធុផ្សេងទៀត ដូចជា ជនជាតិខ្មែរដែលមានចំនួនប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ។ អត្តសញ្ញាណសាសនាបង្កើតនូវព្រំដែនខណ្ឌចែកជនជាតិចាមពីជនជាតិឯទៀត ។ នៅក្នុងព្រំដែននេះមានជនជាតិខ្មែរដែលប្ដូរទៅប្រតិបត្តិសាសនាអ៊ីស្លាម និងក្រុមជាតិពន្ធុជ្វា ។ ប៉ុន្តែអត្តសញ្ញាណជាតិពន្ធុរបស់ជនជាតិចាមបង្កើតនូវព្រំដែនភាសា និងប្រវត្តិសាស្ត្ររវាងក្រុមជាតិពន្ធុទាំងនេះ ។ អត្តសញ្ញាណស្នូលស្ទើរតែក្លាយទៅជាអត្តសញ្ញាណស្ថិតថេរមួយដែលមិនផ្លាស់ប្ដូរ និងរក្សាទុកបានក្នុងអំឡុងពេលប្រវត្តិសាស្ត្រយូរអង្វែងមួយ ។ អត្តសញ្ញាណស្នូលអាចកែប្រែ ប៉ុន្តែការកែប្រែនេះត្រូវការរយៈពេលយូរជាងការផ្លាស់ប្ដូរអត្តសញ្ញាណជាយ ។ អត្តសញ្ញាណអ៊ីស្លាមរបស់ជនជាតិចាមកើតមានឡើងអស់កាលច្រើនជាង៦សតវត្សមកហើយ តែអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេវិញមានអាយុកាលកាន់តែយូរជាងនេះទៅទៀត ។ អ្វីទាំងអស់នេះផ្ទុយទៅនឹងគំនិតរបស់លោក ហល *(Hall)* និងអ្នកគាំទ្រជាច្រើនទៀត ដែលយល់ថាអត្តសញ្ញាណ គឺជាដំណើរការកំពុងតែបន្តកកើតឡើងដោយមិនចាំបាច់បែងចែកប្រភេទអត្តសញ្ញាណ និងពេលវេលា ។

អត្តសញ្ញាណស្នូលទាំងពីរជាប់ទាក់ទងគ្នាខ្លាំង ។ ជនជាតិចាមតែងតែត្រូវបានចាត់ទុកជាមូស្លីម ។ អត្តសញ្ញាណសាសនា និងអត្តសញ្ញាណជាតិពន្ធុត្រូវបានប្រើប្រាស់មានន័យដូចគ្នាក្នុងចំណោមជនជាតិចាម ។ ការប្រកួតប្រជែងរវាងអត្តសញ្ញាណទាំងពីរបានកើតឡើងជាច្រើនដង ។ នាពេលបច្ចុប្បន្ន អត្តសញ្ញាណជាតិពន្ធុមិនសូវបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ទាក់ទងនឹងសង្គម និងនយោបាយរបស់ជនជាតិចាម ប៉ុន្តែអត្តសញ្ញាណសាសនាត្រូវបានលើកឡើងមកពិភាក្សាច្រើនជាង ។ ក្នុងចំណោមជនជាតិចាមដែលរស់នៅសហរដ្ឋអាមេរិក ប្រទេសបារាំង ប្រទេសវៀតណាម និងប្រទេសផ្សេងៗទៀត អត្តសញ្ញាណជាតិពន្ធុនៅតែជាសញ្ញាណសម្គាល់ដែលកំណត់ជនជាតិចាមជាក្រុមមួយដាច់ដោយឡែក ។ ក្នុងសម័យ លន់ នល់ អត្តសញ្ញាណជាតិពន្ធុពិតជាមានសារសំខាន់ពីព្រោះជនជាតិចាមបានប្រើប្រាស់អត្តសញ្ញាណនេះ សម្រាប់បង្កើតអង្គការនយោបាយ ដើម្បីរំដោះប្រទេសចម្ប៉ាចេញពីការគ្រប់គ្រងរបស់វៀតណាម ។

**(តនៅលេខក្រោយ)**

**អេង កុកថាយ**

# អាជីពកំបាំងរបស់ ប៉ុល ពត

**(តពីលេខមុន)**

*លោកឧត្តមសេនីយ៍ ស៊ុន ហ៊ី្ស បានសរសេរទៀតថា “ការបង្ក្រាបសត្រូវដោយមិនចាំបាច់វាយប្រយុទ្ធ គឺជាវិធីសាស្ត្រមួយខ្ពស់បំផុតរបស់អ្នកមានពិសោធន៍” ។ ប្រហែលជាដោយសារ “កម្លាំងដ៏សំខាន់ទាំងនេះ របស់ខ្មែរក្រហមហើយ ដែលធ្វើឲ្យគ្រប់បញ្ហាទាំងអស់រួចផុតពីការធ្វើអត្ថាធិប្បាយរបស់បស្ចិមប្រទេសនោះ ។ ឧបសគ្គដ៏ធំបំផុតដែលរារាំងពួកខ្មែរក្រហម មិនឲ្យវិលមកកាន់អំណាចម្តងទៀតបានគឺរដ្ឋកម្ពុជា ។ ប៉ុន្តែបច្ចុប្បន្នឧបសគ្គមួយនេះ បានរំលងហួសបាត់ទៅហើយ ហើយត្រូវបានជំនួសមកវិញដោយរដ្ឋាភិបាលចម្រុះដ៏កម្សោយមួយ ។ ជោគជ័យរបស់គណបក្សហ៊្វុនស៊ិនប៉ិច គឺគ្រាន់តែជារបស់មនុស្សមួយចំនួនដែលធ្លាប់រស់នៅនិរទេសអស់រយៈពេលជិត១ភាគ៤នៃសតវត្ស ហើយដែលគ្មានបទពិសោធន៍ក្នុងការងារគ្រប់គ្រងថែមទៀត ។ ស្ថាប័ននានាដែលមានរវាងគណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច មានសភាពមិនសូវល្អប្រសើរនិងរឹងប៉ឹងឡើយ ។ រដ្ឋាភិបាលបែបនោះ វាងាយបាក់បែកជាទីបំផុតហើយ ប៉ុល ពត ក៏អាចលូកដៃចូលធ្វើវិទ្ធង្សនា និងចាត់វិធានការខ្មៅងងឹតបានយ៉ាងស្រួល ។*

*កន្លងមកនេះ ការគំរាមកំហែងយ៉ាងធ្ងន់ចំពោះខ្មែរក្រហមគឺការផ្តោតអារម្មណ៍ប្រុងប្រយ័ត្នរបស់អន្តរជាតិទៅលើពួកគេ ។ ថ្មីៗនេះ ប៉ុល ពត បានចាប់ផ្តើមប្រើឥរិយាបថទន់ភ្លន់ជាងមុនក្នុងការនិយាយជាមួយអង្គការសហប្រជាជាតិ ដោយយល់ព្រមឲ្យមានការសម្របសម្រួលបញ្ចូលកងទ័ពរបស់អង្គការនេះ និងការបើកឲ្យចេញចូលតំបន់ដែលគេត្រួតត្រា ហើយក្រុមខ្មែរក្រហមបានត្រូវគេមើលឃើញថា ជាក្រុមមួយដែលងាយស្រួលមិនរឹងត្អឹងដូចពីមុន*



ទៀតទេ ។ ប៉ុន្តែ បន្ទាប់ពីអ៊ុនតាក់ ដកចេញពីកម្ពុជាទៅ បញ្ហាខ្មែរក្រហម វានឹងសាបរលាបបន្តិចម្តងៗពីការយកចិត្តទុកដាក់របស់អន្តរជាតិពេលនោះ តើខ្មែរក្រហមនឹងធ្វើអ្វីទៀត ។ លោក ស៊ុន ហ៊ី្ស បានសរសេរថា «អ្វីដែលសំខាន់ដល់កម្រិតកំពូល ក្នុងការងារធ្វើសង្គ្រាម គឺការវាយបំបាក់យុទ្ធសាស្ត្ររបស់បច្ចាមិត្ត» ។

ប៉ុន្តែ យើងមិនត្រូវភ្លេចសោះឡើយថា ខ្មែរក្រហម និងសត្រូវស្លូពូជរបស់ខ្លួន គឺប្រជាជនកម្ពុជាចំនួនពាលាននាក់ នៅក្នុងប្រទេសកម្ពុជា ដែលពួកគេប៉ុនប៉ងបំផ្លាញឲ្យសាបសូន្យតែម្តង ។ ពាក្យសន្យាដែលធ្វើឡើងដោយបណ្តាអ្នកនយោបាយនានា ដូចជាព្រឹទ្ធសមាជិកអូស្ត្រាលី ហ្គារ៉េត អេវ៉ាន់ជាដើម ដែលមានប្រសាសន៍ថា «សហគមន៍អន្តរជាតិនឹងវាយបករាល់សកម្មភាពរបស់ខ្មែរក្រហមដែលប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាលើកទី២នេះ» គឺជារឿងគួរឲ្យអស់សំណើចពេកណាស់ ។ តើអ្នកណាទៅជាអ្នកផ្តល់កម្លាំងទ័ពសម្រាប់ការវាយបកនេះ? អូស្ត្រាលី? បារាំង? សហរដ្ឋអាមេរិក? ឬប្រហែលជាជប៉ុន? ។ ប្រសិនជាយើងក្រឡេកមួយគ្រួសមើលទៅស្ថានភាពនយោបាយផ្ទៃក្នុងរបស់បណ្តាប្រទេសទាំងនោះ ទើបយើងឃើញថា វាមិនស៊ីគ្នាទៅនឹងសេចក្តីប្រកាសរបស់លោក ហ្គារ៉េត អេវ៉ាន់ សោះ ។

ដូច្នេះ តើគុណភាពនៃពាក្យកុហកទាំងនោះវានឹងទ្រេតទៅខាងណា? ។ ក្នុងការផ្តល់ឲ្យនូវហេតុទាំងនេះ វាដូចជាស៊ីគ្នានឹង «និក្ខេបបទរបស់លោក នេត ថាយយ័រ ដែលបានសរសេរថា «បញ្ហាខ្មែរក្រហមត្រូវបានបញ្ចប់ហើយ» ជាការពិត គឺទំនងគួរឲ្យជឿដែរ ព្រោះគណបក្សហ៊្វុនស៊ិនប៉ិច និងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរឥឡូវនេះ បានងាកមកចងសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនវិញ ។ សព្វាវុធដែលដឹកតាមកប៉ាល់មកពីប្រទេសចិន បានត្រូវកាត់បន្ថយ ឬបញ្ឈប់ទាំងស្រុង ។

ដូច្នេះ រឿងទំនងគួរឲ្យជឿខាងលើនេះ វាដូចជាបញ្ច្រាសទៅនឹងនិក្ខេបបទរបស់ ស៊ុន ហ៊ី្ស ដែលបើពិនិត្យមើលទ្រឹស្តីរបស់លោក និងយកមកប្រៀបធៀបជាមួយយុទ្ធវិធីខ្មែរក្រហម យើងនឹងឃើញថា ប៉ុល ពត ស្ថិតនៅលើទីតាំងមួយដ៏ល្អនាពេលនោះ (១៩៩៣) ដើម្បីវិលមកកាន់អំណាចវិញ ជាងពេលដែលគាត់ទើបនឹងត្រូវផ្តួលរំលំកាលពីឆ្នាំ១៩៧៩ ទៅទៀត ព្រោះពេលនោះ ពួកវៀតណាមបានចាកចេញពីប្រទេសអស់ហើយ «របបរដ្ឋកម្ពុជា» បានទ្រីងដំហាន ហើយត្រូវផ្លាស់ជំនួសមកវិញ នូវអ្វីដែលមិនស្ថិតស្ថេរ ។ ចំណែក ប៉ុល ពត នៅតែមានកងទ័ពក្នុងដៃ និងនៅតែមានចំណងមិត្តភាពដ៏ពិសេសជាមួយអ្នកកាន់អំណាចខ្ពស់ៗក្នុងប្រទេសចិន និងថៃ ថែមទៀត ។ ប៉ុល ពត នៅមានសុខភាពមាំទាំនៅឡើយ ។ គាត់នៅមានទឹកដីគ្រប់គ្រងធំទូលាយបន្តួរ មានកម្លាំងមនុស្សច្រើន និងជាកំពូលអ្នកមានម្នាក់ ។ កម្លាំងរបស់គាត់បានជ្រៀតចូលយ៉ាងជ្រៅក្នុងគ្រប់គណបក្សប្រឆាំងនានា ហើយជាថ្មីម្តងទៀត ពួកគេបានធ្វើសកម្មភាពទាំងចំហ ទាំងសម្ងាត់ក្នុងទីក្រុងភ្នំពេញ ។ ខ្មែរក្រហមមានជំនឿថា ពិភពលោកហាក់ដូចជាកំពុងចាត់ទុកថា «គ្រោះគំរាមកំហែងពីខ្មែរក្រហមគ្មានអ្វីជាសំខាន់ទៀតឡើយ» ។

លោកឧត្តមសេនីយ៍ ស៊ុន ហ៊ី្ស គួរតែមានក្តីរីករាយ និងមានមោទនៈចំពោះទ្រឹស្តីនៅក្នុង «សិល្បៈនៃការធ្វើសង្គ្រាម» របស់គាត់ដែលបានសរសេរថា «អ្នកដែលខ្វះការពិនិត្យពិច័យទុកជាមុន ហើយមើលងាយគូសត្រូវរបស់ខ្លួននោះ ប្រាកដជានឹងត្រូវបច្ចាមិត្តរបស់គេចាប់ខ្លួនជាមិនខាន» ។

## ៧) ប៉ុល ពត និង ព្រះមហាក្សត្រ

នៅដើមឆ្នាំ១៩៧៩ ស្ថានីយ៍វិទ្យុផ្សាយសំឡេងបរទេសជាច្រើន បានបញ្ជាក់អះអាងថា ប្រទេសវៀតណាមបានផ្តើមធ្វើការវាយលុកយ៉ាងធំមួយប្រឆាំងនឹងប្រទេសកម្ពុជាហើយ ។ ក្នុងពេលរសៀលថ្ងៃទី២ មករា ១៩៧៩ កម្មាភិបាលខ្មែរក្រហមម្នាក់បានមកទូលសម្តេចព្រះនរោត្តម សីហនុ ឲ្យដឹងថា ព្រះអង្គ និងព្រះរាជវង្សានុវង្ស មានពេលវេលា១៥នាទី ដើម្បីរៀបចំអីវ៉ាន់របស់ខ្លួនសម្រាប់ការចាកចេញឆ្ពោះទៅគោលដៅមួយដែលមិនទាន់ដឹងនៅឡើយ ។ សម្តេចបានមានបន្ទូលទៅកាន់អ្នកម្នាង ម៉ូនិក ថា «ឱកាសរបស់យើងបានមកដល់ហើយ» ។ ព្រះអង្គរៀបចំព្រះកាយទៅរកសេចក្តីស្លាប់ទេដឹង? តាមការរៀបរាប់ផ្សេងៗរបស់បណ្តាអ្នកភៀសខ្លួនខ្មែរដែលវិទ្យុបរទេសបានផ្សព្វផ្សាយនោះ សម្តេច សីហនុ ទ្រង់ជ្រាបច្បាស់ណាស់ពី «របៀបចាត់ការ» របស់ពួកខ្មែរក្រហម ។ ពួកអ្នករងគ្រោះជាច្រើន បានត្រូវគេកុហកឲ្យចាកចេញពីផ្ទះរបស់ខ្លួន ក្រោមលេសដ៏សាមញ្ញមួយប៉ុណ្ណោះ ហើយក៏បាត់ខ្លួនជារៀងរហូត ។ ពេលនេះ គឺដល់វេនរបស់ព្រះអង្គហើយ ។ ព្រះអង្គសុខចិត្តធ្វើអត្តឃាត

ជាជាងបណ្តោយឲ្យគេនាំយកព្រះកាយទៅប្រៀបដូចជាគេនាំសត្វចៀមទៅកាន់ទីសត្តឃាតអ៊ីចឹង ។ ប៉ុន្តែ បេសកជនរបស់ខ្មែរក្រហមបានត្រឡប់មកវិញ ដោយស្នើឲ្យព្រះអង្គនាំយកម្ហូបកំប៉ុងដែលត្រៀមរួចជាស្រេចទៅជាមួយផង ។ សម្តេច សីហនុ ទ្រង់ព្រះអស្សាសៈបន្ទូរក្នុងព្រះកាយ ។ តើគេចាំបាច់ត្រូវយកស្បៀងបម្រុងទៅធ្វើអ្វី បើគេទៅរកសេចក្តីស្លាប់ដដែលនោះ?

នាពេលល្ងាចថ្ងៃទី៧ មករា នោះ ខៀវ សំផន បានមកសម្តែងការគួរសមចំពោះការបែកគ្នា ដែលសម្តេច និងព្រះរាជវង្សរបស់ព្រះអង្គត្រូវចេញដំណើរទៅខេត្តបាត់ដំបងនាភាគខាងជើងប្រទេស ។ ខៀវ សំផន បានបំភ្លឺថា ពួកឈ្លានពានវៀតណាមនៅតែបន្តការរុលមកមុខរបស់ខ្លួន ហើយថា សម្តេច និងព្រះញាតិវង្សព្រះអង្គនឹងមានសន្តិសុខគ្រប់គ្រាន់ បើសិនជាព្រះអង្គស្ថិតនៅខាងក្រៅរដ្ឋធានីជាបណ្តោះអាសន្នសិន ។ គាត់បានសន្យានឹងសម្តេចថា មិនយូរប៉ុន្មានគាត់នឹងទៅសួរសុខទុក្ខព្រះអង្គនៅបាត់ដំបងមិនខាន ។ មុនពេលព្រះអាទិត្យអស្តង្គត ក្បួនដង្ហែដោយរថយន្តជាច្រើនគ្រឿងបានធ្វើចលនាកក្រើកដីចេញទៅ ។ ស្ទើរតែមិនទាន់ចេញផុតពីភ្នំពេញផង អ្នកភៀសខ្លួនទាំងនេះ បានឮសូរសំឡេងគ្រាប់កាំភ្លើងធំផ្ទុះឯនាយឆ្ងាយនាទិសខាងកើត ។ សង្គ្រាមកាន់តែរំកិលជិតមកដល់រាជធានីហើយ ។

ខៀវ សំផន ពុំនិយាយរឿងឲ្យអស់សេចក្តីប្រាប់ព្រះអង្គទេ ដែលថា នាថ្ងៃទី៧ មករា នោះ មុនពេលព្រះអាទិត្យរះ មានកុម្ម៉ង់ដូអត្តឃាត "ដាក់កុង" របស់វៀតណាម៧កង បានសាកល្បងជ្រៀតចូលក្នុងក្រុងភ្នំពេញ ដើម្បីលួចចាប់ពង្រត់រូបសម្តេចផ្ទាល់ ប៉ុន្តែគ្មានបានការ ។ ពួកអត្តឃាតទាំងនេះ បានលួចឆ្លងទន្លេមេគង្គតាមកាណូតអូប៉័រកៅស៊ូមួយគ្រឿង ហើយបើកតម្រង់ទៅអែបប្រាំងជិតព្រះបរមរាជវាំង ។ ភាគច្រើននៃពួកនោះបានត្រូវគេបាញ់សម្លាប់ ។ ជនម្នាក់ក្នុងចំណោមកងកុម្ម៉ង់ដូទាំងនោះ ដែលគេចផុតពីគ្រោះថ្នាក់ បានរត់ភៀសខ្លួនទៅដល់ប្រទេសថៃ ជាទីដែលគេបាននិយាយពីការប៉ុនប៉ងមិនបានសម្រេចនេះ ប្រាប់ពួកភ្នាក់ងារស៊ើបការណ៍លោកខាងលិចទាំងអស់ ។ ទាល់តែក្រោយមក ទើបសម្តេច សីហនុ បានជ្រាបពីរឿងនេះច្បាស់ គឺនៅពេលដែលសម្តេចបានក្លាយទៅជាមនុស្សមានសេរីភាពមួយអង្គ ។ គោលដៅរបស់ពួកវៀតណាម គឺចង់នាំយករូបព្រះអង្គឲ្យធ្វើជាប្រមុខដឹកនាំចលនាតស៊ូមួយប្រឆាំងនឹងរដ្ឋាភិបាល ប៉ុល ពត ដែលក្រោយមក គេបានស្គាល់ក្រោមឈ្មោះថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (ដឹកនាំដោយ លោក ហេង សំរិន, លោក ជា ស៊ីម និងលោក ហ៊ុន សែន) ។

ការធ្វើដំណើរតាមផ្លូវជាតិលេខ៥ ដែលមានសភាពក្រហេងក្រហូងជាទូទៅនោះ បានធ្វើឲ្យព្រះអង្គនឿយលំបាកយ៉ាងខ្លាំង ។ សម្តេច សីហនុ ទ្រង់គង់នៅក្រុងស៊ីសូផុន តាំងពី២ថ្ងៃមកហើយ ពេលដែល ខៀវ សំផន ធ្វើដំណើរទៅទូលព្រះអង្គឲ្យដឹងមុនថា ព្រះអង្គអាចនឹងត្រឡប់ទៅក្រុងភ្នំពេញវិញបាន ព្រោះពួកបច្ចាមិត្តត្រូវបានយើងវាយរុញច្រានឲ្យថយទៅវិញអស់ហើយ ។ ដោយធ្វើឲ្យព្រះអង្គចុះទន់ខ្សោយអស់កម្លាំងទាំងរូបកាយ ទាំងប្រាជ្ញាស្មារតី ការធ្វើដំណើរទៅ និងមកនេះបង្ហាញឲ្យឃើញថា សម្រាប់កាលៈទេសៈនេះ ពួកខ្មែរក្រហមពុំមានគោលបំណងប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយប្រឆាំងនឹងព្រះអង្គនៅឡើយទេ ។ ប៉ុន្តែ តទៅទៀត តើព្រះអង្គនឹងទៅជាយ៉ាងណាចំពោះការរុលមកមុខបន្តិចម្តងៗរបស់វៀតណាម? ត្បិតអីរឿងនេះ វាផ្ទុយនឹងការអះអាងរបស់ ខៀវ សំផន ទាំងស្រុង ដែលថា សត្រូវពុំត្រូវបានវាយឲ្យថយទៅវិញទេ ។ ស្នូរសន្ធឹកគ្រាប់កាំភ្លើងធំ បានធ្វើឲ្យបន្ទប់កញ្ចក់និវេសនដ្ឋានសម្តេច ឡើងញ័ររញ្ជួយ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ស្នូរនេះហាក់ដូចជាពុកាន់តែឮជិតឡើងៗ ។

នៅល្ងាចថ្ងៃទី៥ មករា ១៩៧៩ សម្តេចសីហនុ ត្រូវបានទទួលឲ្យជួបធ្វើសវនាការដោយ "បងលេខ១" ផ្ទាល់ គឺ ប៉ុល ពត ជាមេដឹកនាំកំពូលខ្មែរក្រហម ។ រាត្រីកាលបានឈានចូលមកដល់ គេបានយាងសម្តេចលុះត្រាតែដល់អគារដ៏ស្កឹមស្កៃមួយមាន២ជាន់ ស្ថិតនៅតាមមាត់ទន្លេសាប ក្បែរវត្តភ្នំ គឺជាអតីតនិវេសនដ្ឋានរបស់អគ្គទេសាភិបាលបារាំងប្រចាំប្រទេសកម្ពុជា ។ កាលពីដើម សម្តេច សីហនុ ធ្លាប់យកអគារនេះធ្វើជាកន្លែងសម្រាប់ទទួលភ្ញៀវជាន់ខ្ពស់របស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។

សម្តេចពុំដែលបានជួបទល់មុខគ្នាជាមួយ ប៉ុល ពត តាំងពីឆ្នាំ ១៩៧៣ម្ល៉េះ ។ ក្នុងឱកាសនៃដំណើរយាងទស្សនកិច្ចរបស់ព្រះអង្គតាមតំបន់រំដោះនានានៅកម្ពុជាកាលពីខែមីនា ឆ្នាំ១៩៧៣នោះ ព្រះអង្គបានជួបនឹងមនុស្សម្នាក់ ដែលកាលណោះ មានត្រឹមតែ

ឈ្មោះថា សាឡុត ស ប៉ុណ្ណោះ ។ អ្នកប្រកាន់ទ្រឹស្តីកុម្មុយនីស្តរូបនេះ ដែលបណ្តុះបណ្តាលនៅសង្កាត់ឡាតាំងក្រុងប៉ារីសមានលក្ខណៈជាមនុស្សមិនសូវនិយាយស្តី និងសុភាពរាបសាណាស់នៅចំពោះមុខសម្តេច ហើយជាមនុស្សមិនសូវខ្វល់នឹងខ្លួនឯងឡើយ ។

បុគ្គលដែលមានលក្ខណៈទុយមុយ និងក្រអឺតក្រទមនេះ បាន "រលាយបាត់" ទៅហើយ ។ នៅថ្ងៃ៥ មករា ១៩៧៩ នោះ ក្នុងរយៈពេល៤ម៉ោង អាកប្បកិរិយារបស់គាត់មានសភាពហាក់ដូចជាមេដឹកនាំគេម្នាក់ សរុបសេចក្តីទៅ គឺជាមនុស្សចេះគួរសម និងគួរឲ្យស្រឡាញ់ចូលចិត្តយ៉ាងឥតខ្ចោះ ។ ថ្ងៃមួយ សម្តេចសីហនុបានរម្លឹកពីបរិយាកាសនាយប់នោះថា "ប៉ុល ពត ជាមនុស្សគំរោះគំរើយម្នាក់ ប៉ុន្តែ គាត់ហាក់ដូចជាគ្មានចំណុចណាមួយធ្វើឲ្យខ្ញុំស្អប់ខ្ពើមឡើយ ។គាត់ចេះសម្តែងខ្លួនដែលធ្វើឲ្យគេទន់ចិត្ត" ។សម្តេចបានត្រូវធ្វើឲ្យភ័ន្តភាំងស្រឡាំងកាំង ដោយសារការស្គាល់ទំនៀមទម្លាប់ស្តេចឥតខ្ចោះរបស់គាត់ និងលក្ខណៈពិសេសនៃការឱនលំទោនដែលគេត្រូវធ្វើចំពោះព្រះមហាក្សត្រផង ។ "អៀង សារី មិនព្រមប្រើភាសានេះជាមួយខ្ញុំទេ ។ សម្រាប់គាត់ ខ្ញុំ គឺជាពលរដ្ឋម្នាក់ដូចពលរដ្ឋឯទៀតដែរ" ។ ខៀវ សំផន មានឥរិយាបថតាមរបៀបផ្សេងពីនេះ ។ បើទុកជាគាត់ប្រកាន់ទ្រឹស្តីសមភាពក៏ដោយ ក៏គាត់និយាយជាមួយសម្តេចជាភាសារាជវាំងដែរ ។ សម្តេច សីហនុ មានព្រះបន្ទូលទៀតថា "នៅយប់នោះ ខ្ញុំដូចជាមិនជឿនឹងភ្នែកខ្លួនឯងសោះ ។ ប៉ុល ពត និយាយភាសាតែមួយដូច ខៀវ សំផន ដែរ ។ វាជារឿងអស្ចារ្យណាស់ ដែលមិនគួរឲ្យជឿ ។ ប៉ុល ពត និយាយប្រាប់ខ្ញុំថា "ព្រះករុណាទូលព្រះបង្គំ សូមអភ័យទោសដែលតម្រូវឲ្យទូលបង្គំចាត់ ខៀវ សំផន ជាតំណាងឲ្យចូលគាល់ព្រះអង្គជានិច្ចនោះ" ។ "គាត់ឱនគោរពខ្ញុំដៃទាំង២ប្រណម្យជាប់ និងប្រើប្រាស់ពាក្យ "ខ្ញុំ" តែម្តងគត់ ប៉ុន្តែគាត់ប្រើពាក្យ "រាជ្យសព្ទ" ដូចគេប្រើនៅព្រះរាជវាំងអង់គ្លេសដែរ ។ ខ្ញុំត្រូវគាត់ធ្វើឲ្យងឿងឆ្ងល់តិចជាងមុន" ។

ប៉ុល ពត បានទទូចយ៉ាងខ្លាំង ដើម្បីឲ្យសម្តេចយល់ព្រមទៅធ្វើជាតំណាងកម្ពុជានៅអង្គការសហប្រជាជាតិ ។ ជាមួយសេចក្តីរាប់អានដែលព្រះអង្គមាននៅបរទេស សម្តេចអាចមានលក្ខណៈជាអ្នកជួយសង្គ្រោះដ៏សំខាន់ម្នាក់ ។ សម្តេចមានបន្ទូលតបទៅ ប៉ុល ពត វិញថា "ព្រះអង្គស្រឡាញ់ប្រទេសជាតិរបស់ទ្រង់ និងថ្កោលទោសការឈ្លានពានរបស់វៀតណាម" សម្តេចបានសន្យាថា នឹងខំប្រឹងប្រែងដើម្បីធ្វើឲ្យកម្ពុជាទទួលបានការគាំទ្រពីក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ។ អៀង សារី បាននិយាយកាត់បន្ទូលសម្តេច ដើម្បីបញ្ជាក់ប្រាប់ព្រះអង្គថា មានតែមហេសីព្រះអង្គមួយអង្គប៉ុណ្ណោះដែលអាចអមដូនដំណើរព្រះអង្គទៅបាន ដោយមូលហេតុខ្វះកន្លែងអង្គុយក្នុងយន្តហោះ ។ សម្តេចបានស្នើទៅ ប៉ុល ពត ថា "ឯកឧត្តមខ្ញុំសូមការអនុញ្ញាតឲ្យបណ្តាសមាជិកនៃរាជវង្ស និងសហការីទាំងប៉ុន្មានរបស់ខ្ញុំ បានទៅជាមួយខ្ញុំដែរ" ។ ប៉ុល ពត ក្រឡេកមើលទៅ អៀង សារី ដែលនៅអង្គុយក្បែរសម្តេច ហើយនិយាយថា "ករុណាថ្ងៃវិសេស! សូមឯកឧត្តម អៀង សារី ជួយសម្រួលបញ្ហានេះ ដើម្បីអាចឲ្យមនុស្សរាល់គ្នាបានឡើងជិះកប៉ាល់ហោះទាំងអស់ផង" ។ ភ្លាមនោះ សម្តេច សីហនុ ហាក់ដូចជាធូរស្រាលក្នុងព្រះទ័យយ៉ាងខ្លាំង ។ សម្តេចបានថ្លែងអំណរគុណយ៉ាងប្រញាប់ ដោយដឹងយ៉ាងច្បាស់នូវអ្វីមួយដែលកំពុងបិទបាំងការជួយជ្រោមជ្រែងដែលមានតែសម្បកក្រៅនេះ ។ ប៉ុល ពត លែងរួញរាទៀតហើយ ។ មេដឹកនាំខ្មែរក្រហម បានរម្លឹកប្រាប់សម្តេចយ៉ាងយូរ អំពីប្រតិបត្តិការសឹកយ៉ាងច្រើនពោរពេញទៅដោយសុទិដ្ឋិនិយមមួយដែលគ្មានអ្វីធ្វើឲ្យរំភើបចិត្តសោះ "ក្នុងរវាង២ខែទៀត យើងនឹងវាយបណ្តេញ ពួកវៀតណាមឲ្យចេញផុតពីប្រទេស" ។ សម្តេច សីហនុ បានមានបន្ទូលតបវិញថា "សូមអបអរសាទរ ឯកឧត្តមប្រធាន សូមអបអរ!" ។ ប៉ុល ពត បានបន្ថែមទៀតថា "ចាប់ពីឥឡូវនេះទៅសម្តេចអាចយាងទៅប្រទេសចិនជាញឹកញាប់បានតាមតែព្រះអង្គសព្វព្រះទ័យ ។ ពេលនេះ ព្រះអង្គមានសេរីភាពពេញទី ហើយនឹងត្រូវបានយើងទទួលរាក់ទាក់យ៉ាងកក់ក្តៅនៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ ។ បើសិនជាព្រះអង្គសម្រេចព្រះទ័យស្ថិតនៅជាមួយពួកយើង ២-៣ថ្ងៃនោះ យើងនឹងរីករាយទទួលស្វាគមន៍ជានិច្ច" ។ អៀង សារី បានឲ្យយោបល់ដោយងក់ក្បាលជាសញ្ញានៃការយល់ព្រមតាមការស្នើ ។ សម្តេចលាន់ព្រះឱស្ឋដោយឆ្ងល់ "អូហ៍! ពិតមែនឬ? សូមអរគុណជាពន្លឹក" ។

សេរីភាពដែលជិតមកដល់ហើយនោះ ហាក់ដូចជាឃ្លាតទៅឆ្ងាយភ្លាមមួយរំពេច នាព្រឹកថ្ងៃទី ៦ មករា ១៩៧៩ ។ កាំភ្លើងធំរបស់វៀតណាម បានលាន់ឮកាន់តែមកជិតរាជធានីមែនទែនហើយ ។

តើយន្តហោះបូអ៊ីង៧០៧របស់ចិនបានមកចុះចតនៅអាកាសយានដ្ឋានពោធិ៍ចិនតុងហើយឬនៅ? បន្ទាប់មក តើវាអាចហោះឡើងទៅវិញ ដោយមិនទទួលរងគ្រាប់កាំភ្លើងធំរបស់ពួកវៀតណាមទេឬ? ។

ក្នុងករណី ដែលយន្តហោះពុំបានមក អៀង សារី បានផ្ដាំឲ្យព្រះអង្គចាកចេញពីក្រុងភ្នំពេញ និងភៀសខ្លួនចូលព្រៃសិន ។ សម្ដេចបានរម្លឹករឿងនេះឡើងវិញថា "ខ្ញុំបានរៀបចំវ៉ាលិស២ ។ វ៉ាលិសមួយ ខ្ញុំបានរៀបសម្លៀកបំពាក់សម្រាប់ទៅក្រុងញ៉ូវយ៉ក ក្នុងវ៉ាលិសមួយទៀត ខ្ញុំបានផ្ទុកម្ហូបកំប៉ុងយ៉ាងច្រើនខោអាវកាគី ខោអាវពីហ្សាម៉ា ក្រមាមួយ និងស្បែកជើងហូជីមិញ "ស្បែកជើងធ្វើពីកង់ឡានចាស់ៗ" ។ ដូច្នេះ តើព្រះអង្គត្រូវរត់ចូលព្រៃជាមួយពួកខ្មែរក្រហមទាំងនោះទៀតឬយ៉ាងណា? ចម្លើយ គឺស្ថិតនៅលើលំហមេឃស្រអាប់ងណោះ ដែលចោលការសម្លឹងមើលមិនចេះធុញទ្រាន់មកលើពួកអ្នកដំណើរជាតិចិន និងកម្ពុជា នាពេលវេលាចុងក្រោយដែលត្រូវរត់ចេញពីទីក្រុង ។ មនុស្សទាំងអស់ខំប្រឹងផ្ទៀងត្រចៀកស្ដាប់សំឡេង "ម៉ាស៊ីនដែលត្រូវមកជួយសង្គ្រោះ" ទាំងខ្វល់ចិត្ត ក្នុងស្នូរណ្ដំទ្រហឹងនៃការបាញ់កាំភ្លើងធំតគ្នាទៅវិញទៅមក ។ ព្រះអាទិត្យចាប់ផ្ដើមរះឡើងផុតពីជើងមេឃហើយ ។ ខ្យល់អាកាសមានសភាពស្ងប់ស្ងាត់យ៉ាងចម្លែក ។ សម្ដេចសីហនុ នៅរង់ចាំ "បក្សីសេរីភាព" ដែលត្រូវមកដឹកយកព្រះអង្គចេញ ពីប្រទេសទាំងតប់ប្រមល់ក្នុងព្រះទ័យ ។ វេលាថ្ងៃត្រង់យន្តហោះបូអ៊ីង៧០៧ នៃអាកាសចរស៊ីវិលចិនបានបន្ទាបខ្លួនចុះចតនៅអាកាសយានដ្ឋានពោធិ៍ចិនតុង ហើយបានហោះឡើងទៅវិញជាបន្ទាន់ ក្រោយពីដាក់មនុស្សរួចរាល់ហើយ ។

**(តទៅលេខក្រោយ)**

**ឌេត ម៉េងយាន**

# ប្រកាសស្វែងរកជីតាជីដូនមួយ

ខ្ញុំបាទឈ្មោះ សាន ថុនែម ជានិស្សិតនៅសាកលវិទ្យាល័យមួយនៅភ្នំពេញ ។ តាមរយៈការស្ដាប់អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្ដីខ្មែរក្រហម និងបានស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្នែកស្វែងរកការពិត ។ ខ្ញុំបាទមានបំណងចង់ស្វែងរកជីតាជីដូនមួយ (ឪពុកមាររបស់ឪពុកខ្ញុំ) ដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ តាមរយៈការផ្ដល់ព័ត៌មានពីឪពុកខ្ញុំ បានឲ្យដឹងថាៈ ជីតាខ្ញុំឈ្មោះ ទូច តុងឌី (ហៅ ឡុយ សុន) មានអាយុ ៤១ឆ្នាំ (ឆ្នាំ១៩៧៥) ។

នៅក្នុងរបបលន់ នល់ គាត់គឺជាទាហានកងម៉ារីន ពាក់សក្ដិ២ របស់ លន់ នល់ ហើយក្រោយមក គាត់ផ្លាស់មកធ្វើជាទាហានជើងគោកវិញ ដោយត្រូវបានដំឡើងឲ្យពាក់សក្ដិ៣ ។ គាត់ធ្លាប់សិក្សានៅសាលាយោធានៅកំបូល និងធ្លាប់បានទៅទស្សនកិច្ចនៅប្រទេសហ្វីលីពីនទៀតផង ។ នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកតាធ្លាប់មកលេងស្រុកកំណើតម្ដងដែរ ។ ក្រោយថ្ងៃ ១៧មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុង ហើយប្រពន្ធរបស់គាត់បានមកតាមរកគាត់នៅស្រុកកំណើត តែពុំបានជួបឡើយ ហើយគិតថា ប្រហែលជាគាត់ស្លាប់បាត់ហើយ ព្រោះប្រពន្ធរបស់គាត់ធ្លាប់បានដឹងពីការបោសសម្អាតអតីតទាហានលន់ នល់របស់ខ្មែរក្រហមដែរ ។ ប៉ុន្ដែទោះជាយ៉ាងណាមកទល់នឹងពេលនេះ មិនមាននរណាម្នាក់បានដឹងពីជោគវាសនារបស់លោកតាខ្ញុំយ៉ាងណាពិតប្រាកដឡើយ ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានដឹងដំណឹង ឬបានស្គាល់ឈ្មោះដែលខ្ញុំបាទរៀបរាប់ខាងលើ សូមមេត្តាទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# «អាយាតករ!» ឌុច ប្រាប់អំពីការចាប់ខ្លួន នៅក្នុងជួរបក្ស

សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច បានឆ្លងកាត់ថ្ងៃសាកសួរ



សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច

ដ៏តានតឹងដោយឡែកមួយទៀត ។ សាក្សីត្រូវបានរំពឹងអស់រយៈពេលពីរទៅបីដង ដែលតម្រូវឲ្យឆ្លើយសំណួរយ៉ាងសង្ខេប ខណៈខ្លួនមានបំណងផ្តល់ព័ត៌មានសំខាន់ៗជាច្រើន ដែលជាការឆ្លើយតបទៅនឹងមតិផ្សេងៗ ។ សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ បានស្នើសុំពេលវេលាបន្ថែមនៅថ្ងៃនេះ ហើយលោកទទួលបានភាពជោគជ័យក្នុងការភ្ជាប់ការបញ្ជារបស់ ឌុច ជាមួយ សុន សេន និង នួន ជា នៅក្នុងឱកាសជាច្រើន។ លោកចៅក្រម និងលោកប្រធាន និល ណុន បានសួរសំណួរបន្ថែមមួយចំនួនទៅកាន់សាក្សី ហើយចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ញ បានធ្វើសេចក្តីសន្និដ្ឋាននៃអង្គសវនាការថ្ងៃនេះ ជាមួយកិច្ចខិតខំប្រឹងប្រែងសួរសំណួរ ។

### សេចក្តីថ្លែងការណ៍នៅក្រោមការធ្វើទារុណកម្ម

សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ មានពេលលើកឡើងតែសំណួរពាក់កណ្តាល មុនពេលអង្គុយម្តងទៀត ។ សហមេធាវីការពារក្តី ខៀវ សំផន លោកស្រី អាន់តា ហ្គីហ្សេ បាននិយាយសំដៅទៅលើឯកសារដែលត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ កាលពីម្សិលមិញ ដែលមានការជាប់ទាក់ទងជាមួយ ខៀវ សំផន ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំក្នុងការធ្វើសេចក្តីសម្រេចចិត្តចាប់លេខាភូមិភាគបស្ចិម ជូ ជេត ហៅ ស៊ី ។ បញ្ហាត្រង់ចំណុចនេះគឺជាការដកស្រង់មានប្រភពមកពីៈ ចម្លើយសារភាពរបស់ ប៉ង់ ខណៈពេលកំពុងជាប់ឃុំនៅមន្ទីរសន្តិសុខស-២១ ។ ដូចដែលបានពន្យល់ដោយលោកចៅក្រមកាលពីម្សិលមិញ មានការសន្មតមួយថា សេចក្តីថ្លែងការណ៍ណាមួយដែលដកស្រង់ចេញពីចម្លើយសារភាពរបស់អ្នកទោសមន្ទីរសន្តិសុខស-២១ ដែលទទួលបានមកពីការធ្វើទារុណកម្ម នោះមិនអាចយកមកប្រើប្រាស់តាមនីតិវិធីនៅចំពោះមុខតុលាការបានទេ ។ សហមេធាវីការពារក្តី អាន់តា ហ្គីហ្សេ បានលើកឡើងម្តងទៀតថា បន្ទុកភស្តុតាងគឺនៅលើសេចក្តីសម្រេចទោស ដែលត្រូវតែបង្ហាញថា ការដកស្រង់នេះមិនចេញមកពីចម្លើយសារភាពនោះទេ ។ សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ បានបដិសេធថា អ្វីដែលខ្លួនបានដកស្រង់ មិនជាប់ពាក់ព័ន្ធស្ថានភាពនៃការធ្វើទារុណកម្មនោះទេ ហើយ ឌុច បានបញ្ជាក់ហើយថា សេចក្តីដកស្រង់នេះចេញពីការសន្ទនាដោយឡែកជាមួយ ប៉ង់ ។

សំណួរបន្ទាប់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ គឺផ្អែកលើឯកសារចំនួន៣ ៈ តើ ខៀវ សំផន បានដឹងថាមេដឹកនាំ និងកម្មាភិបាលត្រូវបានចាប់ខ្លួនហើយ តើការចាប់ខ្លួននេះត្រូវបានដឹងដែរឬទេ? សហមេធាវីការពារក្តី ខៀវ សំផន លោក គង់ សំអុន បានធ្វើការជំទាស់ទៅនឹងសំណួរនេះថា ៈ "ជាការស្វែងរកការធ្វើអត្ថាធិប្បាយដោយសាក្សី ទៅតាមការយល់ដឹងរបស់ខ្លួន លោកប្រធានចៅក្រម និល ណុន បានស្នើឲ្យសហព្រះរាជអាជ្ញាផ្លាស់ប្តូរការប្រើប្រាស់ពាក្យពេចន៍ក្នុងការសួរសំណួររបស់ខ្លួន ប៉ុន្តែ ឌុច អាចត្រឹមតែនិយាយថា ពេលខ្លះពួកគេបានដឹង ទោះបីជាផ្លូវការក៏ដោយ ព័ត៌មានលម្អិតពីការចាប់ខ្លួនមិនត្រូវបានបង្ហើបឲ្យដឹង



សហមេធាវីការក្តី ខៀវ សំផន លោក គង់ សំអុន

ទេ ។ ឌុច មិនជឿថា ខៀវ សំផន មិនបានដឹងពីការចាប់ខ្លួននោះទេ "ខ្ញុំជឿថា គាត់មិនមានសេចក្តីក្លាហានឡើយ" ។

*"លោកសាក្សី! តើលោកធ្លាប់ឮ ខៀវ សំផន ហៅបង ហែម អានចម្លើយសារភាពនៅវគ្គអប់រំ ឬប្រជុំបក្សដែរឬទេ?*

*"ទេ!"*

ស្វែងយល់ពីការធ្វើបន្សុទ្ធកម្ម (ការបោសសម្អាត) កម្មាភិបាលក្នុងរបបនេះ សហព្រះរាជអាជ្ញាបានស្វែងរកឲ្យឃើញ ប្រសិនបើការអនុវត្តត្រូវបានដឹងក្នុងចំណោមសមាជិកបក្ស ។ ឌុច បានប្រាប់សហព្រះរាជអាជ្ញាថា កម្មាភិបាលទាំងអស់ ដែលត្រូវចាប់ខ្លួននៅពេលនោះ ត្រូវបានបញ្ជូន និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយបានលើកឡើងពីកិច្ចប្រជុំតូចៗជាមួយតែកម្មាភិបាលមួយចំនួន ដែលត្រូវបានជ្រើសរើសតែប៉ុណ្ណោះ ។ ឌុច បានទទួលស្គាល់ថាក្នុងអំឡុងពេលប្រជុំនៅខែមករា ឆ្នាំ១៩៧៩ ខៀវ សំផន បាននិយាយថា យើងគ្រប់គ្នាគួរផ្តោតទៅលើភារកិច្ចរបស់ខ្លួន ហើយថា "សភាពការណ៍ធម្មតាទេ" ។ បើយោងតាមសាក្សី ខៀវ សំផន មិនបានលើកឡើងពីស្ថានភាពយោធាទេ ។

ការផ្តោតរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ បានជួយបង្ហាញពីភាពសង្ស័យយ៉ាងខ្លាំង ដែលថាមានការគ្រប់គ្រងក្នុងខ្សែសង្វាក់នៃការបញ្ជារបស់បក្ស ។

សហព្រះរាជអាជ្ញាអន្តរជាតិបានជំរុញឲ្យមានការយល់ដឹងបន្ថែមទៀតពីការធ្វើបន្សុទ្ធកម្មនេះ ៖ តើនរណាបានធ្វើការសម្រេចចិត្តឲ្យចាប់ខ្លួនមេដឹកនាំទាំងនេះ? សាក្សីបានឆ្លើយថា ខ្លួន និង ហ៊ុយ ទទួលបញ្ជាពីថ្នាក់លើ ហើយថា ខ្លួនឯងផ្ទាល់ (ឌុច) គ្មានសិទ្ធិសម្រេចចាប់ខ្លួនបានឡើយ ។ ឧទាហរណ៍ នួន ជា បានសម្រេចចិត្តចាប់ខ្លួន ហ៊ុយ ស្រែ អតីតប្រធានមន្ទីរសន្តិសុខព្រៃស និងជាអ្នកដែលផ្តល់បទបញ្ជាសម្លាប់ទៅកាន់សាក្សី លើកលែងតែពេល សុន សេន នៅទីនោះ ។ ប្រសិនបើប្រធានសន្តិសុខណាមួយបានធ្វើការចាប់ខ្លួនដោយគ្មានការអនុញ្ញាត សាក្សីបាននិយថា ៖ "អ្នកនោះនឹងត្រូវបានចាប់ខ្លួន និងសម្លាប់" ។

ឌុច បានផ្តល់ចម្លើយយ៉ាងវែង លើសពីការសួរសំណួររបស់សហព្រះរាជអាជ្ញារងទៅទៀត ។

## បណ្តុំនៃការបញ្ជាជាខ្សែសង្វាក់

នៅពេលត្រូវបានសួរពីចំណារសរសេរដោយដៃរបស់ខ្លួន ឌុច បានឲ្យដឹងថា ខ្លួន "ធ្វើតាមបញ្ជាតែប៉ុណ្ណោះ" ដូចកាលពីម្សិលមិញ សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ បានឲ្យ



សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់

សាក្សីពិនិត្យមើលឯកសារដែលបានបញ្ជាក់នៅក្នុងការប្រើប្រាស់ចម្លើយសារភាពពីមុន ដែលបានចោទប្រកាន់សមាជិកជាន់ខ្ពស់របស់បក្សក្នុងអំឡុងពេលសួរចម្លើយ ។ ឌុច បានបញ្ជាក់ត្រង់នេះព្រមទាំងការពិតដែលថា ជាឧទាហរណ៍យ៉ាងហោចណាស់ នួន ជា បានណែនាំឲ្យខ្លួនដកឈ្មោះមួយចំនួនចេញពីបញ្ជី ពីព្រោះគាត់មិនចង់ឲ្យអ្នកទាំងនោះដឹងថា ឈ្មោះរបស់ខ្លួនមានជាប់ពាក់ព័ន្ធ ។ អ្នកទាំងនោះ នឹងត្រូវបានចាប់ខ្លួន បន្ទាប់មក សហព្រះរាជអាជ្ញារងអន្តរជាតិ ខែលី សាក់ បានបន្ត ៖ "តើ នួន ជា ផ្តល់សេចក្តីណែនាំដល់អ្នកដែលជាប់ទាក់ទងអ្នកទោសមកពីភូមិភាគបូព៌ាដែរឬទេ?"

*"អ្នកទោស ដែលត្រូវបានបញ្ជូនមកពីបូព៌ាទៅឃុំ*

*យាំងនៅមន្ទីរសន្តិសុខស-២១ ត្រូវបានសួរចម្លើយដោយមន្ទីរសន្តិសុខស-២១ ហើយ នួន ជា មិនបានណែនាំអ្វីបន្ថែមនោះទេ ។ គាត់ (នួន ជា) បានរង់ចាំចម្លើយសារភាព ។ នៅមន្ទីរសន្តិសុខស-២១ នៅពេលសមាជិកភូមិភាគពិសេសជាច្រើន ត្រូវបានចាប់ខ្លួន ខ្ញុំត្រូវបានណែនាំឲ្យកម្ទេចអ្នកទោសដែលបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ ដើម្បីទុកកន្លែងសម្រាប់ដាក់អ្នកទោសថ្មី ។ បន្ទាប់ពីការចាប់ខ្លួនបងភឹម អ្នកទោសជាច្រើននាក់ត្រូវបានបញ្ជូនមកដល់ ។ មានមនុស្សពី២០ ទៅ៣០ នាក់ត្រូវបញ្ជូនមកតែមួយព្រឹក» ។*

ឌុច បានរំពឹងថា អ្នកទោសប្រមាណជា៣០០នាក់ ត្រូវបានបញ្ជូនទៅកាន់ជើងឯក ដែលជាកន្លែងសម្លាប់មួយក្នុងចំណោមកន្លែងសម្លាប់ផ្សេងទៀត ។ អ្នកទោសមួយចំនួនមកពីភូមិភាគបូព៌ាបានជាប់ឃុំនៅមន្ទីរសន្តិសុខស-២១ បានតែមួយថ្ងៃតែប៉ុណ្ណោះ មុនពេលត្រូវបានបញ្ជូនទៅសម្លាប់ដោយមិនត្រូវបានសួរចម្លើយ ។

ទាក់ទងនឹងកិច្ចប្រជុំអប់រំនយោបាយក្នុងខែតុលា ឆ្នាំ១៩៧៨ ដឹកនាំដោយ ប៉ុល ពត សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ បានសួរ ឌុច ថា តើ ប៉ុល ពត បានផ្តល់ការណែនាំជាក់លាក់ណាមួយដែរឬទេ? សាក្សីបានលើកឡើងពីសារាចរ ដែលត្រូវបានចេញផ្សាយថា អ្នកទោសមួយចំនួន ដែលបានសារភាពថាខ្លួនជា សេ.អ៊ី.អា និងត្រូវបានលើកលែងទោស ហើយការសួរចម្លើយត្រូវបានបញ្ឈប់ ។ ឌុច ចងចាំនូវអ្វីដែលនិយាយជាមួយ នួន ជា ៖ «តើខ្ញុំគួរធ្វើអ្វីជាមួយអ្នកទោសដែលនៅសេសល់?

បង នួន ជា បានឆ្លើយថា ៖

«ប្អូន ឌុច ឯង ក៏នៅជាមួយ (នៅក្នុងមាគ៌) បក្សដែរតើ៎

ដោយផ្អែកលើចំណុចនេះ ឌុច បាននិយាយថា ខ្លួនបានបន្តការសួរចម្លើយ ។

កំណត់ត្រាពី ទុយ ឬ ប៉ុន នៅថ្ងៃទី០៨ ខែតុលា បានបង្ហាញថា សាក្សីបានលើកឡើងថាការសួរចម្លើយអ្នកទោសខ្មែរ គួរតែធ្វើឡើងដោយមិនមានការវាយដំ និងទទួលបានចម្លើយសារភាព ៨០ភាគរយ «មិនមានការវាយដំ និងការទទួលបានចម្លើយសារភាពលម្អិត៧០ភាគរយ» និងជាមួយ (វិធានការដាច់ខាតរបស់ការិយាល័យឧក្រិដកម្ម និងអចិន្ត្រៃយ៍ទាំងស្រុងសម្រាប់ជនបរទេស «ជនជាតិយួន» និង «ចក្រពត្តិនិយម-សេអ៊ីអា») ។ សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ បានសួរថា តើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទាំងនេះត្រូវបាននាំយកដោយសាក្សី (ឌុច) ទៅកាន់អ្នកសួរចម្លើយរបស់ខ្លួនដែរឬទេ ដោយយោងតាមសេចក្តីណែនាំដែលខ្លួនទទួលបានក្នុងអំឡុងពេលប្រជុំជាមួយ ប៉ុល ពត និងកម្មាភិបាលផ្សេងទៀតដែលបានលើកឡើងពីមុន ។ សាក្សីបានបញ្ជាក់ថាអ្វីដែលខ្លួនបានប្រាប់អ្នកសួរចម្លើយគឺយកចេញពីសម័យប្រជុំអប់រំ ដឹកនាំដោយ ប៉ុល ពត ។ ផ្ទុយទៅនឹងជនជាតិខ្មែរ ចម្លើយសារភាពអាចទទួលបាន ដោយគ្មានការវាយដំ រហូតដល់៧០ភាគរយ ខណៈយួន និង សេ.អ៊ី.អា ត្រូវតែទទួលរងការវាយដំ ។

នៅពេលបន្តសួរចម្លើយកម្មាភិបាល មានសិទ្ធិពិសេសមួយបន្ទាប់ពីកិច្ចប្រជុំ សហព្រះរាជអាជ្ញាបន្ទាប់មកបានសាកសួរសាក្សីពីការសួរចម្លើយឧបនាយករដ្ឋមន្ត្រី វន វ៉េត ។ ឌុច បានឲ្យដឹងថា សមមិត្ត លីន បានចាប់ខ្លួនគាត់ (វ៉ន វេត) នៅគណៈមជ្ឈិមបក្សបន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ យោងតាមចម្លើយរបស់ ឌុច ខ្លួនបានឲ្យ ប៉ុន សួរចម្លើយ និងធ្វើទារុណកម្ម វន វ៉េត ដោយស្រោចទឹកត្រជាក់ និងបានបើកកង្ហារទៅរកគាត់ដើម្បីឲ្យរងា «ញាក់ញ័រ» ដើម្បីបង្ខំឲ្យគាត់សារភាព ហើយនៅពេលខ្ញុំចាកចេញ វន វ៉េត បានស្រែកជេរខ្ញុំថា ៖

***«អាឃាតករ!»***

*វន វ៉េត ជាអ្នកដែលបានណែនាំ ឌុច ចូលបក្ស ។*

## ***ការសួរចម្លើយ និងធ្វើទារុណកម្មរបស់អ្នកទោសសំខាន់***

សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ បានសួរថាតើ ឌុច ឬក៏នរណាផ្សេងទៀត ដែលមានតួនាទីស្រដៀងគ្នា ត្រូវតែមានការអនុញ្ញាតពីថ្នាក់លើ ប្រសិនបើជាការធ្វើទារុណកម្មអ្នកទោសសំខាន់ ដូចជា វន វ៉េត ជាដើម ។ សាក្សី បានឆ្លើយថា នួន ជា និង សុន សេន ហៅ បង ខៀវ បានផ្តល់ការណែនាំ ដោយភ្ជាប់ខ្លួនចំពោះសកម្មភាពធ្វើទារុណកម្មកម្មាភិបាលបក្ស ។

ឌុច បាននិយាយថា «ប៉ុល ពត ជាមនុស្សដែលមិនងាយជឿនរណានោះទេ» ។

បើតាមសាក្សី (ឌុច) ខ្លួននឹងមិនធ្វើអ្វីដែលមិនមែនជាបញ្ជាពី នួន ជា ឬ សុន សេន នៅពេលការសួរចម្លើយអ្នកទោសសំខាន់ត្រូវបានធ្វើឡើង ទោះបីមានពេលខ្លះ នួន ជា អនុញ្ញាតឲ្យពួកគេដំណើរការសួរចម្លើយជាធម្មតាដែលពួកគែងធ្វើ ដោយមិនបាន "ព្យាយាមរកឲ្យឃើញ ដែលហួសដែនតួនាទីរបស់ខ្លួននៅមន្ទីរសន្តិសុខស-២១"

"អ្នកមិនត្រូវភ្លេចថា នួន ជា តាមដានបញ្ហានេះយ៉ាងយកចិត្តទុកដាក់ និងត្រូវការចម្លើយសារភាពពេញលេញតែប៉ុណ្ណោះ ។ ទោះបីជាខ្ញុំគោរព សុន សេន និង វន វេត ក៏ដោយ ក៏ប៉ុន្តែខ្ញុំខ្លាច នួន ជា" ។ បច្ចេកទេសសួរចម្លើយ ជាពិសេសចំពោះកម្មាភិបាល ត្រូវបានបកស្រាយបន្ថែមទៀតដោយសាក្សី ។ ពួកគេនឹងប្រើប្រាស់សក្ខីកម្មដែលបានចោទប្រកាន់ពួកគេនៅក្នុងគោលបំណងដើម្បីគំរាមដល់កម្មាភិបាល ដែលត្រូវបានសួរចម្លើយ និងដំណើរការដែលបានសំដៅទៅលើ "ការធ្វើឲ្យខាងខ្លួនក្លាយជាពេញលេញ" ។

បន្ទាប់មក រូបថតរបស់ កុយ ធួន ត្រូវបានដាក់បង្ហាញនៅលើអេក្រង់ ៖ ឌុច បានបញ្ជាក់ថា គាត់ (កុយ ធួន) កំពុងអង្គុយនៅក្នុងបន្ទប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ។ សាក្សី បាននិយាយថា សុន សេន បានចាកចេញទៅសមរភូមិ នៅខែសីហា ឆ្នាំ១៩៧៧ ស្របពេល ខ្លួន (ឌុច) បានចាប់ផ្តើមធ្វើការឲ្យ នួន ជា នៅមន្ទីរសន្តិសុខស-២១ ។

សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ បានអះអាងដោយផ្អែកលើការថតសំឡេងផ្សាយតាមវិទ្យុ និងសៀវភៅកំណត់ត្រារបស់អ្នកសួរចម្លើយចំនួន២ក្បាល កងទ័ពត្រូវបានបញ្ជូនទៅសមរភូមិប្រយុទ្ធជាមួយកងទ័ពវៀតណាម ប្រហែលនៅក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៧ ដោយបានស្តែងឲ្យឃើញថា សុន សេន នៅតែស្ថិតនៅក្នុងទីក្រុងភ្នំពេញរហូតមក ។ ឌុច បានធ្វើការកត់សម្គាល់ថា ខ្លួនមិនដែលបានឃើញមុខ សុន សេន ក្រោយខែសីហា ឆ្នាំ១៩៧៧ ទេ ។ យើងបានធ្វើការទាក់ទងតាមវិទ្យុ ។ "នៅក្នុងឆ្នាំ១៩៧៨ អ្នកទោសមានជាប់ពាក់ព័ន្ធជាមួយ សុន សេន ហើយ ឌុច បាននិយាយថា នៅក្នុងបទសម្ភាសន៍ឆ្នាំ១៩៩៩ របស់ខ្លួន បាននិយាយសំដៅទៅរក នួន ជា (ដែលខ្លួនបានបញ្ជាក់នៅថ្ងៃនេះ) សម្រាប់សេចក្តីណែនាំ មុនចូលដល់សេចក្តីសន្និដ្ឋានថា" ៖

"ខ្ញុំដឹងថា នៅមន្ទីរសន្តិសុខស-២១ មិនត្រឹមតែជាឧបករណ៍ដើម្បីស្វែងរកការពិតនោះទេ ប៉ុន្តែក៏ជាឧបករណ៍ដើម្បីកម្ទេចអ្នកផ្សេង ដើម្បីខ្លួនឯង ។ វាពិតជាខុស ខ្ញុំបានធ្វើខុស ខ្ញុំបានបំពានការពិត"

សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ បានចូលមកដល់ទីបញ្ចប់នៃការសួរសំណួរសាក្សីយ៉ាងហ្មត់ចត់របស់ខ្លួន ។ លោកបានរាយឈ្មោះកម្មាភិបាលជាន់ខ្ពស់ទាំងអស់ ដែលត្រូវបានចាប់ខ្លួន វន វេត គណៈដឹកនាំស្ទើរតែគ្រប់ភូមិភាគ និងមេបញ្ជាការកងពលយោធាជាច្រើនទៀត ។ ជាការសន្និដ្ឋានជាមួយជនជាតិ អ៊ុយហ្គ័រ ព្រះរាជអាជ្ញាបានសួរថា ៖ ពួកគេត្រូវបានចោទថាក្បត់ និងត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ហើយក្រោយមកត្រូវបានសម្លាប់ ។ សាក្សី! តើអ្នកគិតថា បក្សកុម្មុយនីស្តកម្ពុជាអាចទទួលបានជោគជ័យក្នុងបដិវត្តន៍ទេ បើសិនទាំងអស់ឬក៏ពាក់កណ្តាលនៃគណៈដឹកនាំ និងគណៈមជ្ឈិម ជាជនក្បត់? តើមានរឿងអញ្ចឹងបានកើតឡើងចំពោះនរណាម្នាក់ដែរឬទេ? តើពួកគេបានលើកយកបញ្ហានេះ ជាមួយអ្នកដែរឬទេ?

"អត់ទេ!"

## ប្រធានចៅក្រម និល ណុន ស្នើឲ្យមានសេចក្តីបញ្ជាក់បន្ថែម

លោកប្រធាន និល ណុន បានកត់សម្គាល់ថា សាក្សីបានចងចាំឈ្មោះ និងកាលបរិច្ឆេទជាក់លាក់ និងយ៉ាងត្រឹមត្រូវ ។


ប្រធានចៅក្រម និល ណុន

"សាក្សី! អ្នកបាននិយាយថា សុន សេន បានចាកចេញនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ តើអ្នកអាចរំឭកថាតើមានព្រឹត្តិការណ៍ជាក់លាក់ណាមួយ ដែលបាននាំឲ្យអ្នកមានការចងចាំពី

កាលបរិច្ឆេទដាក់លាក់បែបហ្នឹង?

"ខ្ញុំបានចងចាំវា ព្រោះវាមានសារសំខាន់ចំពោះខ្ញុំ ។ ខ្ញុំបានធ្វើការនៅក្រោមបងធំទី២ ដែលបានទម្លាក់តួនាទីមុខតំណែងរបស់ខ្លួន ដើម្បីមកធ្វើការជាមួយខ្ញុំ ។ ត្រង់នេះបានស្ថិត ឲ្យនៅជាប់ក្នុងចិត្តរបស់ខ្ញុំ" ។

បន្ទាប់មក សាក្សីត្រូវបានសួរដើម្បីឲ្យផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតពីការបញ្ជាជាខ្សែសង្វាក់ ។ នៅក្នុងករណីរបស់លេខាភូមិភាគឧត្តរ កុយ ធួន ដែលត្រូវបានចាប់ និងឃុំខ្លួន លោកប្រធានបានសួរថាតើ ឌុច បានដឹងថាការបញ្ជានេះ ចេញមកពី ប៉ុល ពត តាមរបៀបណា? សាក្សីបានឆ្លើយថា សុន សេន បាននាំយកបទបញ្ជានេះ ហើយគាត់ (កុយ ធួន) ត្រូវបានឃុំខ្លួននៅមន្ទីរបក្ស ។ បន្ទាប់មក លោកប្រធាន និល ណុន បានផ្តោតទៅលើការប្រាស្រ័យទាក់ទង (អន្តរកម្ម) របស់សាក្សីជាមួយ នួន ជា ។ បើយោងតាមឌុច ខ្លួនបានឃើញគាត់ (នួន ជា) នៅក្នុងឱកាសជាច្រើន "បានឃើញជារៀងរាល់៣ឬ៤ថ្ងៃម្តង" ។

បន្ទាប់មក ឌុច បានបញ្ជាក់ថា ខ្លួនបានដឹងថាចម្លើយសារភាពពីមុនត្រូវបានយកមកប្រើប្រាស់ដើម្បីធ្វើឲ្យមានការជាប់ពាក់ព័ន្ធជាមួយសមាជិកបក្ស ដែលនឹងត្រូវបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ។ ឌុច បានបញ្ជាក់ថា សុន សេន ឬ បង ខៀវ ទទួលខុសត្រូវបញ្ជូនបន្តចម្លើយសារភាព មុនការសួរចម្លើយ រួមទាំងនៅក្នុងភូមិភាគផ្សេងទៀត ។ គាត់ក៏ជាអ្នកដែលបានធ្វើចំណារជាច្រើនផងដែរ ។

លោកប្រធាន បានធ្វើសេចក្តីសន្និដ្ឋានចំពោះកិច្ចដំណើរការនេះ ដោយចោទសួរថា ៖ អង្គជំនុំជម្រះ បានដឹងឮភ័ស្តុតាងទាក់ទងនឹងកិច្ចប្រជុំមួយនៅភ្នំពេញ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ នៅពហុកីឡដ្ឋានជាតិ តើអ្នកបានចូលរួមក្នុងកិច្ចប្រជុំនេះទេ?

"នៅពេលនោះ ខ្ញុំនៅអមលាំង ដោយមិនបានដឹងថាមានអ្វីកើតឡើងនៅភ្នំពេញនោះទេ" ។

**បច្ចេកទេសសួរចម្លើយបន្ថែម ៖ ការគំរាមកំហែង និងការបំភិតបំភ័យ**

សាក្សី បានរំឭកពីឈ្មោះ ឌឿន ដែលជាគណៈប្រធានមន្ទីរ


កុយ ធួន ជាប់ឃុំនៅមន្ទីរសន្តិសុខស-២១


រូបខាងឆ្វេង កុយ ធួន និង វន វ៉េត រង់ចាំទទួលគណៈប្រតិភូនៅព្រលានយន្តហោះពោធិ៍ចិនតុង

៨៧០ ត្រូវបានចាប់ខ្លួន និងត្រូវបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅឆ្នាំ១៩៧៧ ។ សាក្សីគ្រាន់តែដឹងថា អ្នកដែលបានបញ្ជាឲ្យចាប់ខ្លួន ឌឿន ចេញមកពីថ្នាក់លើ ។ ឌុច បានពន្យល់ថា ឈ្មោះសម្ងាត់ដែលខ្លួនបានប្រើប្រាស់ជាមួយ ប៊ុន និយាយថា អ្នកទោសបាននិយាយកុហកក្នុងការសួរចម្លើយរបស់គាត់ ។

## សំបុត្រពី ប៊ុន បានបង្ហាញពីវិធីបំភិតបំភ័យ ដែលត្រូវបានប្រើប្រាស់ក្នុងការសួរចម្លើយ ៖

«ម្សៀ ឌឿន! ខ្ញុំនឹងរំពឹកអ្នកដូចតទៅ ខ្លឹមសារដែលអ្នកបានសរសេរ និងកំពុងសរសេរឥឡូវអំពីរឿងរ៉ាវអ្នកផ្សេងទៀត មិនមានព្រឹត្តិការណ៍ពិត ដែលថារឿងរ៉ាវនៃការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនអ្នកនៅក្នុងបក្សទេ ។ នេះបើយោងតាមគោលការរបស់ក្រសួងសន្តិបាល សរសៃពួរកែងជើងរបស់អ្នកនឹងត្រូវដាច់ ប្រសិនបើអ្នកនៅតែរឹងចចេស» ។

ឌុច បានពន្យល់ថា ពាក្យ ម្សៀ គឺជាវិធីបន្ថយមុខតំណែងដើម្បីនិយាយទៅកាន់នរណាម្នាក់ជាភាសារខ្មែរ ដែលទំនងជាអាចភ្ជាប់ទៅនឹងការស្អប់ខ្ពើមរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះពួកបក្រពត្តិនិយមនេះ ។ សាក្សីបានបញ្ជាក់អង្គជំនុំជម្រះថា ការគំរាមកំហែង គ្រាន់តែជា «ការព្រមាន» តែប៉ុណ្ណោះ ដែលជាការពិត មិនត្រូវបានអនុវត្តនោះទេ ។ អ្នកសួរចម្លើយ ឈ្មោះ ប៊ុន ត្រូវបានបំពាក់បំប៉នដោយសាក្សី ។ នៅមន្ទីរសន្តិសុខស-២១ សាក្សីបានឲ្យ ប៊ុន សួរចម្លើយអ្នកទោសសំខាន់ៗ ហើយជានិច្ចកាលទទួលបានលទ្ធផលដោយមិនចាំបាច់វាយដំពួកគេ ។

## ស្ថានភាពធ្វើទារុណកម្ម

លោកប្រធាន និល ណុន បានយកឯកសារ ដែល ឌឿន បានសរសេរទៅកាន់ ឌុច ថា គាត់ (ឌឿន) «មិនមានពាក្យអ្វីនិយាយទេ» ដើម្បីពិពណ៌នាពីទុក្ខវេទនារបស់ខ្លួនពីការធ្វើទារុណកម្ម ដែលខ្លួនត្រូវទទួលរង ។ សហមេធាវីការពារក្តី ខៀវ សំផន អាន់តា ហ្គីហ្សេ បានជំទាស់ទៅនឹងការប្រើប្រាស់សំបុត្រ ដែលខ្លួនទទួលបានចេញពីស្ថានភាពនៃការធ្វើទារុណកម្ម ។ មេធាវីបាននិយាយថា វាជាស្ថានភាពនៃការធ្វើទារុណកម្ម ។ សហព្រះរាជអាជ្ញារងអន្តរជាតិ ឌែលី សាក់ ដែលបានចូលរួមនៅ ក្នុងកិច្ចតស៊ូពិភាក្សាលើបញ្ហានេះ កាលពីម្សិលមិញរួមទាំងព្រឹកនេះ បានក្រោកឈរឡើង និងបាននិយាយថា វិវាទនេះនៅមិនទាន់បិទបញ្ចប់នៅឡើយទេ ។

«នៅទីនេះ ត្រង់ចំណុចនេះ ត្រូវបង្ហាញឲ្យឃើញថា មានការធ្វើទារុណកម្ម ។ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម មិនអាចហាមឃាត់ (សេចក្តីថ្លែងការណ៍ ដែលអះអាងថា មានការធ្វើទារុណកម្ម) ។ វាមិនអាចជាករណីនេះបានទេ ។ ប្រសិនបើវាជាករណីជាការលើកឡើង និងការដាក់ចុះ»

មេធាវីការពារក្តី អាន់តា ហ្គីហ្សេ បានអះអាងម្តងទៀតដោយបានលើកឡើងថា ការពិតដែលថាមានការធ្វើទារុណកម្មត្រូវបានដឹងរួចទៅហើយចំពោះភាគី ។ មេធាវីបានគូសបញ្ជាក់យ៉ាងច្បាស់ រវាងចំណារដែលត្រូវបានអនុញ្ញាត និងសេចក្តីថ្លែងការណ៍ដែលត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលត្រូវបានបញ្ជូនទៅធ្វើទារុណកម្ម ។ មេធាវីធ្វើដូច្នេះដោយបានផ្អែកទៅលើការសម្រេចចិត្ត ដែលត្រូវបានធ្វើឡើងដោយចៅក្រមកាលពីម្សិលមិញ ។

លោកប្រធាន បានបដិសេធសម្រង់របស់ខ្លួន ហើយបានផ្តល់សេចក្តីវិនិច្ឆ័យទៅចៅក្រម ហ្សង់ម៉ាក ឡាវែរញ ដែលបង្ហាញសញ្ញាថា លោកចៅក្រមមានសំណួរមួយចំនួនសួរសាក្សី ។

## លោកចៅក្រម ហ្សង់ម៉ាក ឡាវែរញ៉ បទបញ្ហានៅក្នុងរបបនេះ

ចៅក្រម ហ្សង់ម៉ាក ឡាវែរញ បានសួរសាក្សីយ៉ាងលម្អិតដោយដំបូងបានសួរថាតើនៅពេលណា តា ណាគ ត្រូវបានផ្ទេរពី


ចៅក្រម ហ្សង់ម៉ាក ឡាវែរញ

មន្ទីរសន្តិសុខស-២១ ទៅកាន់គណៈមជ្ឈិមបក្ស ។ សុន សេន បាននិយាយនៅក្នុងនាមគណៈមន្ទីរ៨៧០ ។ ឌុច បានឆ្លើយថា ខ្លួនបានបញ្ចប់សកម្មភាពសេសសល់របស់ខ្លួននៅមន្ទីរសន្តិសុខស-២១

នៅខែមិថុនា ឆ្នាំ១៩៧៦ ។

ណាត ត្រូវបានបញ្ជូនទៅកាន់ក្រសួងការបរទេស ។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានសួរហេតុអ្វីបានជាការបញ្ជូននេះត្រូវបានចាត់ទុកថាជាវិធានការអវិជ្ជមាន និងជាការដាក់ទោសទណ្ឌ? ឌុច បានបញ្ជាក់ថា ការផ្ទេរនេះពិតជាអឺចឹង ប៉ុន្តែមិនបានលើកឡើងពីមូលហេតុនោះទេ ។ ណាត ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ បានមួយរយៈខ្លី មុនពេលកងទ័ពវៀតណាមបានមកដល់ ។ «សាក្សី! តើមានបទបញ្ជាឲ្យសម្លាប់ ណាត ដែរឬទេ? បើមាន តើនរណាជាអ្នកបញ្ជា?»

> «គេមិនទុកគាត់ (ណាត) យូរទេ ពីព្រោះយើងបានទទួលបានព័ត៌មានគ្រប់គ្រាន់ ក្រោយមក គាត់ត្រូវបានយកទៅសម្លាប់»

សាក្សី បានបញ្ជាក់ថា មនុស្សសំខាន់ៗត្រូវបានសម្លាប់នៅក្បែរស្រះទឹកមួយ នៅក្នុងម្តុំផ្លូវលេខ១៦៣ និងមហាវិថីម៉ៅសេទុង ។ ទីតាំងដែល ឌុច បាននិយាយ គឺជាកន្លែងដែលប្រជាជនរស់នៅក្នុងទីក្រុងភ្នំពេញបានស្គាល់ដែលបានធ្វើឲ្យមនុស្សគ្រប់គ្នាមានអារម្មណ៍អស្ចារ្យ ។

## ឌុច នៅមន្ទីរសន្តិសុខ ស-២១

ឌុច បានរំឭកថា ខ្លួនត្រូវបានតែងតាំងជាលេខាគណៈកម្មការមន្ទីរសន្តិសុខស-២១ ព្រមទាំងជាប្រធានគុកនៅខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពី ណាត ត្រូវបានផ្ទេរចេញ ។ អនុលេខារបស់ ឌុច គឺ ឈ្មោះ ហ៊ី និង ហ៊ុយ ស្រែ ជាសមាជិក ដែលអ្នកទាំង២ជាផ្នែកមួយនៃកងពល៧០៣ ដែលជាកន្លែងអ្នកទោសមន្ទីរសន្តិសសុខស-២១ជាច្រើនត្រូវបានបញ្ជូនមក ។ បន្ទាប់មក លោកចៅក្រម ឡាវែញ បានសួរអំពីការទទួលខុសត្រូវផ្សេងទៀតរបស់ ហ៊ី និង ហ៊ុយ ។ សាក្សីបានឆ្លើយថា ហ៊ុយ ទទួលកិច្ចការត្រួតពិនិត្យការធ្វើកសិកម្មនៅព្រៃស ចំណែកឯ ហ៊ី ទទួលភារៈត្រួតពិនិត្យនៅក្នុងទីក្រុងភ្នំពេញ និងជើងឯក ដែលជាវាលពិឃាដមួយនៃវាលពិឃាតផ្សេងទៀត ។ ហ៊ុយ ត្រូវបានចាប់ខ្លួន និងសម្លាប់ ប៉ុន្តែមិនមែន ហ៊ី នោះទេ ។ ចៅក្រម ឡាវែញ បានសួរសាក្សីថាតើហេតុអ្វី?

ឌុច បានឆ្លើយថា ហ៊ុយ ព្រមទាំង ហ៊ី មិនបំពេញភារកិច្ចរបស់ខ្លួន ដោយបានបញ្ជាក់សាជាថ្មីថា រាល់ការសម្រេចចិត្តធ្វើការចាប់ខ្លួននរណាម្នាក់ គឺទុកឲ្យថ្នាក់លើជាអ្នកសម្រេច ។ «ខ្ញុំត្រូវបានគេបំភ័យ ព្រោះជាធម្មតាយើងមិនអនុញ្ញាតឲ្យកម្មាភិបាលផ្សេងទៀត "មកពីទីក្រុងហាណូយ នៅក្នុងករណីនេះ" មើលចម្លើយសារភាពសត្រូវនោះទេ ។

«សាក្សី! នៅពេលអ្នកបានឃើញពីសារសំខាន់នៃតួនាទីរបស់ ប៉ង់ (អាចមើលចម្លើយសារភាព) តើអ្នកយល់ថា ប៉ង់ ជាផ្នែកមួយនៃសន្តិបាលនេះដែរឬទេ? «ការិយាល័យប្រឆាំងឧក្រិដកម្មនៃរបបខ្មែរក្រហម មានដែនអំណាចគ្រប់គ្រងសន្តិសុខផ្ទៃក្នុង និងគ្រប់គ្រងជំរំគុកដូចគុកទួលស្លែង(ស-២១) ជាដើម» ។

«ខ្ញុំបានដឹងថា ប៉ង់ ជាសមាជិកមជ្ឈិម ដូច្នេះខ្ញុំចាប់ផ្តើមគោរពគាត់ ពីព្រោះគាត់អាចនាំយកសេចក្តីណែនាំរបស់ ប៉ុល ពត ទៅកាន់មន្ទីរសន្តិសុខស-២១» ។

នៅពេលនោះ ឌុច បានឲ្យដឹងថា ប៉ង់ ជាអ្នកនាំពាក្យ និងជាប្រធានកងការពារ ប៉ុល ពត ហើយក្រោយមក ឌុច ក៏បានដឹងបន្ថែមទៀតថា គាត់ (ប៉ង់) ជាប្រធានមន្ទីរស-១៧ ។ ប៉ង់ បាននាំយកមនុស្សទៅឲ្យ ឌុច នៅក្នុងមន្ទីរសន្តិសុខស-២១ ។

សាក្សីមិនអាចរំឭកឲ្យលម្អិតបន្ថែមពី ប៉ង់ និងការជាប់ពាក់ព័ន្ធចោទប្រកាន់របស់គាត់ក្នុងការនាំយកមនុស្សពីក្រសួងការបរទេសជនបរទេស ឬក៏ជនជាតិខ្មែរ ទៅកាន់មន្ទីរសន្តិសុខស-២១ ឬក៏សកម្មភាពផ្សេងទៀតនៅក្នុងប្រទេសទេ ។

ចៅក្រម ឡាវែញ ទំនងជាកំពុងព្យាយាមអះអាងថាតើកម្មាភិបាលនៅក្នុងការសួរសំណួរបានកំពុងប្រើប្រាស់តួនាទីរបស់ខ្លួននៅក្នុងក្រសួង ដើម្បីនាំយកអ្នកទោសទៅកាន់មន្ទីរសន្តិសុខស-២១ ។ នៅពេល ប៉ង់ ត្រូវបានចាប់ខ្លួន លឹម ខន ហៅ ខេន ឬក៏ គេន (មកពីកងពល១៨០) បានឡើងជំនួស ។ ឌុច មិនបានដឹងថា ប៉ង់ មានទំនាក់ទំនងជាមួយ អៀង សារី ទេ ហើយនេះជាអ្វីដែលលោកចៅក្រម ឡាវែញ ចង់ដឹង ។

បន្ទាប់ពីមានការយល់ច្រឡំបន្តិចនៅក្នុងការផ្លាស់ប្តូរចុងក្រោយរវាងចៅក្រម និងសាក្សី លោកប្រធានចៅក្រមបានផ្អាកសវនាការ ។ សវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងបន្តនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ។

**អាលីស រមីហ្គើរ**

# ការឃោសនា ទារុណកម្ម និងកេរដំណែលពីសម័យអាណានិគមបារាំងៈ មើលដោយស៊ីជម្រៅទៅលើវិធានការរបស់ខ្មែរក្រហម

*សាក្សី ចៅក្រម និងមេធាវីបានផ្តល់ព័ត៌មានយ៉ាងលើសលប់អំពីបញ្ហានានា ហើយថ្ងៃនេះគឺផ្តោតលើចំណុចសំខាន់ៗចំនួនបី ។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានធ្វើការសន្និដ្ឋានទៅលើការសួរចម្លើយអ្នកទោសមន្ទីរស-២១ ដែលជាជនជាតិវៀតណាម មុនពេលប្រគល់វេទិកាដល់សហមេធាវីការពារក្តីរបស់ នួន ជា គឺលោក វីកទ័រ កូប៉េ ។ លោក កូប៉េ មានបំណងដាក់បញ្ចូលភាពព្រៃផ្សៃ និងវិធានការទារុណកម្មនៃរបបខ្មែរក្រហមទៅក្នុងទម្រង់ទូលាយមួយ ៖ កេរដំណែលបន្សល់ពីរបប លន់ នល់ និងសម័យអាណានិគមបារាំង ។ ផ្នែកចុងក្រោយនៃសវនាការថ្ងៃនេះគឺផ្តល់ជូនមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរ៉ូដ និង ពេជ អង្គ ដែលលើកឡើងអំពីគម្រោងផ្នែកអប់រំ វប្បធម៌ និងសិល្បៈ ដែលនឹងត្រូវអនុវត្តនាពេលខាងមុខ ។ គម្រោងសំណងសម្រាប់ជនរងគ្រោះក៏ដូចជាការសន្ទនាឆ្លងជំនាន់ដើម្បីធានាថាអំឡុងពេលដ៏សោកសង្រេងនៃរបបខ្មែរក្រហមនឹងមិនកើតមានម្តងទៀត គឺមានសារសំខាន់ចំពោះវិធានទាំងនេះ ។*

## ***ការដកពិសោធន៍ផ្នែកវេជ្ជសាស្ត្រនៅមន្ទីរស-២១***

*យោងលើអ្វីដែលសាក្សីបានលើកឡើងនៅក្នុងសក្ខីកម្មរបស់គាត់ លោកចៅក្រម ឡាវែញ បានសួរនូវព័ត៌មានលម្អិតអំពីការវះកាត់ឆៅដែលត្រូវបានធ្វើឡើងលើខ្លួនភរិយារបស់គា ជា ។ ឌុច បាននិយាយថា គាត់មិនបានបញ្ជាទេ ហើយគាត់ក៏មិនអាចនឹកឃើញថាការដកពិសោធន៍ទាំងនេះបានធ្វើឡើងដែរ ។ ចំណារផ្ទាល់របស់គាត់លើសំណុំឯកសាររបស់ស្ត្រីវ័យ២៣ឆ្នាំ ហាក់ដូចជាផ្ទុយគ្នាពីការអះអាងនេះ ក៏ប៉ុន្តែសាក្សីមិនបានធ្វើការផ្លាស់ប្តូរជំហររបស់គាត់ទេ ។*

*បន្ទាប់មក ចៅក្រមបានបង្ហាញសវនាការនូវសេចក្តីដកស្រង់ពីភាពយន្តឯកសារដែលមានចំណងជើងថា "អង្គការស្លាប់" និងធ្វើការយោងទៅកាន់ពេទ្យមួយរូបដែលធ្វើការនៅមន្ទីរឃុំឃាំង ។ នៅក្នុងសៀវភៅណែនាំវេជ្ជសាស្ត្រមួយក្បាល បានពិពណ៌នាថា ស្ត្រីវ័យ១៧ឆ្នាំមួយរូបត្រូវបាន "វះបំពង់ក ហើយវះពោះនៅមុនពេលដែលគាត់ត្រូវបានដាក់ទៅក្នុងទឹករយៈពេលពីរម៉ោង" ។ បន្ទាប់មក គាត់ត្រូវបានវាយដំ ព្រមទាំងដាក់ទៅក្នុងទឹកម្តងទៀតរយៈពេលមួយ ហើយដំណើរការនេះត្រូវបានធ្វើឡើងម្តងហើយម្តងទៀតចំនួនពីរបីដង ។ នៅពេលត្រូវបានសួរថា តើការពិពណ៌នានេះធ្វើឲ្យគាត់ចងចាំឬទេ? ឌុច បានឆ្លើយថា ៖*

> *"វាហាក់ដូចជាគេកំពុងលេងសើចជាមួយអ្នកដែលជាប់ឃុំឃាំង វាមិនមែនជាការដកពិសោធន៍ផ្នែកវេជ្ជសាស្ត្រទេ"*

*គាត់បានបញ្ជាក់ថា គាត់បានបញ្ជាឲ្យ ហ៊ី ធ្វើការពិសោធន៍នេះនៅក្នុងបរិបទនៃការស៊ើបអង្កេតមួយ បន្ទាប់ពីសាកសពលេចឡើងពីក្នុងទឹក ដើម្បីស្រាវជ្រាវឲ្យដឹងថាតើសាកសពមនុស្សអាចស្ថិតនៅក្នុងទឹកបានប៉ុន្មានថ្ងៃនៅមុនពេលដែលសាកសពនោះអណ្តែតជាថ្មី ។*

## ***ទាហានយួន និងការឃោសនាសង្គ្រាម***

*កាលពីថ្ងៃចន្ទសប្តាហ៍មុន សាក្សី ឌុច បានលើកឡើងថា នួន ជា បានបញ្ជាឲ្យគាត់សួរចម្លើយអ្នកទោសមន្ទីរស-២១ ដែលជាជនជាតិយួន (វៀតណាម) និងផ្សព្វផ្សាយចម្លើយសារភាពរបស់អ្នកទាំងនោះតាមវិទ្យុ ។ បង នួន ស្នើឲ្យធ្វើការផ្សាយពីរដងក្នុងមួយថ្ងៃ ពីប្រាំទៅដប់នាទី ។ អ្នកទាំងនោះគឺជាប្រធានបទនៃកាតព្វកិច្ចមួយចំនួន រួមមានអ្វីៗដែលបានចុះផ្សាយនៅក្នុងកូនសៀវភៅផ្សព្វផ្សាយរបស់ផ្នែកសេវាកម្មព័ត៌មាននៃក្រសួងការបរទេស*

របស់របបកម្ពុជាប្រជាធិបតេយ្យ ៖ ចម្លើយសារភាពត្រូវតែឆ្លងកាត់ការធ្វើសក្ខីកម្មទាក់ទងនឹងការបំពានលើកម្ពុជាដោយជនជាតិវៀតណាម (បោះពុម្ពផ្សាយក្នុងកក្កដា ឆ្នាំ១៩៧៨) ។

ឈ្មោះ វូ ឌីង ង៉ី ដែលជាទាហានវៀតណាមជាប់ឃុំឃាំង មាននៅក្នុងបញ្ជីឈ្មោះពីរផ្សេងពីគ្នា ។ ឌុច នៅចាំឈ្មោះនេះបាន គាត់បានពន្យល់ថា បញ្ជីឈ្មោះទាំងពីរត្រូវបានប្រើប្រាស់ដើម្បីបែងចែកទាហាន និងជនបន្ទប់ ។ តាមសម្តីរបស់គាត់ ទាហានមួយចំនួនព្យាយាមក្លែងខ្លួនជាជនស៊ីវិលដើម្បីកុំឲ្យគេចាប់ ។ សាក្សីបានរំឭកថា ង៉ី ត្រូវបានបញ្ជូនឲ្យទៅធ្វើការជាមួយនឹងរដ្ឋាភិបាលថ្មី ។ បន្ទាប់មកលោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានភ្ជាប់ចម្លើយសារភាពរបស់អតីតទាហានរូបនេះជាផ្នែកមួយនៃកូនសៀវភៅផ្សព្វផ្សាយដែលបានលើកឡើងខាងលើ ។

សហមេធាវីអន្តរជាតិការពារក្តីរបស់ ខៀវ សំផន គឺលោកស្រី អាន់តា ហ៊្គីហ្សេ បានជំទាស់លើមូលដ្ឋាននេះ ។ គាត់បានធ្វើការជំទាស់នៅថ្ងៃចន្ទ និងថ្ងៃអង្គារថា ៖ "ខ្លឹមសារនៃចម្លើយសារភាពទាំងនេះ ត្រូវបានដកស្រង់ចេញមកយ៉ាងច្បាស់ ហើយសាក្សីក៏ត្រូវបានស្នើឲ្យផ្តល់យោបល់លើកាលៈទេសៈនេះ ដែលនេះជាទង្វើមិនសមស្របទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះ និងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ។

សហព្រះរាជអាជ្ញា ឌែលី សាក់ បានឆ្លើយតបទៅកាន់លោកស្រី ហ៊្គីហ្សេ ថា នៅក្នុងករណីផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ ទំនាក់ទំនងរវាងចម្លើយសារភាពរបស់មន្ទីរស-២១ ដែលបន្ទូចតាមរយៈការធ្វើទារុណកម្ម និងការផ្សព្វផ្សាយគឺមិនទាន់អាចបញ្ជាក់បានទេ ។ មិនមានអ្វីបញ្ជាក់ថាសម្ភារឃោសនាមិនអាចសម្រេចបានតាមរយៈការធ្វើទារុណកម្មទេ ។ ចៅក្រមបានពិភាក្សាបញ្ហានេះជាមួយគ្នាអស់រយៈពេលប៉ុន្មាននាទី រួចសម្រេចថាទទួលយកការជំទាស់របស់លោកស្រីមេធាវី ហ៊្គីហ្សេ ។

ចៅក្រមបានបន្តសវនាការ ព្រមទាំងបានឲ្យ ឌុច បញ្ជាក់ថា ទាហានវៀតណាមច្រើនតែត្រូវបានសួរចម្លើយ ហេតុនេះអ្នកទាំងនោះសារភាពថា បានបង្កើតគម្រោងវៀតណាមដើម្បីដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងសម្ព័ន្ធឥណ្ឌូចិន ។

### ជីវប្រវត្តិរបស់ជនជាតិវៀតណាមនៅមន្ទីរស-២១ និងអនុសញ្ញាស្តីពីទារុណកម្ម

លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ មានការចាប់អារម្មណ៍លើជីវប្រវត្តិខ្លីៗដែលភ្ជាប់មកជាមួយនឹងសំណុំឯកសារនៃអ្នកទោសមន្ទីរស-២១ ហើយតាមការពិព័ណ៌នាលម្អិតក្នុងអំឡុងសក្ខីកម្មរបស់ សួស ធី កាលពីប៉ុន្មានសប្តាហ៍មុន ។ លោកស្រី ហ៊្គីហ្សេ បានលើកឡើងនូវការជំទាស់ដូចខាងដើម ដោយជំទាស់ថា នៅពេលដែលជីវប្រវត្តិទាំងនេះត្រូវបានបង្ហាញយ៉ាងលម្អិត ដូចជាមូលហេតុនៃការឃាត់ខ្លួន វាអាចនឹងខុសដែលថាចម្លើយសារភាពទាំងនេះត្រូវទទួលបានតាមរយៈទារុណកម្ម ។ ប្រសិនបើអ្នកទោស "សារភាពនូវទោសកំហុសដោយសារការបង្ខំ នោះយើងនឹងស្ថិតក្រោមការគ្រប់គ្រងដែលត្រូវបានហាមឃាត់" លោកស្រីបានលើកឡើងយ៉ាងដូច្នេះ ។

សហព្រះរាជអាជ្ញា ឌែលី សាក់ ក៏ដូចជាចៅក្រម គ្លោឌៀ ហ្វិន មិនយល់ស្របលើការជំទាស់នេះទេ ជាពិសេសគឺដោយសារតែជីវប្រវត្តិគឺមិនមែនជាឯកសារដែលធ្វើឡើងដោយអ្នកទោសផ្ទាល់ទេ ហើយវាត្រូវបានប្រើប្រាស់ក្នុងដំណើរការសវនាការពីមុនមក ។ លោកស្រីមេធាវី ហ៊្គីហ្សេ បានទទូចថា រាល់ធាតុផ្សំដែលទាក់ទងនឹងខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទាំងនេះ មិនត្រូវបានប្រើប្រាស់ទេ គាត់បានផ្តល់ឧទាហរណ៍មួយនៅក្នុងតុលាការនេះ ខណៈដែលក្រុមការងាររបស់គាត់គឺលោក វីកទ័រ កូប៉េ ដែលជាសហមេធាវីអន្តរជាតិការពារក្តី នួន ជា ត្រូវបានហាមឃាត់ពីការយោងទៅកាន់ឯកសារដែលប្រហាក់ប្រហែលនេះ (ថ្ងៃទី២៤ មេសា ឆ្នាំ២០១៥) ។ សហព្រះរាជអាជ្ញា ឌែលី សាក់ បានយល់ស្របចំពោះការសន្និដ្ឋាននេះ នៅពេលដែលលោកមើលប្រភពព័ត៌មានមួយចំនួន៖ "ប្រសិនបើឯកសារបង្ហាញ ថាអ្នកទាំងនេះជាអ្នកនេសាទ វាត្រូវតែមានការបញ្ជាក់យ៉ាងច្បាស់ថា ឯកសារទាំងនេះចេញមកពីបុគ្គលិកមន្ទីរឃុំឃាំង ដែលបានរាយការណ៍មិនមែនចេញពីអ្នកទោសផ្ទាល់ទេ ។

ការតស៊ូមតិនេះបង្ហាញថា មាត្រាទី១៥នៃអនុសញ្ញាស្តីពីទារុណកម្ម បើទោះជាមានសភាពត្រង់ នៅតែអាចមានការបកស្រាយផ្សេងៗគ្នាអាស្រ័យលើលក្ខណៈនៃការសិក្សាលើឯកសារទាំងនោះ ។ ចម្លើយសារភាពមួយអាចនឹងកើតចេញពីការបង្ខំ

ដោយទារុណកម្ម ។ ក៏ប៉ុន្តែ ចម្លើយនោះមិនអាចក្លាយជាភ័ស្តុតាងទេ នៅពេលវាចេញជាឯកសារដែលអាចសន្និដ្ឋានបានថាច្បាស់លាស់ និងក្តោបនូវព័ត៌មានដែលអាចទាក់ទងនឹងចម្លើយសារភាព ។ ជាចុងក្រោយ ចៅក្រមជនទែសម្រេចគាំទ្រការជំទាស់នេះ ទោះបីជាចៅក្រម ឡាវែញ បង្ហាញអំពីការយល់ស្របយ៉ាងណាក្តី ។

## ប្រើប្រាស់អ្នកទោសជនជាតិវៀតណាមជាឧបករណ៍នយោបាយ

បន្ទាប់ពីសម្រាក ចៅក្រម ឡាវែញ បានបន្តការចោទសួរ និងឲ្យសាក្សីពណ៌នាអំពីជីវិតជាប់ឃុំឃាំង ជាពិសេសនៅក្រោយពេលដែលជនជាតិវៀតណាមត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ៖ សេចក្តីសម្រេចបានធ្វើឡើងដោយថ្នាក់លើ ថាអ្នកទាំងនេះជាជនបង្កប់ ។ យ៉ាងណាមិញ ករណីអ្នកបកប្រែជនជាតិវៀតណាម ឈ្មោះ ប៉ា ថាចាន់ ហៅ ចាន់ ដែលត្រូវបានរក្សាទុកដើម្បីជួយ ម៉ម ណៃ បានផ្តល់នូវទិសដៅចាំបាច់មួយចំនួន ដូចជាអ្វីដែលគេបានប្រព្រឹត្តទៅលើអ្នកទោសជនជាតិវៀតណាម ។



អ្នកបកប្រែជនជាតិវៀតណាម ឈ្មោះ ប៉ា ថាចាន់ ហៅ ចាន់

ខ្សែវីដេអូមួយដកស្រង់ពីបទសម្ភាសន៍របស់ ប៉ា ថាចាន់ ដោយ រិទ្ធី ប៉ាន់ ត្រូវបានបង្ហាញនៅក្នុងបន្ទប់សវនាការ ។ គាត់បានបាត់បង់ភ្នែកទាំងសងខាង ហើយគាត់កំពុងមើលរូបថតចាស់ៗរបស់អ្នកទោសជនជាតិវៀតណាមនៅមន្ទីរស-២១ នៅក្នុងបន្ទប់មួយដែលមានព្យួររូបថត កាំង ហ្គេកអ៊ាវ (ឌុច) កាលពីវ័យក្មេងនៅលើជញ្ជាំង ។

«នៅពេលនោះ ខ្ញុំស្ថិតនៅក្នុងគុក ។ ខ្ញុំត្រូវតែប្រាប់អំពីរឿងរ៉ាវនានាដែលមិនជាប់ពាក់ព័ន្ធនឹងរូបខ្ញុំ ។ គេចង់ឲ្យខ្ញុំសារភាព ។ ចុងក្រោយ គេបានវាយខ្ញុំនឹងរំពាត់ ហើយនៅពេលដែលខ្ញុំមិនឆ្លើយតប គេបានវាយខ្ញុំនឹងដំបង ។ ខ្ញុំមានស្នាមជាច្រើន ។ គេវាយខ្ញុំ ។ ខ្ញុំវេទនាណាស់ ។ ខ្ញុំគឺជាជនរងគ្រោះ ។ គេតែងតែត្រូវជានិច្ច ។ ទីបំផុត គេឆក់ខ្ញុំ គេគាបដង្កៀបនៅត្រចៀកទាំងសងខាង ហើយចរន្តបានឆ្លងចូលខួរក្បាលខ្ញុំ ។ ពេលខ្លះខ្ញុំបានបាត់បង់ស្មារតី ។ ពេលខ្ញុំភ្ញាក់ឡើង គេក៏នាំខ្ញុំទៅសួរចម្លើយវិញ ។ ក្នុងពេលខ្លះទៀត គេប្រើប្រាស់វិធីសាស្ត្រដទៃ ៖ ដកក្រចកដៃខ្ញុំ ។ ខ្ញុំនៅមានស្លាកស្នាមនៅលើដៃ និងប្រអប់ជើងខ្ញុំនៅឡើយ ។ គេដកក្រចកខ្ញុំ វាពិតជាឈឺផ្សាណាស់ ។ ការឈឺចាប់នោះពិតជាមិនអាចទ្រាំទ្របានទេ ខ្ញុំស្ទើរតែស្លាប់ទៅហើយ ។ គេជ្រមុជក្បាលខ្ញុំទៅក្នុងទឹកមួយធុង ។ បន្ទាប់មក គេចងខ្ញុំដាំចុះក្រោម ។ ខ្ញុំប្រាប់ខ្លួនឯងថាខ្ញុំនឹងត្រូវស្លាប់ ក៏ប៉ុន្តែខ្ញុំនៅតែប្រាប់ការពិត ។ គេសួរចម្លើយខ្ញុំដើម្បីស្វែងរកព័ត៌មាន គេដឹងថាខ្ញុំចេះភាសាវៀតណាម ហើយប្រាកដជាធ្វើតាមបញ្ជាគេដើម្បីធានាជីវិត ។ ថ្វីបើដូច្នេះក្តី គេរក្សាខ្ញុំទុក អ៊ីចឹង ខ្ញុំអាចធ្វើការឲ្យគេបាន ។ គេដាក់ច្រវ៉ាក់ និងខ្នោះខ្ញុំ ហើយប្រាប់ខ្ញុំឲ្យបកប្រែ និងប្រែសម្រួល ។ ប្រសិនបើខ្ញុំនិយាយអ្វីខុស ខ្ញុំនឹងត្រូវគេវាយដំ»

ចាន់ បានបន្តទៀតថា អ្នកសួរចម្លើយចង់ឲ្យអ្នកទោសជនជាតិវៀតណាមសារភាពថា គេបានចូលមកឈ្លានពានកម្ពុជា ។ អ្នកទោសទាំងនេះប្រហែលជាត្រូវបានគេសម្លាប់ និងកប់នៅជើងឯកនាពេលក្រោយមក ។ បើតាមសម្តីរបស់គាត់ នៅពេលនោះជនជាតិវៀតណាមមិនបាននៅក្នុងប្រទេសកម្ពុជាទេ ។ ចាន់ បានបន្ថែមទៀតថា នៅពេលដែលខ្មែរក្រហមមិនបានទទួលជោគជ័យក្នុងការឃាត់ខ្លួនទាហានវៀតណាម គេបានរកមកចាប់ខ្លួនជនស៊ីវិលវិញ ដោយអ្នកទាំងនោះត្រូវបានគេចាត់ទុកថាជាជនបង្កប់ ។ គេបង្ខំឲ្យអ្នកទាំងនេះស្លៀកសម្លៀកបំពាក់ និងសញ្ញាសម្គាល់របស់កងទ័ពវៀតណាមដើម្បីថតរូប និងចោទអ្នកទាំងនោះថាជាកងទ័ពវៀតណាម ។ ចាន់ បានធ្វើការសរុបសេចក្តី ដោយកាន់រូបថតជា

ច្រើនថា ៖ "គេបានក្លែងបន្លំភ័ស្តុតាង ។ គេបាននិយាយថា វាគឺជាភ័ស្តុតាងបញ្ជាក់អំពីការឈ្លានពានរបស់ជនជាតិវៀតណាម ។"ឲ្យគេគ្រាន់តែចង់ទាក់ទាញ"ជំនួយ និងការអាណិតអាសូរពីអន្តរជាតិប៉ុណ្ណោះ"

ឌុច ចំណាំ ចាន់ បានយ៉ាងច្បាស់ ក៏ប៉ុន្តែគាត់បានច្រានចោលសក្ខីកម្មនេះ ។ គាត់បាននិយាយថា ចាន់ នៅខាងជនជាតិវៀតណាម ហេតុនេះ "គាត់បានបំផ្លើសអំពីទារុណកម្មដែលធ្វើលើអ្នកទោស" លើកឡើងជាថ្មីអំពីចម្លើយរបស់គាត់ពីមុន ឌុច បដិសេធអំពីការដកក្រចក និងការជ្រមុជទឹកថាមិនមែនជាវិធីសាស្ត្រប្រើនៅក្នុងមន្ទីរស-២១ទេ ។ គាត់ក៏បានអះអាងទៀតថា អ្នកទោសជាជនជាតិវៀតណាមស៊ីវិល មិនត្រូវបានបង្ខំឲ្យសារភាពថា គេជាទាហានវៀតណាមឡើយ ។

## ខ្សែភាពយន្តឃោសនា

កាលពីសប្តាហ៍មុន សហព្រះរាជអាជ្ញា ខែលី សាក់ បានសួរសំណួរសាក្សីអំពីខ្សែភាពយន្តឃោសនាមួយដែលថតដោយក្មួយប្រុសរបស់ ប៉ុល ពត គឺ ថេង ដែលខ្សែភាពយន្តនេះបង្ហាញអំពីការឃាត់ខ្លួន និងសួរចម្លើយទាហានវៀតណាម ។ លោកចៅក្រម ឡាវែញ បានសួរថា តើខ្សែភាពយន្តនេះត្រូវបានបញ្ចាំងនៅក្នុងវគ្គសិក្សា ជាពិសេស នៅក្នុងឆ្នាំ១៩៧៨ នៅក្នុងឱកាសគម្រប់ខួបនៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥? ការលើកឡើងនេះយោងតាមសក្ខីកម្មរបស់បុគ្គលិកមន្ទីរស-២១ ដោយរួមមាន ហ៊ឹម ហ៊ុយ (នៅថ្ងៃទី៤ ឧសភា ឆ្នាំ២០១៦) ក៏ដូចជា ឡាច មាន (នៅថ្ងៃទី២៦ មេសា ឆ្នាំ២០១៦) ។ ឌុច បានបដិសេធអំពីការចាក់បញ្ចាំងខ្សែភាពយន្តនេះដល់បុគ្គលិកមន្ទីរស-២១ ព្រមទាំងនិយាយថាសាក្សីទាំងពីររូបនេះមិនអាចជឿទុកចិត្តបាន ។ ឌុច បានធ្វើការបដិសេធជាច្រើនដងចំពោះសាក្សី ឡាច មាន ថាមិនមែនជា ឡាច មានដែលខ្លួនស្គាល់នោះទេ ហើយដោយសារតែគាត់មិនមានអ្វីបញ្ជាក់អំពីខ្លួនគាត់ ។ ចៅក្រម ឡាវែញ បញ្ជាក់ថាការចោទនេះ ដោយពន្យល់ថា នៅពេលក្រោយមកហត្ថលេខាត្រូវបានបញ្ជាក់ថាមិនមែនជារបស់ ឡាច មានទេ ។

ការដកស្រង់ចេញពីខ្សែភាពយន្ត "ប្រទេសកម្ពុជា កម្ពុជា" ត្រូវបានបញ្ចាំង និងត្រូវបានបញ្ចាំងដល់សាក្សី សួស ធី នៅពេលដែលគាត់មកផ្តល់សក្ខីកម្មនៅខែឧសភាដែរ ។ រូបភាពបង្ហាញថាបុរសក្នុងឯកសណ្ឋានជាយោធាវៀតណាមបានឱនក្បាល និងនិយាយ ។ បន្ទាប់មក ប៉ុល ពត ធ្វើការថ្លែងសុន្ទរកថា ហើយប្រជាជននាំគ្នាសាទរ ។ ឌុច បាននិយាយថា អ្វីទាំងនេះមិនមែនជាខ្សែភាពយន្តដែលថតដោយ ថេង ទេ ហើយគាត់ក៏មិនមានអ្វីនិយាយបន្ថែមអំពីបញ្ហានេះដែរ ។

ទាំងនេះបានធ្វើសេចក្តីសរុបលើការចោទសួររបស់ចៅក្រម ឡាវែញ អំពីអ្វីដែលសាក្សីបានដឹងអំពីការឃោសនារបស់មន្ទីរស-២១ និងអ្នកទោសជនជាតិវៀតណាម ។ គាត់បានប្រគល់វេទិកាជូនដល់លោក វិកទ័រ កូប៉េ សហមេធាវីអន្តរជាតិការពារក្តីរបស់ នួន ជា ។



សហមេធាវីការពារក្តី នួន ជា លោក វិកទ័រ កូប៉េ

## វិធីសាស្ត្រធ្វើទារុណកម្ម ៖ សិក្សាពីជនអាណានិគមបារាំង ឬរបស់លន់ នល់?

ទោះបីជាមានជាមានគានតឹងយ៉ាងណា អ្នកទាំងអស់គ្នាបានផ្តោតអារម្មណ៍ចំពោះក្រុមការពារក្តី ។ ពោរពេញដោយ ជំហររឹងមាំ និងបេ្តជ្ញា លោក កូប៉េ ដំបូងបានធ្វើការផ្តោតទៅលើ ទីកន្លែងដែលកាំង ហ្កេកអ៊ាវ ហៅ ឌុច បានសិក្សាអំពីវិធីសាស្ត្រធ្វើទារុណកម្មដែលប្រើប្រាស់នៅមន្ទីរស-២១ ។ សាក្សីបានលើកឡើងក្នុងសប្តាហ៍នេះថា វ៉ន វេត គឺជាអ្នកបង្រៀនដល់រូបគាត់ អំពីការបន្តក់ដង្កើមអ្នកទោសដោយថង់ប្លាស្ទិក ក៏ប៉ុន្តែលោក កូប៉េ បានទាញសេចក្តីយោងទៅកាន់សក្ខីកម្មរបស់ ឌុច កាលពីឆ្នាំ២០០៩ ដែលគាត់បានលើកឡើងថា ៖

*«អ្នកដែលបានបង្រៀនខ្ញុំអំពីរបៀបធ្វើទារុណកម្ម គឺរបប លន់ នល់ ។ នេះគឺជាចំណុចទីមួយ ។ អ្នកយាមនៅគុកប៉េហ្សេ (PJ) បានវាយដំលើអ្នកទោសខ្មែរក្រហម ។ ទីពីរ គឺរបបបារាំង ។ ជនជាតិបារាំងបានធ្វើទារុណកម្មលើសមាជិកនៃបក្សពលករវៀតណាម ។*

ឌុច ត្រូវបានស្នើឲ្យបកស្រាយចំណុចនេះ ក៏ប៉ុន្តែគាត់បានបដិសេធពីការសិក្សាបច្ចេកទេសតាមរបៀបនោះ ហើយបានស្នើឲ្យលោក កូប៉េ ផ្ដល់ជូនគាត់នូវអត្ថបទសម្ភាសន៍ជាក់ស្ដែងចេញពីឯកសារដែលលើកឡើង ។ សាក្សីក៏បានបដិសេធថាគាត់មិនបានសិក្សាវិធីសាស្ត្រទាំងនោះចេញពីសៀវភៅនិពន្ធឡើងដោយ អេឡែន ឌូលស៍ ក្រោមចំណងជើង «ខបាយកលដ៏វៃឆ្លាត» "Techniques de Renseignement" ដែលគាត់បានលើកឡើងនៅក្នុងសក្ខីកម្មនៅថ្ងៃទី ១៨ ខែមិថុនា ។

សំឡេងផ្ទុយលាន់ធ្វើឲ្យការសួរចម្លើយមើលទៅហាក់ដូចជាមានបញ្ហាខ្វះ ស្របពេលនោះ លោក វីកទ័រ កូប៉េ សហមេធាវីអន្តរជាតិការពារក្ដីរបស់ នួន ជា បានបង្ហាញដល់សាក្សីនូវសម្រង់មួយចេញពីសៀវភៅរបស់ ហ្វីលីព ស្សត ។ អ្នកនិពន្ធបានអះអាងនៅក្នុងសៀវភៅនេះថា នៅពេលដែលមើលការសួរចម្លើយ និងទារុណកម្មធ្វើឡើងដោយបារាំង គឺវាស្ទើរតែដូចទៅនឹងអ្វីដែលកើតមាននៅមន្ទីរស-២១ ។

*«រដ្ឋាភិបាលប្រជាធិបតេយ្យក៏ដើរតាមផ្លូវនេះដែរ ។ ទាហានបារាំងនៅប្រទេសអាល់សេរីបានបង្កើតមន្ទីរទារុណកម្ម ដែលជាទីតាំងប្រមូលផ្ដុំពួក ហ្វីដាយីន (ជនជាតិអាល់សេរីដែលរើបម្រះ) ដែលនឹងត្រូវសម្លាប់ និងជាប់សង្ស័យ ហើយបន្ទាប់មកក៏សម្លាប់អ្នកទាំងនេះដើម្បីរក្សាការសម្ងាត់ វាគឺដូចទៅនឹងអ្វីដែលបានបញ្ជាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទោសអាល់សេរីចំនួន ៥.០០០នាក់ត្រូវបានសម្លាប់ដោយរបៀបនេះនៅក្នុងមន្ទីរសួរចម្លើយ ។ ជារួម នៅក្នុងប្រទេសទាំងមូល ចំនួននៃការស្លាប់ដោយរបៀបនេះ ប្រហែលជាលើសពី១៥ ទៅ ២០.០០០នាក់ បើប្រៀបធៀបនឹងចំនួនអ្នកស្លាប់ក្នុងមន្ទីរស-២១ ។ កត្តាដែលបណ្ដាលឲ្យជនជាតិបារាំងកាន់សាសនារ៉ូម៉ាំង-កាតូលិកវ័យក្មេង បំពានលើគោលការណ៍នៃយុត្តិធម៌ និងមនុស្សជាតិ គឺអ្នកទាំងនេះបានសិក្សាតាំងពីកុមារភាព ដែលនេះមិនមានភាពខុសប្លែកអ្វីពីអ្នកដែលគ្រប់គ្រងការប្រព្រឹត្តទៅនៃឆ្មាំមន្ទីរស-២១ទេ ។ អាចនឹងមានការអះអាងថា ចំពោះខ្មែរ វាអាចនឹងងាយស្រួលជាង៖ ការមិនអើពើចំពោះការបណ្ដុះបណ្ដាលសាសនា ។ ទោះបីជាយ៉ាងណាក្ដី មន្ទីរស-២១ ប្រព្រឹត្តទៅតាមប្រព័ន្ធគុកបារាំងពីមុន៖ ច្រវាក់ដែលប្រើនៅក្នុងគុកត្រូវបានបន្សល់ពីជំនាន់អាណានិគមបារាំង ។ ទារុណកម្មដែលខ្មែរក្រហមហៅថា «ជ្រមុជអ្នកទោសនៅក្នុងទឹក» ត្រូវបានធ្វើឡើងក្នុងតំបន់ឥណ្ឌូចិនដោយទាហានបារាំង ដែលហៅថា «la baignoire»*

សាក្សីអះអាងថា នេះជាលើកដំបូងដែលគាត់បានឮអំពីបញ្ហានេះ ។ តាមសម្ដីរបស់គាត់ ច្រវាក់ និងខ្នោះត្រូវបានធ្វើឡើងតាមការណែនាំរបស់អ្នកថ្នាក់ដឹកនាំនៅម-១៣ ។ ឌុច បានសិក្សា «មេរៀនមួយចំនួន» ពីរបប លន់ នល់ ក៏ប៉ុន្តែ «អ្វីទាំងនោះមិនដែលជ្រាបចូលទៅក្នុងការគិតផ្ទាល់ខ្លួនរបស់គាត់ទេ» ។

### ចំណេះដឹងដែលកើតមានដំណាលគ្នា

ចាប់តាំងពីការចាប់ផ្ដើមនៃសក្ខីកម្មរបស់គាត់ ឌុច ផ្ដល់ចម្លើយដោយផ្អែកលើចំណេះដឹងពីពេលដែលគាត់បម្រើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាចំណេះដឹងដែលគាត់ទទួលបានពីការអានសំណុំឯកសារ ។ លោក វីកទ័រ កូប៉េ ព្យាយាមបញ្ជាក់ថាព័ត៌មានបានមកពីពេលណា ខណៈដែលមានភាពខុសគ្នារវាងសក្ខីកម្មដែលសាក្សីផ្ដល់ឲ្យនៅពេលផ្សេងគ្នា ៖

«ខ្ញុំព្យាយាមយល់អំពីការចងចាំរបស់លោក»

លោក កូប៉េ បានលើកឡើងនូវចម្លើយមួយចំនួនរបស់សាក្សីដែលបង្ហាញអំពីភាពមិនស៊ីគ្នា និងភាពខុសគ្នារវាងសក្ខីកម្មរបស់គាត់ ក៏ប៉ុន្តែ ឌុច មិនយល់ស្របលើចំណុចនេះទេ ផ្ទុយទៅវិញ គាត់បែរជាសួររកនូវអត្ថបទសម្ភាសន៍ជាក់ស្ដែងនៃឯកសារដែលបាន

បង្ហាញដល់គាត់ ។

សហមេធាវីការពារក្តី វីកទ័រ កូប៉េ បានប្រកាន់ជំហរថា៖

“ខ្ញុំនឹងមិនបោះបង់ចោលចំពោះចំណុចនេះទេ”

កាលពីម្សិលមិញ ឌុច បានធ្វើការប៉ាន់ប្រមាណថា អ្នកទោសប្រហែល១០.០០០នាក់ត្រូវបាននាំមកមន្ទីរស-២១ ។ ទោះបីជាយ៉ាងណា នៅពេលដែលគាត់ត្រូវបានសួរអំពីចំនួនសរុបនៅក្នុងឆ្នាំ១៩៩៩ គាត់បានលើកឡើងថា “ខ្ញុំមិនអាចចាំបានទេ” ឌុច បញ្ជាក់ថាគាត់ពិតជាច្បាស់ថា សុន សេន បានចាកចេញទៅសមរភូមិនៅថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៧ ។ យ៉ាងណាមិញ ភ័ស្តុតាងខ្លះដែលបានបង្ហាញក្នុងសប្តាហ៍នេះដោយព្រះរាជអាជ្ញាក៏ដូចជាបទសម្ភាសន៍ពីមុនៗជាមួយនឹងសាក្សីផ្ទាល់ បង្ហាញនូវភាពខុសគ្នា ។

“លោកសាក្សី តើវាជាការពិតទេដែលថា លោកធ្វើការប្តូរចម្លើយរបស់ខ្លួន ដូចជាពេលដែល សុន សេន ចុះហត្ថលេខាលើចម្លើយសារភាព ពីខែតុលាទៅខែវិច្ឆិកា ក្នុងគោលបំណងធ្វើឲ្យការបរិច្ឆេទស្របទៅនឹងសំណុំឯកសារដែលលោកបានអាន?

“ឯកសារមួយណាដែលលោកសំដៅលើ? តើលោកអាចផ្តល់វាឲ្យខ្ញុំ និងទុកវានៅលើតុរបស់ខ្ញុំ? ពេលក្រោយ សូមលោកសួរសំណួរមកខ្ញុំឲ្យបានពេញលេញ”

ដោយរងការរំខានពីផ្នែកចុងក្រោយនៃការចោទសួរ ឌុច បានបញ្ចប់សក្ខីកម្មរបស់គាត់សម្រាប់សប្តាហ៍នេះ ។

## ដើមបណ្តឹងរដ្ឋប្បវេណី ៖ ផ្តោតលើជនរងគ្រោះ

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរ៉ូដ បានបន្ត និងលម្អិតនូវគម្រោងនៃការធ្វើបទបង្ហាញស្តីពីគម្រោងសំណងដែលបញ្ជាក់នៅក្នុងករណី០០២ ក្នុងនោះគម្រោងចំនួនប្រាំបី ត្រូវបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ និងរូបរាល់សម្រាប់ការអនុវត្ត ។ គាត់បានរំពឹកថា គម្រោងទាំងនេះនឹងមិនតម្រូវឲ្យមានចំណាយលើជនជាប់ចោទទេ ។ គម្រោងទាំងនេះបានទទួលថវិកាពីប្រភពខាងក្រៅដូចជាអង្គការមិនមែនរដ្ឋាភិបាលនានា ។ បន្ថែមពីនេះ គម្រោងសំណងដែលលើកឡើងក្នុងថ្ងៃនេះ នឹងក្លាយជាសំណងយុត្តាធិការ ប្រសិនបើមានជនជាប់ចោទណាម្នាក់ត្រូវជាប់ទោស ។


សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរ៉ូដ

លោកស្រី ហ្គីរ៉ូដ បានពន្យល់ថា គម្រោងទាំងនេះនឹងចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីជាចម្បង ដោយអមជាមួយនឹងគោលការណ៍គ្រឹះរបស់អង្គការសហប្រជាជាតិស្តីពីសំណង (២០០៥) ។

## គម្រោងទីមួយ ៖ កម្មវិធីលើបណ្តាញបច្ចេកវិទ្យា ស្តីពីប្រវត្តិសាស្ត្រ និងការអប់រំអំពីរបបខ្មែរក្រហម

គម្រោងនេះនឹងត្រូវបានអនុវត្តដោយ មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ។ កម្មវិធីលើបណ្តាញបច្ចេកវិទ្យានេះ នឹងរុករកនូវបញ្ហាចម្បង និងឧក្រិដ្ឋកម្មនានា ដែលកើតមានក្នុងករណី ០០២ មកថតជាភាពយន្តគំរូសម្រាប់ការអប់រំ រូបថត អត្ថបទ រូបភាពនៃសវនាការ ឯកសារសោតទស្សន៍ និងអ្វីៗដែលស្រដៀងនេះ នឹងមានការប្រឹក្សាយោបល់នៅក្នុងសវនាការនៅថ្ងៃទី២៤ មិថុនា ឆ្នាំ២០១៦ ដើម្បីពន្យល់អំពីគម្រោងនេះ ។

## គម្រោងទីពីរ ៖ ការបណ្តុះបណ្តាលគ្រូបង្រៀនវិទ្យាល័យ និងសាកលវិទ្យាល័យ

មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) បានស្នើរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅវិទ្យាល័យ និងសាកលវិទ្យាល័យទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរ ។

## គម្រោងទីបី ៖ សិល្បៈ និងការអប់រំ នៅផ្ទះមេត្តា (Meta House)

វាគឺជាគម្រោងមួយដែលមានលក្ខណៈសិល្បៈ និងអប់រំបែបទូលាយ គាំទ្រដោយផ្ទះមេត្តា (សិល្បៈកម្ពុជាវ័យក្មេង) ។ គេបានបង្កើតជារោងល្ខោនសហគមន៍ ដោយធ្វើការជាមួយនឹងសិល្បៈខ្មែរសកម្ម (Khmer Art Action) ។ ការសម្តែងនេះសង្កត់ធ្ងន់លើសកម្មភាពមោះមុត តស៊ូប្រឆាំង និងសាមគ្គីភាពនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិភាក្សារវាងអ្នកទាំងអស់គ្នា

នឹងប្រព្រឹត្តទៅបន្ទាប់ពីការសម្តែងនេះ ដែលនឹងត្រូវធ្វើឡើងនៅតាមសាលារៀន ។

**គម្រោងទីបួន ៖ ជនជាតិភាគតិចចាម**

ផ្ទះមេត្តានឹងបង្កើតជាសិក្ខាសាលាសម្រាប់ផលិតករភាពយន្តជនជាតិចាមវ័យក្មេង និងជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីថតចេញជាខ្សែភាពយន្តឯកសារ ឬភាពយន្ត ។

បន្ទាប់ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ បានបន្តនិងពន្យល់អំពីគម្រោងដែលនៅសេសសល់ ។

**គម្រោងទីប្រាំ ៖ អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម**

សិល្បៈខ្មែរ (Khmer Art Academy) សហការជាមួយនឹងក្តីករុណា T.P.O និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គម្រោងនេះគឺជាការផលិតរបាំសហសម័យបុរាណ ដែលប្រើប្រាស់ប្រវត្តិសាស្ត្រ និងសក្ខីកម្មរបស់អ្នករស់រានមានជីវិត ។ គម្រោងនេះនឹងរុករកផលប៉ះពាល់យេនឌ័រពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។ ការផលិតនេះ នឹងអមមកជាមួយនឹងការសន្ទនាបែបសហគមន៍ ដែលនឹងត្រូវធ្វើឡើងបន្ទាប់ និងមុនការសម្តែង ហើយក៏មានការប្រមូលផ្តុំសក្ខីកម្មផ្ទាល់មាត់សម្រាប់ធ្វើជាបណ្ណសារដ្ឋានអចិន្ត្រៃយ៍ទាក់ទងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។

**គម្រោងទីប្រាំមួយ ៖ សំឡេងនៃជនជាតិភាគតិច**

គម្រោងនេះមានគោលបំណងលើកឡើងកម្ពស់ការយល់ដឹងអំពីអ្វីដែលគេបានទទួលរងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមានការសហការជាមួយក្តីករុណា ។ សកម្មភាពទាំងនេះរួមមាន៖ គោលការណ៍ទំនើបកម្មដើម្បីសម្របសម្រួលដល់ការសន្ទនាបែបសហគមន៍ ពិព័រណ៍ ការរៀបរាប់ការពិតជាសាធារណៈ និងការចងក្រងឯកសារប្រវត្តិសាស្ត្រតាមរយៈការនិយាយផ្ទាល់ ។

**គម្រោងទីប្រាំពីរ ៖ សាច់រឿងដែលមិនបានប្រាប់ដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលចូលរួមនៅក្នុងករណី ០០២**

គម្រោងនេះស្ថិតក្រោមការសហការជាមួយនឹងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ។ គម្រោងនេះមានគោលបំណងបង្កើតនូវដំណើររឿងផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ដែលត្រូវបានទទួលស្គាល់ក្នុងករណី០០២ ក៏ប៉ុន្តែមិនបានធ្វើសក្ខីកម្មនៅក្នុងតុលាការ (ប្រហែលជា៣០នាក់) ។

**គម្រោងទីប្រាំបី ៖ ទីតិសម្បទា ៖ ធ្វើឲ្យប្រសើរឡើងលើផ្នែកសុខាភិបាល និងសុខុមាលភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ការផ្តោតរបស់គម្រោង គឺបង្កើតនូវសមត្ថភាពក្នុងការកសាងជំនាញវិជ្ជាជីវៈផ្នែកសុខាភិបាល អ្នកស្ម័គ្រចិត្តគាំពារផ្នែកសុខភាព ក៏ដូចជាផែនការថែទាំសុខភាពដល់សហគមន៍គោលដៅ ។

**គម្រោងទីប្រាំបួន ៖ ដំណាក់កាលសំណើ**

វាគឺជាសំណើមួយដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យអនុញ្ញាតដល់អង្គភាពរដ្ឋបាលរបស់ អ.វ.ត.ក ឲ្យក្លាយជាផ្នែកមួយនៃសំណង ។ មជ្ឈមណ្ឌលឯកសារច្បាប់ គឺជាដៃគូ ហើយវានឹងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចប្រើប្រាស់កំណត់ត្រាច្បាប់ទាក់ទងនឹងសវនាការខ្មែរក្រហម ។

សំណើមួយចំនួនដទៃទៀតរួមមាន មជ្ឈមណ្ឌលបូជនីយដ្ឋានសាធារណៈនៅក្បែរវត្តបាត់ដំបងស្ថិតក្នុងខេត្តសៀមរាប ពិធីជាសាធារណៈដើម្បីរំឭកដល់ជនរងគ្រោះនៅសៀមរាប ឬអង្គរវត្ត សំណើដល់រដ្ឋាភិបាលចំពោះក្រសួងវប្បធម៌ និងទេសចរណ៍ ដើម្បីអភិរក្សសិល្បៈ និងរចនាសម្ព័ន្ធសាធារណៈ ដែលបានផ្លាស់ប្តូរឈ្មោះដើម្បីផ្តល់កិត្តិយសដល់ជនរងគ្រោះ ។

បន្ទាប់មក ប្រធានបានផ្អាកការស្តាប់ក្តីក្នុងថ្ងៃនេះ ។ កាំង ហ្កេកអ៊ាវ ហៅឌុច នឹងបន្តសក្ខីកម្មរបស់គាត់នៅថៃច័ន្ទ ទី២០ ខែមិថុនា ។ មេធាវីការពារក្តី ជាអ្នកបន្តការត្រួតពិនិត្យលើសាក្សី ។

**អាលីស មើហ្គើរ**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការយល់ឃើញចំពោះសាលាក្តីខ្មែរក្រហម

ថ្ងៃនេះ ខ្ញុំមានឱកាសចូលរួម និងទទួលបានបទពិសោធន៍នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ឬហៅថាតុលាការខ្មែរក្រហម) ទាក់ទងហ្នឹងសំណុំរឿង០០២ ។ នេះជាលើកដំបូងរបស់ខ្ញុំក្នុងការចូលរួមសវនាការនៅតុលាការខ្មែរក្រហម ដូច្នេះអ្វីៗគ្រប់យ៉ាង គឺថ្មី និងគួរឲ្យចាប់អារម្មណ៍ចំពោះខ្ញុំ ។ ថ្ងៃនេះ លោកចៅក្រមបានបើកដំណើរការជំនុំជម្រះ ដោយប្រាកដថាមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណី (TCCP236) ។ បន្ទាប់មកលោកចៅក្រមបានពន្យល់ថា នួន ជា មានជំងឺផ្តាសាយ និងឈឺពោះ ដែលវគាត់នឹងមិនមានវត្តមាននៅក្នុងបន្ទប់សវនាការបានទេ ប៉ុន្តែគាត់នឹងតាមដានដំណើរការកាត់ក្តីនេះនៅក្នុងបន្ទប់ឃុំឃាំង ។ ប្រធានបទនៃសវនាការថៃនេះគឺការបន្សុទ្ធកម្មផ្ទៃក្នុង (ការបោសសម្អាតផ្ទៃក្នុង) របស់ខ្មែរក្រហមនៅក្នុងភូមិភាគបូព៌ា ។ លោកប្រធានតុលាការបានពិនិត្យមើលសំណួរមូលដ្ឋានផ្ទាល់ខ្លួនទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាឈ្មោះឪពុក និងម្តាយរបស់គាត់ ថ្ងៃខែឆ្នាំកំណើត ចំនួនបងប្អូនបង្កើត និងបែបនេះ ។ ខ្ញុំជឿជាក់ថា ដំណើរការនេះត្រូវបានបញ្ចប់ដើម្បីកំណត់ថាតើដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពឆ្លើយសំណួរទាំងអស់ពេញមួយសវនាការ ។

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលមានឈ្មោះ ឈុន សាម៉ន កើតនៅឆ្នាំ១៩៥៧ នៅក្នុងក្រុមគ្រួសារដែលមានបងប្អូន៨នាក់ ។ ឪពុក និងម្តាយរបស់គាត់ជាកសិកររស់នៅក្នុងតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា ។ លោកម៉ុន បានសរសេរកត់ត្រាថា បងប្អូនស្រីរបស់គាត់បានកំពុងធ្វើការជាបុគ្គលិករដ្ឋបាលឲ្យបក្សកុម្មុនីសកម្ពុជា (DPK) ។ ខ្ញុំកំពុងសន្និដ្ឋានថា នេះជាការរួមចំណែកមួយដែលបណ្តាលឲ្យគាត់ចូលរួមជាមួយខ្មែរក្រហម ។ នៅឆ្នាំ១៩៧៥ គាត់បានចូលរួមជាមួយខ្មែរក្រហម ដោយមានតួនាទីជានីសារឲ្យ៥អនុសេនាធំ ចំណុះឲ្យកងវរសេនាតូច ។ ក្រោយមក គាត់ត្រូវបានចាត់តាំងសាជាថ្មីទៅតំបន់២៣ ដោយសារតែខ្វះទាហាននៅភូមិភាគបូព៌ា ។ នៅពេលទៅដល់តំបន់២៣ គាត់ត្រូវផ្ទេរទៅអង្គភាពស៊ើបការណ៍ពិសេសរបស់កងវរសេនាធំ១១២ ។ តួនាទីជាក់លាក់ របស់គាត់នៅក្នុងអង្គភាពពិសេសនេះ គឺត្រូវប្រមូលព័ត៌មានទាក់ទងហ្នឹងចលនាសត្រូវ និងអង្គភាពស៊ើបការណ៍សម្ងាត់ផ្សេងទៀត ។ កងវរសេនាតូច១១២ត្រូវបានចល័ត ដោយបានដាក់ពង្រាយកម្លាំងស៊ើបការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ។ នៅពេលមិនមានការស៊ើបយកការណ៍ណាមួយនោះ កម្លាំងនេះនឹងពង្រាយគ្រាប់មីននៅតាមបណ្តោយព្រំដែនតែម្តង ។ ការប្រយុទ្ធគ្នាទៅវិញទៅមកនៅភូមិភាគបូព៌ា បានអូសបន្លាយរហូតដល់ឆ្នាំ១៩៧៧ ពេលដែលកងទ័ពខ្មែរក្រហមមកពីភូមិភាគមជ្ឈិមចូលមកដល់ភូមិភាគបូព៌ា ហើយបានស្នើហៅឲ្យមេបញ្ជាការ និងគណៈដឹកនាំទាំងអស់ត្រឡប់ទៅទីក្រុងវិញដើម្បីទទួលបានការបណ្តុះបណ្តាល ។ នៅពេលចាកចេញអស់ គណៈដឹកនាំភូមិភាគបូព៌ាទាំងនោះ មិនត្រូវបានឮ ឬឃើញម្តងទៀតឡើយ ។ ក្រោយមកទៀត កងទ័ពភូមិភាគមជ្ឈិមបានប្រាប់ឲ្យកងទ័ពភូមិភាគបូព៌ានៃកងវរសេនាធំ១១២ទម្លាក់អាវុធរបស់ខ្លួន ហើយទៅបណ្តុះបណ្តាល ពីព្រោះកងទ័ពបូព៌ានឹងត្រូវបានបញ្ចូលទៅក្នុងអង្គភាពភូមិភាគបូព៌ា និងត្រូវបានបំពាក់អាវុធថ្មី ។ ក្នុងអំឡុងពេលដំណើរការនេះលោក សាម៉ន បានរំឭកថា កងទ័ពភូមិភាគបូព៌ាត្រូវបានបែងចែកជា២ក្រុម អ្នកដែលបានចូលបម្រើចលនារបបខ្មែរក្រហមមុនឆ្នាំ១៩៧៥ និងអ្នកដែលចូលរួមជាមួយខ្មែរក្រហមក្រោយពីឆ្នាំ១៩៧៥ ។ មានកងទ័ព៣០០នាក់ បានចូលបម្រើខ្មែរក្រហមមុនឆ្នាំ១៩៧៥ និងមាន៤នាក់តែប៉ុណ្ណោះ បានចូលបដិវត្តន៍ក្រោយឆ្នាំ១៩៧៥ ។ នៅពេលអាវុធត្រូវបានរឹបអូស និងក្រុមនីមួយត្រូវបានបែងចែកទៅតាមមុខ


ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន

ព្រួញរបស់ខ្លួន ។ កងទ័ព៣០០នាក់ដែលចូលមុនឆ្នាំ១៩៧៥ត្រូវបានបញ្ជូនទៅកាន់ភូមិផ្សេងមួយ ដោយបានប្រាប់ពួកគេថាការបញ្ជូននេះគឺឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ ហើយនៅពេលក្រោយអង្គការនិងស្នើឲ្យកងទ័ពភូមិភាគបូព៌ាទាំងអស់វិលត្រឡប់ទៅភូមិរបស់ពួកគេវិញ ដើម្បីអនុញ្ញាតឲ្យភូមិភាគមជ្ឈិមធ្វើការបោសសម្អាត និងធ្វើការប្រយុទ្ធប្រឆាំងក្រុមប្រឆាំងនៅសេសសល់នៅក្នុងភូមិភាគមជ្ឈិម ។ បន្ទាប់មក លោក សាម៉ន បានមកដល់ភូមិ២ថ្ងៃ ហើយបន្ទាប់មកត្រូវបានប្រាប់ឲ្យទៅរាយការណ៍ទៅគណៈឃុំ ។ គណៈឃុំត្រូវបានប្រាប់ឲ្យចុះឈ្មោះកងទ័ពទាំងអស់ ដែលបានវិលត្រឡប់មកពីភូមិភាគបូព៌ាវិញ ។ នៅយប់ដដែលនៃការចុះឈ្មោះក្នុងបញ្ជីកងទ័ព មកពីភូមិភាគបូព៌ា បានមកប្រមូលផ្តុំ ដែលមានកងទ័ពភូមិភាគបូព៌ាទាំងអស់២៩នាក់ ។ លោក សាម៉ន ត្រូវបានចាប់ខ្លួន និងចោទពីបទក្បត់ជាតិប្រឆាំងបដិវត្តន៍ ។ សាម៉ន បាននិយាយថា គាត់ជាយុទ្ធជនស្មោះត្រង់ម្នាក់ និងមិនដែលប្រឆាំងបដិវត្តន៍ទេ ។ ជាការឆ្លើយតបនឹង ការលើកឡើងរបស់ខ្លួនសាម៉ន ត្រូវបានវាយដំ ដោយធាក់មួយជើងចំទ្រូង និងយកស្វាយកាំភ្លើងវៃបំបាក់ដៃគាត់ ។ គាត់ បានរំឭកថា ក្រុមកងទ័ព២៩នាក់ពីភូមិភាគបូព៌ានេះត្រូវបានប្រាប់ឲ្យងើបឈរ និងដើរជាពីរជួរចូលក្នុងព្រៃ ហើយឲ្យដោះខោអាវចេញឲ្យអស់ទុកតែខោខ្លី ដោយរង់ចាំវេនត្រូវយកទៅសម្លាប់ចោល ។ គាត់បានព្រួសម្រែកអ្នកដែលត្រូវបានយកទៅមុនគាត់ ។ ដោយស្វែងរកផ្លូវរត់គេច គាត់បានស្រាយចំណងដៃរបស់គាត់ ហើយបានជួយស្រាយខ្សែមនុស្ស២នាក់ផ្សេងទៀត ។ គាត់បានស្រែកឲ្យទាហានផ្សេងទៀតរត់ ហើយអ្នកគ្រប់គ្នាបានរត់ ។ មានកងទ័ពជាច្រើននាក់មិនមានសំណាងល្អ ហើយត្រូវបានបាញ់សម្លាប់ ពេលកំពុងរត់គេច ។ គាត់ និងមនុស្ស២នាក់ផ្សេងទៀតក្នុងចំណោមមនុស្ស២៩នាក់ អាចរួចពីសេចក្តីស្លាប់នៅពេលនោះ ។ អ្នកទាំងបីនាក់បានរត់ទៅទន្លេ និងហែលឆ្លងកាត់ទន្លេ ស្របពេលដែលកងទ័ពខ្មែរក្រហមនៅតែបន្តបាញ់មកលើពួកគាត់ពីខាងក្រោយ ។ យ៉ាងណាក៏ដោយ នៅពេលក្លី សាម៉ន អាចហែលឆ្លងកាត់ទន្លេរហូតដល់ព្រំដែនវៀតណាម ដែលជាកន្លែងគាត់បានជួបកងទ័ពខ្មែរក្រហមមួយក្រុមផ្សេងទៀត និងកងទ័ពវៀតណាម ។ នៅក្នុងសភាពអាក្រាតពាក់កណ្តាល កងទ័ពវៀតណាមដឹងថា គាត់មានទុកលំបាក និងបានការពារគាត់ ដោយបានផ្ទុះអាវុធប្រឆាំងខ្មែរក្រហមដែលតាមគាត់ ។ ក្រោយមក វៀតណាមបានសួរចម្លើយ សាម៉ន និងបានអនុញ្ញាតឲ្យគាត់ចូលរួមជាមួយកងទ័ពរំដោះ ដើម្បីជួយប្រយុទ្ធជាមួយខ្មែរក្រហម ។

តាមការផ្តល់សក្ខីកម្មរបស់ សាម៉ន វាគួរឲ្យចាប់អារម្មណ៍ជាខ្លាំងដើម្បីមើលឃើញថាតើលោកព្រះរាជអាជ្ញា និងភាគីការពារក្តីបានសាកសួរដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ ។ ខ្ញុំបានកត់សម្គាល់ឃើញថា លោកព្រះរាជអាជ្ញាបានសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីនាំគាត់បន្តរឿងរ៉ាវរបស់គាត់ និងបានអនុញ្ញាតឲ្យសាម៉ុន ចែករំលែកសក្ខីកម្មដោយសេរី ដោយគ្មានការជ្រៀតជ្រែកឬត្រឡប់ពីព្រឹត្តិការណ៍មួយទៅព្រឹត្តិការណ៍មួយដើម្បីកាត់បន្ថយសម្ពាធរបស់គាត់ ។ ក្រោយមក នៅរសៀលថ្ងៃនេះ ជាវេនរបស់មេធាវីការពារក្តី ដើម្បីសួរសំណួរ ហើយវាពិតជាមានភាពខុសគ្នាទាំងស្រុង ។ ភាគីខាងជនជាប់ចោទបានសួរពីទិដ្ឋភាពនៃរឿងរ៉ាវឲ្យលម្អិត ។ ការបង្ហាញភ័ស្តុតាងពីឯកសារភ័ស្តុតាងមុន ដើម្បីមើលឲ្យឃើញថាតើវាត្រឹមត្រូវទៅតាមអ្វីដែល សាម៉ន បានបញ្ជាក់ដែរឬទេ ។ ការដាក់សម្ពាធខ្លាំងដោយសង្ឃឹមធ្វើឲ្យការពិត និងការចងចាំរបស់សាក្សីហាក់ដូចជាស្រពិចស្រពិល ហើយនេះកាន់តែច្បាស់ចំពោះខ្ញុំថា ភាគីជនជាប់ចោទកំពុងព្យាយាមយកការលំបាកក្នុងការស្វែងរកការបញ្ជាក់ជាខ្សែសង្វាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបួរទិស និងការបង្វែរការទទួលខុសត្រូវឲ្យទៅឆ្ងាយ ពីជនជាប់ចោទចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងភូមិភាគបូព៌ា ។ មេធាវីទាំងនេះមានភាពវៃឆ្លាត និងមានបច្ចេកទេសខ្ពង់ក្នុងការសួរ ។ រឿងមួយចំនួនដែលខ្ញុំបានកត់សម្គាល់ ដោយសារតែមានភាសា៣ចម្បងដែលត្រូវបានប្រើប្រាស់នៅក្នុងតុលាការ គឺអង់គ្លេស ខ្មែរ និងបារាំង ។ ដំណើរការសួរសំណួរ និងចម្លើយនេះមានរយៈពេលវែង ដែលសវនាការនេះចាប់ផ្តើមពីម៉ោង ០៩:០០ព្រឹក រហូតដល់ម៉ោង ១១:៣០ព្រឹក និងពេលរសៀលចាប់ពីម៉ោង១៣:៣០ ដល់ម៉ោង១៦:០០ ។ បើទោះបីជា ការសាកសួរសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបញ្ចប់ក្នុងពេលនេះក៏ដោយ តែខ្ញុំអាចនិយាយបានថា នៅក្នុងបរិយាកាសពោរពេញទៅដោយសម្ពាធ ។

នេះជាបទពិសោធន៍ដ៏អស្ចារ្យមួយ ដែលខ្ញុំអាចអង្គុយនៅ

ក្នុងសវនាការនេះ ។ ចាកចេញពីសហរដ្ឋអាមេរិក ទៅតៃវ៉ាន់ និង បន្ទាប់មក មកដល់ប្រទេសកម្ពុជា ខ្ញុំមិនដែលបានដឹងពីរបបខ្មែរក្រហម នោះទេ ។

ទោះបីជាខ្ញុំស្វែងយល់ព័ត៌មានមួយចំនួនអំពីរបបខ្មែរក្រហម នេះពិតជាមានភាពខុសគ្នាទាំងស្រុងក្នុងកម្រិតនៃការយល់ដឹង និងការរៀនប្រវត្តិសាស្ត្រក្នុងស្រុក ហើយបន្ទាប់ពីបានចូលរួមក្នុងសាលាក្តីអន្តរជាតិ ខ្ញុំយល់អារម្មណ៍ថា សាលាក្តីនេះបាននាំខ្ញុំទៅដល់កម្រិតនៃការសិក្សាស្វែងយល់ និងការទទួលបានបទពិសោធន៍ពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះ ។ ដើម្បីធ្វើជាសាក្សី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់សក្ខីកម្មនៅចំពោះមុខអ្នក ហើយនេះជាបទពិសោធន៍ដ៏អស្ចារ្យ ពីព្រោះព្រឹត្តិការណ៍នៅរបបខ្មែរក្រហមដែលហាក់ដូចជាទើបតែកើតឡើងថ្មីៗរយៈកាលប៉ុន្មានឆ្នាំមុននេះ ហើយអាចត្រូវបាននាំយកនូវការបិទបញ្ចប់ ដោយការនាំយកការពិតទៅកាន់ពន្លឺមួយ ។ ខ្ញុំមិនអាចបង្ហាញឲ្យអស់នូវភាពពេញចិត្តរបស់ខ្ញុំ ចំពោះបទពិសោធន៍មួយនេះបានទេ ។ ដើម្បីអាចឃើញជាលើកដំបូងនូវប្រវត្តិសាស្ត្រមួយនេះ និងរៀនពីវា ។ ការទៅអង្គុយនៅក្នុងតុលាការកម្រិតខ្ពស់មួយ និងការដឹងពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) ផ្តល់នូវឯកសារជាច្រើនទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថាតុលាការខ្មែរក្រហម) ធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយចិត្ត ដែលបានឃើញប្រសិទ្ធភាពនៃអង្គការមួយនេះ ។

**ស៊ីហ៊ិន ឌុ**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញែកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើបសហរដ្ឋអាមេរិក ប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង អ៊ូច មករា តាមរយៈទូរស័ព្ទលេខៈ ០១៧ ៦៦៥ ៦៧៥ ។ អ៊ីម៉ែលៈ truthmakara@dccam.org

គេហទំព័រៈ www.ariverchangescourse.com





# រសាត់តាមខ្យល់



**(តពីលេខមុន)**

«អ្នកនៅរស់ដែរ?» អាឃ្មី ពោលមកកាន់ខ្ញុំដោយត្រេកអរ ខ្ញុំបានតបទៅវាវិញថា «បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ អញស្មានតែអ្នកឆ្លងមិនផុតទេ! ចុះអ្នកនៅឯណាសព្វថ្ងៃ?» «អញនៅជាមួយម្ដាយធម៌ អញធាក់កង់ឌុបកន្ទេលយកមកលក់...ចុះអ្នកសព្វថ្ងៃ?» ខ្ញុំមិនទាន់និយាយផុតពីមាត់ផង អាឃ្មី បានតបមកខ្ញុំវិញថាៈ «សព្វថ្ងៃអញនៅតែម្នាក់ឯងទេ អញចូលធ្វើការហើយ អញរស់នៅហ្នឹងកន្លែងធ្វើការតែម្ដង» ខ្ញុំប្រញាប់សួរទៅវាភ្លាមថាៈ «អ្នកធ្វើការស្អីសព្វថ្ងៃ?» «អញធ្វើការជាមួយអ្នកការសែតអានេះ តោះអញនាំអ្នកទៅឲ្យស្គាល់កន្លែង អញ» ។

អាឃ្មី យកកង់ខ្ញុំទៅផ្ញើគ្រួសារអ្នកភូមិមួយដែលរស់នៅខាងមុខពេទ្យលោកសង្ឃ ហើយវាបាននាំខ្ញុំដើរតម្រង់ទៅកាន់ឡានរ៉ុលវ៉ាហ្កែនមួយគ្រឿងដែលចតឆ្ងាយបន្តិចពីទីនោះ ។ អាឃ្មី នៅបានប្រាប់ខ្ញុំថា ឡាននេះគឺជាឡានប្រចាំកន្លែងកាសែតរបស់វា ។ នៅពេលដែលខ្ញុំឆ្ងល់ហើយសួរវាថា ចុះអ្នកចេះបើកឡានពីអង្កាល់ អាឃ្មី តបមកខ្ញុំវិញថាចុះមានពិបាកអីរៀន តែពីរបីថ្ងៃចេះបើកហើយ ។

ពេលដែលខ្ញុំចូលទៅអង្គុយក្នុងឡានទន្ទឹមវា អាឃ្មី ចាប់ផ្ដើមបញ្ឆេះម៉ាស៊ីនឡាន គឺជាឡានរ៉ុលវ៉ាហ្កែនយ៉ាងកញ្ចាស់ប្រហែលជាតាំងពីជំនាន់ហ៊ីត្លែរមកម្ល៉េះ ទំរាំតែនឹងឡានឆេះ អាឃ្មី សឹងតែចុះហៅឲ្យគេជួយរុញម្ដងៗ អាឃ្មី បញ្ចូលលេខមួយរៀបតែនឹងបើកចេញទៅមុខស្រាប់តែឡានកញ្ឆក់ទៅមុខរលត់ឈឹង អាឃ្មី សាកល្បងជាថ្មីម្ដងទៀត ហើយវាបានងាកមកនិយាយប្រាប់ខ្ញុំថា «ឡានអញនេះរុញច្រើនជាងជិះ» ។

អាឃ្មី បើកឡានកាត់មុខសកលវិទ្យាល័យភ្នំពេញ ដែលមានសភាពយ៉ាងស្ងាត់ជ្រងំ តាមផ្លូវកម្ពុជាក្រោម នៅចំពីមុខរោងកុនឋានសួគ៌កណ្ដាលថ្នល់បំបែកមានដាក់របាំងបន្ទាលួសធំមួយ ខ្ញុំឃើញមានកងស៊ុយត្រាណខ្មែរពីរនាក់ស្ពាយកាំភ្លើងឈរកណ្ដាលថ្នល់ ម្នាក់ទៀតអង្គុយនៅនឹងតុតូចមួយក្បែរកាំជណ្ដើររោងកុន ។ អាឃ្មី បត់ស្ដាំបើកកាត់មុខបុរីកីឡាជាកន្លែងដែលកងទ័ពវៀតណាមឈរជើង តាមបណ្ដោយផ្លូវនានាក្នុងទីក្រុងពុំឃើញមានប្រជាជន ធ្វើដំណើរទៅមកទេ យូរៗម្ដងខ្ញុំឃើញរថយន្តដឹកកងទ័ពវៀតណាម និងរថយន្តអ្នកធ្វើការបើកឆ្លងកាត់ ។

ខ្ញុំហាក់ដូចជានឹកស្រងេះស្រងោចក្នុងចិត្តពេលដែលបានឃើញរបងស្តាតអូឡាំពិកត្រូវស្មៅដុះឡើងព័ទ្ធយ៉ាងទ្រុបទ្រុល ។ ពីស្តាតអូឡាំពិកមកដល់វិមានឯករាជ្យស្ងាត់ឈឹង ក្រៅពីឡានអាឃ្មី គ្មានអ៊ីមករំខានទេ អាឃ្មី បត់ឡានបើកតម្រង់ទៅចំការមន ។ ទីស្នាក់ការកាសែត អាឃ្មី នៅហ្នឹងកំណាត់ផ្លូវនោះ ទំនងបែបជាអតីតភូមិគ្រឹះរបស់មន្ត្រីរដ្ឋការនៃរបបលន់ នល់ ។ អាឃ្មី រស់នៅក្នុងកន្លែងធ្វើការតែម្ដង នៅខាងក្រោយ និងបន្ទប់តូចមួយដែលក្នុងបន្ទប់នោះ អាឃ្មី មានតែគ្រែដេក តុសរសេរនិងទូដាក់ខោអាវមួយតែប៉ុណ្ណោះ ។

យប់ជួបគ្នាដំបូងនោះ ខ្ញុំ និងអាឃ្មី មិនបាននឹកគិតដល់រឿងដេកពួនទេ យើងជជែកគ្នារហូតទល់ភ្លឺ ។ អាឃ្មី មានទឹកមុខក្រៀមក្រំ

ចំពោះដំណឹងមរណភាពរបស់អ្នកម៉ែខ្ញុំ ពូដន និងធានីកូនស្រីរបស់គាត់ ហើយវានៅបាននិយាយថា ថ្ងៃណាមួយយើងនឹងទៅរកមីងណារុង នៅកំពង់ចាម ។

អាឃ្មី វាមិនចង់ឲ្យខ្ញុំត្រឡប់ទៅវិញទេ វាចង់ឲ្យខ្ញុំរកការងារធ្វើនឹងគេ ហើយរស់នៅជាមួយវាបានគ្នាពីរនាក់ ។ ការពិតក្នុងចិត្តខ្ញុំក៏ធ្លាប់បានគិតដូច្នេះដែរ ខ្ញុំក៏បានប្រាប់ទៅវាថា ឲ្យអញត្រឡប់ទៅទន្ទេវិញលាម្ដាយធម៌ និងប្អូនៗអញសិន ព្រោះកន្លងមកគាត់ និងប្អូនៗមានសណ្ដានចិត្តល្អណាស់ចំពោះរូបអញ យ៉ាងយូរបីថ្ងៃទៀតអញត្រឡប់មកដល់អ្នែងវិញហើយ ។

ស្អែកឡើង អាឃ្មី បានជូនខ្ញុំមកយកកង់នៅមុខពេទ្យលោកសង្ឃហើយមុនពេលដែលខ្ញុំបែកពីវា អាឃ្មី នៅបានប្រគល់សំបុត្រខទ្ទេសនាមរបស់វាមកឲ្យខ្ញុំសម្រាប់ប្រើប្រាស់ក្នុងការធ្វើដំណើរត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ ។

គម្រប់បីថ្ងៃក្រោយមក ខ្ញុំក៏បានមកដល់ អាឃ្មី វិញដូចពាក្យសន្យា រសៀលថ្ងៃខ្ញុំមកដល់នោះ អាឃ្មី បានវេចអន្ទករគន្ធះកូនថង់ហើយនាំខ្ញុំដើរកាត់តម្រង់ទៅផ្លូវមុនីវង្ស ដើរបណ្ដើរ អាឃ្មី បានប្រាប់ខ្ញុំបណ្ដើរថា «អញនាំអ្នែង ទៅស៊ីចេកចៀន» ។

មកដល់មុំមេភ្លើង នៅនឹងចិញ្ចើមថ្នល់ពីមុខអគារធំមួយដែលទើបតែលើកស្លាកថ្មីៗ សរសេរដោយអក្សរធំៗថា «ក្រសួងផែនការ» ខ្ញុំបានឃើញបងស្រីម្នាក់អាយុប្រហែលម្ភៃបីម្ភៃបួនឆ្នាំសម្បុរស ផ្ទៃមុខពងក្រពើ សក់ខ្មៅក្រិបប្រះស្មាកំពុងតែអង្គុយចៀនចេកនៅក្នុងខ្ទះមួយដែលមានខ្លាញ់ក្ដៅពុះយ៉ាងកញ្ជ្រោល ។

អាឃ្មី ប្រហែលជាជាប់ស្នេហ៍បងស្រីលក់ចេកចៀននេះហើយ មើលទៅ បានជាខំនាំខ្ញុំដើរពីណាពីណីមក ។ ជាមួយនឹងចំហាយខ្លាញ់ក្ដៅពីក្នុងខ្ទះគាត់បែកញើសសើមជោគចុងច្រមុះ ដែនថ្ពាល់ទាំងគូឡើងក្រហមទុំគាត់ ញញឹមមកកាន់ខ្ញុំ និងអាឃ្មី យ៉ាងសែនស្រស់ ។ គាត់បានហុចជើងម៉ាតូចៗពីរមកឲ្យខ្ញុំ និងអាឃ្មី អង្គុយលើជើងម៉ា ពែនភ្លែនទល់មុខអ្នកលក់ ហូបចេកចៀនបណ្ដើរខ្ញុំទាំងពីរនាក់បានសំណេះសំណាលជាមួយគាត់ពីនេះពីនោះបណ្ដើរ ។ ជជែកចុះជជែកឡើងវិលៗដល់រឿងជិនាន់អាពតជងដែល ដោយទឹកមុខស្រពាប់ស្រពោនក្រៀមក្រំ គាត់បានពោលមកកាន់ខ្ញុំនិងអាឃ្មីថាៈ «ប្អូនអើយជីវិតរបស់យើងម្នាក់ៗ គ្មានអ្វីធំជាងព្រេងវាសនាទេ បើវាសនាតម្រូវមកយ៉ាងម៉េចហើយ យើងត្រូវតែទទួល ពោលគឺយើងមិនអាចប្រឆាំងនឹងព្រេងវាសនាបានឡើយ» ។

គាត់នៅបានប្រាប់ខ្ញុំពីខ្សែជីវិតប្ដីប្រពន្ធដ៏កំសត់របស់គាត់ ។ ពីរឆ្នាំមុនដាច់ភ្នំពេញ គាត់បានរៀបការ ហើយបានកូនប្រុសមួយ គាត់ត្រូវបានជម្លៀសទៅនៅខេត្តបាត់ដំបង នៅភូមិសាលាឆេះ ជាងបីឆ្នាំក្នុងរបបប៉ុល ពត លំបាកវេទនាឈឺចាប់ខ្លោចផ្សាយ៉ាងណាគាត់ថាគាត់មិនបាច់រៀបរាប់ទេ ព្រោះខ្ញុំទាំងពីរនាក់ក៏បានឆ្លងកាត់មកហើយដែរ ។ នៅថ្ងៃ៧មករា ដែលជាថ្ងៃរំដោះ ប្ដីគាត់បានត្រឡប់មកពីការដ្ឋានភ្នំជញ្ជាំងជួបជុំគ្នានៅនឹងភូមិវិញ តែបាត់មិនឃើញកូនប្រុសគាត់ដែលនៅកងកុមារក្នុងភូមិស្វាយមិនត្រឡប់មកវិញសោះ ។

ជាមួយនឹងប្រជាជនអ្នក១៧មេសាម្នាក់ទៀត ដែលបាត់កូនមិនឃើញត្រឡប់មកពីកងកុមារដែរនោះ ប្ដីគាត់ក៏បាននាំគ្នាចេញដំណើរទៅភូមិស្វាយ ដើម្បីតាមរកកូន ។ គាត់ទន្ទឹងចាំមើលផ្លូវប្ដីគាត់ទាំងអន្ទះសារក្នុងចិត្ត មួយយប់ ពីរយប់បានកន្លងផុតទៅនៅតែមិនឃើញស្រមោលប្ដីគាត់ត្រឡប់មកវិញសោះ ។

ដំណឹងចុងក្រោយពីអ្នកស្រុកអ្នកភូមិដែលបានទទួលមុនពេលគាត់ប្រញាប់ចាកចេញពីភូមិសាលាឆេះ មកបាត់ដំបងនោះ គឺពេលដែលប្ដីគាត់ចេញទៅតាមរកកូន ចៃដន្យជួបនឹងទាហានខ្មែរក្រហមដែលបាក់ទ័ព ពួកវាបានបាញ់សម្លាប់ប្ដីគាត់ និងអ្នករួមដំណើរទាំងអស់នៅកណ្ដាលទួលព្រៃ ។

រួមដំណើរជាមួយឪពុកម្ដាយក្មេក គាត់បានមករស់នៅទីរួមខេត្តបាត់ដំបង ហើយស៊ើបដំណឹងរកកូនប្រុសគាត់រាល់ថ្ងៃ ។ ពីរខែក្រោយមក មានតាយាយពីរនាក់ប្ដីប្រពន្ធ បានយកកូនប្រុសគាត់ទៅចិញ្ចឹម បាននាំកូនយកមកប្រគល់ឲ្យគាត់នៅនឹងផ្សារបាត់ដំបង ។ ដោយត្រេកអរខ្លាំងពេក និងដើម្បីជាកិច្ចតបស្នងសងគុណដ៏ធំលើសលប់នេះ គាត់ជូនទៅតាយាយនូវអង្ករ អំបិល និងរបស់របរមានតម្លៃជាច្រើនទៀត តែត្រូវបានគាត់ទាំងពីរនាក់បដិសេធ ។ តាំងពីបានជួបកូនប្រុសតែមួយរបស់គាត់មក គាត់ហាក់ដូចជាមានជីវិតថ្មី ហើយក្នុងមួយជីវិតគាត់នេះ គាត់នៅតែនឹកសង្ឃឹមថាប្ដីរបស់គាត់នៅរស់រានមានជីវិតនៅឡើយ ថ្ងៃណាមួយគាត់ និងបានជួបប្ដីគាត់វិញមិនខាន ។

រសៀលថ្ងៃនោះ ខ្ញុំ និងអាឃ្មី ហូបចេកចៀនគាត់ម្នាក់មួយ

ចំអែត អស់ថ្លៃតែ "បីកំប៉ុងអង្ករ" ក្នុងថង់នៅសល់អង្ករប្រហែលពីរបីកំប៉ុងទៀត អាឃ្មី ក៏បានជូនគាត់ទាំងអស់ទៅ ។ នៅជាមួយ អាឃ្មី ខ្ញុំទទួលអារម្មណ៍អផ្សុក ជាពិសេសនៅពេលដែល អាឃ្មី ចេញទៅធ្វើការបាត់ទៅ ជាញឹកញាយ ខ្ញុំនឹករលឹកដល់ប្អូនៗ ពូៗដែលធ្លាប់ធាក់កង់ឌុបកន្ទុលទៅលក់ជាមួយគ្នា នឹកទន្លេ នឹកធម្មជាតិទឹកដី ភូមិព្រៃជ្រីងដែលខ្ញុំធ្លាប់បានផ្ញើវាសនាមួយរយៈកន្លងមកនេះ ខ្ញុំនឹកជាពិសេសជាងនេះទៅទៀតដល់គ្រួសារម្តាយធំ ឆាវ៉ាក់ និងកូនៗទាំងអស់របស់គាត់ទាំងស្រីប្រុស ដែលមានសណ្តានចិត្តដ៏ល្អបរិសុទ្ធស្រឡាញ់រាប់អានខ្ញុំដូចជាបងប្អូន ក្នុងគ្រួសារតែមួយ ។

ប៉ុន្មានថ្ងៃចុងក្រោយនេះ ឲ្យតែពេលដែល អាឃ្មី ចេញទៅធ្វើការបាត់ ខ្ញុំក៏ចេញពីផ្ទះដែរ ។ នៅក្នុងទីក្រុង អ្នកដែលបានស្ម័គ្រចិត្តចូលបម្រើការងារតាមក្រសួងមន្ទីរនានាមានកាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយត្រូវបានអនុញ្ញាតឲ្យរស់នៅក្បែរៗកន្លែងធ្វើការ ចំណែកប្រជាជនធម្មតា មិនត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុង ទីក្រុងឡើយ ។

តាមតំបន់ជាយក្រុងនានា ប្រជាជនបានមករស់នៅយ៉ាងច្រើនកុះករ ។ នៅផ្សារដើមគមានកើតកូនផ្សារតូចមួយលក់ដូរតែមួយព្រឹក ដល់ថ្ងៃត្រង់ស្ងាត់សូន្យទៅវិញ អ្នករស់នៅទីនោះឲ្យឈ្មោះថា "ផ្សារក្រមួន" នៅស្ទឹងមានជ័យក៏កើតផ្សារមួយដែរ តាមបណ្តោយផ្លូវជាតិ ។

ថ្ងៃមួយខ្ញុំបានដើរទៅមើលគុកទួលស្លែង ជាអតីតវិទ្យាល័យដែលខ្ញុំធ្លាប់បានរៀនមុនពេលដាច់ភ្នំពេញ ហើយដែលបានត្រូវប្រែក្លាយទៅជាគុក "ស-២១" ក្នុងរបបប៉ុល ពត ។ គ្រាន់តែបានមកដល់គុកទួលស្លែងភ្លាម ធ្វើឲ្យខ្ញុំនឹកឃើញដល់ជីវភាពជាកូនសិស្សនឹកឃើញលោកគ្រូ សាស្ត្រាចារ្យប្រុសស្រី មិត្តរួមវិទ្យាល័យដែលធ្លាប់តែជុំៗគ្នា ហាក់ដូចជានៅថ្មីៗ ។ ខ្ញុំបានចូលទៅមើលតាមបន្ទប់នានានៃអគារ "ដេ" ខ្ញុំឡើងទៅដល់ជាន់ខាងលើបង្អស់ ទៅមើលថ្នាក់រៀននៃឆ្នាំដំបូងរបស់ខ្ញុំ ដែលប្រែទៅជាបន្ទប់ធ្វើទារុណកម្មយ៉ាងសាហាវ ។

នៅតាមជណ្តើរឡើងទៅអគារ "សេ" ជាន់ទីមួយ នៅនឹងជញ្ជាំងខាងស្តាំដៃ អក្សរមួយជួរដែល អាភិរម្យ មិត្តរួមថ្នាក់របស់ខ្ញុំបានសរសេរឲ្យមិត្តស្រីម្នាក់ដែលវាលួចស្រឡាញ់ "ចិញ្ចៀនពេជ្រណារូន" នៅជិតឃើញច្បាស់ក្រឡែតនៅឡើយ ។ ថ្នាក់រៀនរបស់ខ្ញុំនៅក្នុងអគារ "សេ" នេះត្រូវបានប្រែក្លាយទៅជាបន្ទប់ដាក់អ្នកទោសដែលមានរបងបន្លាលួសការពារយ៉ាងរឹងមាំ ។

នៅបន្ទប់ជាន់ក្រោមនៃអគារមួយផ្សេងទៀត ខ្ញុំបានចូលទៅមើលរូបថតជនរងគ្រោះដែលបិទនៅតាមជញ្ជាំងរាប់ពាន់នាក់ដោយពិនិត្យពិច័យ ។ ក្នុងចំណោមរូបថតសខ្មៅទាំងនោះ ភ្នែកខ្ញុំបានពើបជំពប់នឹងរូបថតជនរងគ្រោះម្នាក់ដែលខ្ញុំធ្លាប់ស្គាល់ ហើយដែលមាននរណាម្នាក់បានមកឃើញមុនខ្ញុំ ដោយគេបានសរសេរនឹងខ្មៅដៃនៅពីក្រោយរូបនោះថាៈ "សមមិត្តលឹម ប្រធានឃុំកំពង់ថ្ម" ។

ពេទ្យចិនគឺជាមន្ទីរពេទ្យដំបូងបង្អស់ដែលបានដំណើរការព្យាបាលជំងឺជូនប្រជាជន ដោយមានវេជ្ជបណ្ឌិតខ្មែរបីបួននាក់សហការជាមួយក្រុមវេជ្ជបណ្ឌិតមកពីប្រទេសគុយបា ។ មហាវិទ្យាល័យវេជ្ជសាស្ត្រក៏ត្រូវបានបើកទ្វារឡើងវិញ ដែលដំបូងមានកូនសិស្សពេទ្យប្រហែល ៧០-៨០ នាក់មកពីបណ្តាខេត្តនានាទូទាំងប្រទេស ។ តាមក្រសួងផ្សេងខ្លះទៀត ក៏មានបើកវគ្គបំពាក់បំប៉នគោលនយោបាយ និងវគ្គមុខជំនាញដល់បុគ្គលិក ដោយមានពួកជំនាញការវៀតណាមមកពីហាណូយជាគ្រូបង្រៀន ។

ផ្ទះទំនេរៗក្នុងទីក្រុង ត្រូវបានបុគ្គលិកដែលជាអ្នកធ្វើការមកបោសសំអាត និងរស់នៅជាបណ្តើរៗ ដែលភាគច្រើនរស់នៅម្តុំក្បែរៗគ្នាជិតកន្លែងធ្វើការរៀងៗខ្លួន ។ បុគ្គលិកឃោសនាការវប្បធម៌វិចិត្រសិល្បៈរស់នៅតាមអគារខ្ពស់ៗជិតសាលហោស្រពទន្លេបាសាក់ បុគ្គលិកក្រសួងការបរទេសនៅម្តុំក្រោយរដ្ឋសភាជុំវិញផ្សារកាប់គោ និងជិតវិមានឯករាជ្យ បុគ្គលិកក្រសួងពាណិជ្ជកម្មរបស់នៅជុំវិញផ្សារថ្មី និងផ្សារអូរឫស្សី បុគ្គលិកក្រសួងអប់រំ នៅម្តុំបឹងកេងកងជាដើម ។

បុគ្គលិកស្ទើរតែគ្រប់ក្រសួងមន្ទីរទាំងអស់ ត្រូវបានហូបរបបបាយរួមដែលឧបត្ថម្ភរបបត្រីសាច់ដោយមន្ទីរស្បៀងមួយ ក្រោមឱវាទក្រសួងពាណិជ្ជកម្មឈ្មោះមន្ទីរសត្តឃាត២ធ្នូ ។ ម្តុំមាត់ទន្លេនៅនឹងរោងបាយខាងក្រោយអគាររដ្ឋសភាជាតិ ខ្ញុំធ្លាប់បានឃើញបុគ្គលិកក្រសួងការបរទេសបួនដប់នាក់អង្គុយហូបបាយរួមដែលកាលនោះស្ថាប័នសភាជាតិមិនទាន់បានរៀបចំស្រួលបួលនៅឡើយ ក្នុងអគាររដ្ឋសភាតាមបន្ទប់នានាក៏មានបុគ្គលិកក្រសួងការបរទេសរស់

នៅដែរ ។

ក្រោយមកផ្សារមួយ បានកើតឡើងតាមបណ្តោយផ្លូវខាងកើតផ្សារថ្មី ដើម្បីសម្រួលដល់បុគ្គលិក កម្មករ កម្មការិនីសហគ្រាសកាត់ដេរមួយនៃក្រសួងពាណិជ្ជកម្ម ហើយដោយប្រធានសហគ្រាសកាត់ដេរនោះ ឈ្មោះថា តាប៉ាង ផ្សារនោះក៏ជាប់ឈ្មោះផ្សារតាប៉ាងៗរហូតមក ។

នៅចំកាច់ជ្រុងផ្លូវ១៨មីនា និងប៉ាស្ទ័រ ខ្ញុំបានជួប លី និងអារី ដែលប្រកបមុខរបររកស៊ីប៉ះកង់នៅចិញ្ចើមផ្លូវ គេទាំងពីរនាក់បានកូនប្រុសមួយ ។ ខ្ញុំខស្សាហ៍ដើរមកលេងគេទាំងពីរនាក់ណាស់ ថ្ងៃមួយដោយឪពុកមារបស់ អារី ម្នាក់ត្រូវរៀបការ គាត់ក៏បានមកនិយាយជាមួយខ្ញុំ សូមឲ្យខ្ញុំ និងលី ជួយធ្វើជាអ្នកកំដរក្នុងពិធីមង្គលការគាត់ ខ្ញុំក៏យល់ព្រម ។ ដោយសាម៉ីខ្លួនខាងស្រីជាអ្នកធ្វើការនៅក្នុងក្រសួងធំមួយ មានភ្ញៀវកិត្តិយសជាច្រើនបានអញ្ជើញមកជាបន្តបន្ទាប់នោះ ស្រាប់តែខ្ញុំបានឃើញវត្តមានបង ជា ពន្ទក ដែលទើបតែចុះពីរថយន្តម៉ែរសីដេសពណ៌ស្លឹកឈើមួយ គ្រឿងក្នុងសម្លៀកបំពាក់អាវធំយ៉ាងសង្ហា បានឃើញគាត់ ខ្ញុំត្រេកអរខ្លាំងណាស់ នឹកឃើញភ្លាមដល់ទឹកត្នោតជ្រូមដែល បងឈាង ទួលសង្កែបានឲ្យគាត់យកទៅស្រូបបាយកកទាំងព្រលឹម តែប៉ុន្មាននាទីក្រោយមក ខ្ញុំត្រូវខកចិត្តយ៉ាងខ្លាំងដោយពេលនោះបង ពន្ទក បែរជាធ្វើព្រងើយមិនស្គាល់ខ្ញុំទៅវិញ ។

ក្រោយពីរៀបការឪពុកមាអារី រួចបានពីរខែ លី និងអារី ក៏បាននាំកូនទៅរស់នៅជំរុំជនភៀសខ្លួនឯ ព្រំប្រទល់ខ្មែរ-ថៃ រង់ចាំចេញទៅសហរដ្ឋអាមេរិកជុំគ្នាជាមួយឪពុកម្តាយលី ដែលបានមករង់ចាំនៅជំរុំតាំងពីយូរណាស់មកហើយ ។

ខ្ញុំបានជួបបង ម៉ៅ អាយុទ្ធ នៅនាយកដ្ឋានភាពយន្តនៃក្រសួងឃោសនាការ គាត់ និងប្រពន្ធ បានឃាត់ខ្ញុំឲ្យចូលធ្វើការជាមួយគាត់ ។ ខ្ញុំក៏បានជួបនឹងបង ម៉ម ប៊ុនណារ៉ាយ ដែលលេងភ្លេងនៅវង់តន្ត្រីវិទ្យុជាតិ អារីរដ្ឋា ក្មួយរបស់គាត់បានរៀបការជាមួយបង សុខា ហើយទាំងពីរនាក់នៅច្រៀងក្នុងវង់តន្ត្រីវិទ្យុជាតិដែរ ។ ខ្ញុំបានស្គាត់ទៅលេងបង អាំង ថេងអុង នៅអយស្ម័យយានកម្ពុជា និងបង គ្រីឆេង នៅប្រៃសណីយ៍ទូរគមនាគមន៍ ។

ក្រសួងពាណិជ្ជកម្មមានបើកវគ្គបណ្តុះបណ្តាលមុខជំនាញមួយវគ្គដំបូងសម្រាប់រយៈពេលបីខែនៅលីសេដេកាដ ។ នៅទីនោះខ្ញុំបានជួបបងស្រីអាស្រ៊ុន ភូមិប្រាសាទ ជួប អារ៉ា កំពង់ថ្ម និងបានជួបអ្នកចល័តស្រុកសន្ទុក អ្នកតាំងក្រសាំងជាច្រើននាក់ទៀត ដែលកំពុងបំពេញកម្មសិក្សាក្នុងវគ្គមុខជំនាញនោះ ។

បងស្រីអាស្រ៊ុន បានប្រាប់ដំណឹងដ៏រំភើបត្រេកអរមួយដល់ខ្ញុំ ដែលអាស្រ៊ុន វាបានទៅដល់ប្រទេសអូស្ត្រាលីហើយ ។ អារ៉ា ក៏បានប្រាប់ខ្ញុំដែរពីដំណឹងដែលមិត្តសំ ភូមិឈើទាលប្រធានកងរបស់វាកាល នៅចល័តឃុំកំពង់ថ្ម ត្រូវវៀតណាមចាប់ដាក់គុកបុរីកីឡា ។

អារ៉ា បានប្រាប់ខ្ញុំទៀតថា ថ្ងៃមួយដោយចៃដន្យស្រាប់តែវាបានជួបមិត្តសំ នៅក្រោយវត្តព្រះពុទ្ធមានបុណ្យ ឃើញមិត្តសំភ្លាម វាបានគិតថា វាមិនយកកម្មពៀរអីទេ ទោះជាវាមានប្រវត្តិធ្លាប់ត្រូវបានមិត្តសំ ជាប្រធានទាត់ធាក់ខ្ទះក៏ដោយ តែក្រោយពីពេលដែលវាបានសួរទៅមិត្តសំ ថា "មិត្តឯងទៅណាមកណា?" មិត្តសំបានឆ្លើយ ថា "ទៅយកជ័យភណ្ឌ" ។

គ្រាន់តែឮមិត្តសំ ថាទៅយកជ័យភណ្ឌភ្លាម ពួកម៉ាកឯងជួយគិតមើលអាណាមិនក្តៅ យកជ័យភណ្ឌអីពីរបីដងតែឯង កាលពីឆ្នាំ១៩៧៥ ពួកយើងត្រូវវាបណ្តេញចេញពីផ្ទះទីណាត់ទីណែង វាយកជ័យភ័ណ្ឌម្តងហើយ ដល់ឥឡូវវាយកជ័យភណ្ឌម្តងទៀត? ក្តៅពេកទ្រាំមិនបានហៅវៀតណាមចាប់មិត្តសំ ដាក់គុកបុរីកីឡាទៅ ។

អារ៉ា បាននាំខ្ញុំទៅលេងបងប្រុសវាម្នាក់ ដែលកំពុងតែធ្វើការនៅកន្លែងខ្លាញ់២ធ្នូ ។ នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានជួបអ្នកភូមិទួលសង្កែជាច្រើនគ្រួសារ ជាពិសេសក្រុមគ្រួសារកូនចៅ តាសួង ដែលធ្លាប់នៅបម្រើគាត់ កាលពីគាត់នៅរស់នៅឡើយ ។ នៅនឹង២ធ្នូនោះដែរ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលដែលខ្ញុំបានជួប តាពុំ ប្រធានរោងបាយយោធាស្រុកសន្ទុកទាំងគ្រួសារ ខ្ញុំបានឃើញមិត្តធិ (សមិទ្ធិ) នារីកងចល័តស្រុកសន្ទុកជាមួយខ្ញុំ ធ្វើការនៅទីនោះដែរ ។ មិត្តហេន ពេទ្យស្រុកសន្ទុក ខ្ញុំក៏ធ្លាប់បានជួបម្តងម្កាល តែមិត្តហេនអត់ធ្វើការនៅ២ធ្នូទេ គ្រាន់តែមកលេង ។

ក្រោយពីបានទទួលដំណឹងពីបងស្រីអាស្រ៊ុន មកថា អានឿន (ឃុំប្រាសាទ) ក៏បានចូលធ្វើការនៅក្រសួងពាណិជ្ជកម្មនាយកដ្ឋានគយ និងរដ្ឋាករដែរ ខ្ញុំក៏ប្រញាប់ប្រញាល់ស្គាត់ទៅរកវាភ្លាម ។ ក្រោមម្លប់ដើមអំពិលបារាំង នៅក្នុងធ្លាមន្ទីរគយ និងរដ្ឋាករ អានឿន

អង្គុយលើពូកម៉ូតូហុងដារបស់វាដដែកលេងជាមួយខ្ញុំ យើងនាំគ្នាសើចនៅពេល ដែលខ្ញុំរំលឹកដល់អនុស្សាវរីយ៍នៅទំនប់ទឹក១មករាដែលនារីយោធាម្នាក់ស្រឡាញ់វា ហើយបានសរសេរសំបុត្រស្នេហាមួយច្បាប់ឲ្យវា កាលនោះ អានឿន បានយកមកឲ្យខ្ញុំ អាពន្លក និងអាស្រ៊ុន អាននៅរោងចល័តស្រុក ។ សំបុត្រស្នេហារបស់នារីយោធានោះ ពិបាកអានបន្តិចដោយការយល់ដឹងមានកម្រិតទាបពេក តែនាងបានខិតខំសរសេរពីចិត្តស្មោះយ៉ាងអស់ពីក្រអៅបេះដូង ។

ពេលកំពុងតែជជែកគ្នាលេងជាមួយ អានឿន ខ្ញុំបានឃើញរថយន្តមីនីការពណ៌សមួយគ្រឿងកំពុងតែបើកចូលមក ។ ពេលដែលម្ចាស់រថយន្តបើកទ្វារចេញ ខ្ញុំបានជួបនឹងរឿងភ្ញាក់ផ្អើលថ្មីមួយទៀត ក្នុងឯកសណ្ឋានជាមន្ត្រីគយ ខោអាវពណ៌ខៀវចាស់ ស្បែកជើងពណ៌ខ្មៅរលោង មានក្រវ៉ាត់កាំភ្លើងខ្លីនៅចង្កេះផង មិត្តជនអនុប្រធានវរៈទីមួយកងចល័តឃុំកំពង់ថ្ម កំពុងតែបោះជំហានឡើងកាំជណ្តើរឆ្ពោះទៅកាន់ការិយាល័យរបស់គាត់យ៉ាងសង្ហា ។

ថ្ងៃក្រោយបន្ទាប់មកទៀត ពេលដែលខ្ញុំទៅលេង អានឿន ខ្ញុំក៏បានឃើញមិត្តសេក ពេទ្យស្រុកសន្ទុកធ្វើការនៅមន្ទីរគយ និងរដ្ឋាករនេះដែរ ។ ខ្ញុំរកគិតពុំយល់ដោយបានជួបតែអ្នកស្រុកសន្ទុកតាំងក្រសាំង កំពង់ថ្មច្រើនពេក ក្រោយមកតាមប្រភពជិតដិតពីក្រុមគ្រួសារ តាសួង ធ្វើការនៅ២ឆ្នាំបានឲ្យដឹងថាៈ «ដោយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មធ្លាប់មានអតីតភាពជានីរសាផ្ទាល់របស់ តាសួង ហើយក្នុងសម័យតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវាលន់នល់ គាត់ធ្លាប់ធ្វើជាគណៈស្រុកសន្ទុកទៀតផង» ។

ប្រមាណមួយខែក្រោយមក ខ្ញុំក៏បានចូលបម្រើការងារជាបុគ្គលិកនៅក្នុងក្រសួងនយោបាយមួយ ដែលកាលនោះនៅក្នុងនាយកដ្ឋានរបស់ខ្ញុំមិនទាន់មានតុកៅអ៊ីនៅឡើយ ។ យើងបានរៀបចំបោសសំអាតអាចម៍នោមក្នុងភូមិគ្រឹះមួយខ្នងធំ ដែលមានរបងជាប់ខាងជើងវត្តស្វាយពពែ ។

អស់ពេលជាច្រើនថ្ងៃ ដែលខ្ញុំរួមនឹងបុគ្គលិកជាងដប់នាក់ទៀត បាននាំគ្នាកើបសំរាមដែលពួកខ្មែរក្រហមបានយកមកចាក់មួយគំនរធំចំកណ្តាលបន្ទប់ទទួលភ្ញៀវជាន់ក្រោម តាមបន្ទប់នានានៅជាន់ខាងលើក៏សុទ្ធតែសំរាមដែរ ហើយថែមទាំងមានក្លិនស្អុយឆ្អេះឆ្អាបយ៉ាងខ្លាំងទ្រាំសឹងតែពុំបានផង សូម្បីតែបន្ទប់តូចមួយនៅក្រោមជណ្តើរវិលតូចខ្សែងខាងចំហៀងផ្ទះ ក៏ត្រូវបានពួកខ្មែរក្រហមយកសំរាមទៅចាក់យ៉ាងណែនឡើងពេញហៀរមកក្រៅ ។

រសៀលថ្ងៃមួយ ពេលដែលខ្ញុំកំពុងតែកើបសំរាមចេញពីបន្ទប់នៅជាន់ខាងក្រោមជណ្តើរវិលនោះ ស្រាប់តែខ្ញុំបានប្រទះភ្នែកឃើញលោហៈធាតុមួយបន្ទះតូចប៉ុនមេដៃប្រវែងប្រហែល៦-៧សង់ទីម៉ែត្រ ពណ៌មាសចាំងផ្លេកៗ ខ្ញុំក៏ប្រញាប់ឱនរើសយកមកមើលភ្លាម ខ្ញុំឃើញអក្សរឡាតាំងមួយជួរសរសេរថា “John Gunter Dean” ។ ក្រោយមកទើបខ្ញុំបានដឹងថា ភូមិគ្រឹះគឺជាលំនៅដ្ឋានរបស់លោកឯកអគ្គរដ្ឋទូតអាមេរិកាំងចុងក្រោយដែលរត់ឡើងយន្តហោះចាកចោលទីក្រុងភ្នំពេញកាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ។

តាំងពីពេលដែលខ្ញុំរើសបានស្លាកឈ្មោះលោកឯកអគ្គរដ្ឋទូតអាមេរិកាំងនោះមក ខ្ញុំបានថែរក្សាទុកដូចជាវត្ថុ មានតម្លៃបំផុតសម្រាប់ខ្ញុំ ។ លើសពីនេះទៅទៀត ខ្ញុំធ្លាប់បានស្រមៃនឹកឃើញថា ថ្ងៃណាមួយបើសិនជាខ្ញុំបានជួបអ្នកកាសែតអាមេរិកាំង ខ្ញុំនឹងផ្ញើស្លាកឈ្មោះលោកឯកអគ្គរដ្ឋទូត ដែលខ្ញុំរើសបានដូតដុសខាតឡើងឲ្យភ្លឺរលោងទៅជូនលោកវិញ ។ ខ្ញុំគ្មានចង់បានអ្វីពីលោកទេ តែខ្ញុំចង់សូមអរគុណលោក ព្រោះបើកុំតែមានរូបលោកម្ល៉េះស្រុកខ្ញុំ មិនបានជាប់លេខមួយដោយសារ «ក្បាលខ្មោច»ដូចសព្វថ្ងៃនេះទេ ។

បានចូលធ្វើការហើយមែន តែខ្ញុំរស់នៅជាមួយ អាឃ្មី នៅឡើយ ជីវភាពជាអ្នកកាសែតដូច អាឃ្មី ខ្ញុំមើលទៅដូចជាល្ហេមល្ហាមណាស់ ។ ពេលខ្លះយើងបានទទួលរបបស្ករស សាប៊ូបោកខោអាវដែលផលិតនៅប្រទេសវៀតណាមពីកន្លែងធ្វើការ ហើយមានពេលមួយនោះយើងបានទទួលមីម្ហូបកំប៉ុង និងបារីដែលជាជំនួយពីប្រទេស ហុងគ្រីជាមិត្ត អាឃ្មី យកទៅលក់អស់គ្មានសល់ ។

ធ្វើជាអ្នកកាសែតបដិវត្តន៍ អាឃ្មី រកតែស្លឹបស្លៀកសឹងតែពុំបាន ។ ព្រឹកៗឡើងពេលស្លៀកពាក់ចេញទៅធ្វើការ ជាញឹកញយ អាឃ្មី នៅបានស្រែកសួរខ្ញុំថាៈ «អាមួយនេះស្លឹបអញឬស្លឹបអ្ហែង?» ។ ថ្វីត្បិតការងាររបស់វា «ស៊ីតែក្រដាស» មែន តែ អាឃ្មី ពេញចិត្តរីករាយ និងមានឧត្តមគតិយ៉ាងខ្ពង់ខ្ពស់ក្នុងការបម្រើវិជ្ជាជីវៈកាសែតរបស់វានេះ ។

ដោយសារស្ថានភាពនៃការរស់នៅកាន់តែយ៉ាប់យឺនទៅៗ អាឃ្មី ក៏បានសម្រេចចិត្ត «យកប្រពន្ធ» មុនខ្ញុំ ។ អាឃ្មី វាមានសំណាង

ណាស់ដោយបានការជួយជ្រោមជ្រែងពីប្រធានការសែតវាផង (ប្រធានកាសែត អាឃ្មី ក៏នៅកម្លោះដែរ) ថ្ងៃចូលទៅស្តីដណ្តឹង ឪពុកខាងស្រីមិនដឹងជាគាត់មានកម្មពៀរអ្វីជាមួយអ្នកកាសែត គ្រាន់តែបានដឹងថា កូនកម្លោះមានមុខរបរជាអ្នកកាសែត ស្រាប់តែគាត់ឆ្លើយដាំងក្លាមថា «និយាយតាមត្រង់បើដុកទ័របុរីស្ករ ចូលមកស្តីដណ្តឹងកូនខ្ញុំ ខ្ញុំមិនឲ្យទេ តែបើធ្វើការជាអ្នកកាសែត ខ្ញុំលើកកូនឲ្យភ្លាមដោយមិនចាំបាច់ស៊ើបប្រវត្តិរូបទេ» ។

អាពាហ៍ពិពាហ៍របស់ អាឃ្មី បានប្រព្រឹត្តទៅក្នុងសភាពយ៉ាងអធឹកអាធ៍ម ព្រោះឪពុកក្មេកវាធ្វើការនៅក្រសួងសិក្សាធិការអប់រំ គាត់បានអញ្ជើញភ្ញៀវមកពីក្រសួងចូលរួមជាច្រើន ។

ប្រពន្ធ អាឃ្មី ឈ្មោះពិសី អាយុ១៨ឆ្នាំ មានបងប្អូនតែពីរនាក់ គត់ ប្អូនប្រុសរបស់នាងឈ្មោះ ឧត្តម នៅផ្ទះ ហៅ «អាគ្គុំៗ» នៅរៀននៅឡើយ ។ ឪពុកម្តាយក្មេក អាឃ្មី ដល់ចំណាស់ប្រហែលជាង ៤០ឆ្នាំស្របាលគ្នា ជាមនុស្សរបៀបរបបខ្ពង់ខ្ពស់ដែល អាឃ្មី បាននឹងកំពុងតែសម្របខ្លួនរៀបបុកពាររាល់ថ្ងៃ តែគាត់ទាំងពីរនាក់មានសណ្តានចិត្តយ៉ាងល្អអាណិតអាសូរស្រឡាញ់ អាឃ្មី ដែលជាមនុស្សកំព្រីកំព្រា គាត់មិនចង់បានអីពី អាឃ្មី ឡើយ ។

ថ្ងៃរៀបការ អាឃ្មី មានតែអវយវៈ សូម្បីតែអុសមួយចម្រៀក ឬអំបិលមួយគ្រាប់ក៏គ្មានដែរ អាឃ្មី (មានតែបីតម្លឹងដាក់នៅជាប់នឹងខ្លួន) គឺស៊ីចុកខាងស្រីគេទទួលទាំងអស់ ។ ក្នុងចិត្តខ្ញុំនឹកស្ងើចសរសើរសំណាងរបស់វា ហើយមានថ្ងៃមួយនោះ អាឃ្មី នៅបាននិយាយជាមួយខ្ញុំដោយមោទកភាពថាៈ «ពេលអ្ហែងយកប្រពន្ធ បើមិនបានលើសអញទេ ត្រឹមប្រហាក់ប្រហែលអញក៏បានដែរ» ។

ខ្ញុំបានអរគុណវាដែលវាបាននឹកគិតដល់ខ្ញុំ ដោយចង់ឲ្យខ្ញុំបានជួបនឹងសំណាងល្អដូចវា អាឃ្មី បានឲ្យយោបល់ខ្ញុំទៀតថា មុននឹងរៀបការ យើងត្រូវសម្លឹងមើលសេដ្ឋកិច្ចខាងស្រីជាមុនសិន ព្រោះក្បាលមួយដូចអ្ហែងដូចអញ គ្មានអីរំពឹងទេ ។ ខ្ញុំទទួលស្គាល់ថា អាឃ្មី ពិតជាមានសំណាងមែន ពេលរៀបការស៊ីខាងស្រី រៀបការរួចរហូតដល់ពិសីប្រពន្ធវាមានផ្ទៃពោះជិតគ្រប់ខែទៅហើយ អាឃ្មី នៅតែស៊ីខាងស្រីដដែល ។

ក្រោយមកម្តាយក្មេកវាបានទិញម៉ូតូហុងដាមួយគ្រឿងឲ្យ អាឃ្មី គ្រាន់ជិះទៅធ្វើការ ហើយដោយរូបខ្ញុំខស្សរាហ៍ចុះឡើងទៅលេង ខ្ញុំក៏បានទទួលនូវការស្រឡាញ់រាប់អានពីក្រុមគ្រួសារ អាឃ្មី យ៉ាងកក់ក្តៅ ។

ថ្ងៃដែល ពិសី ឆ្លងទន្លេបានកូនប្រុសមួយ អាឃ្មី សប្បាយត្រេកអរយ៉ាងខ្លាំង វាបានស្រែកប្រាប់ខ្ញុំថា «តែ ប៉ុណ្ណេះអញបានក្លាយទៅជាឪពុកគេហើយ» ។ កូនប្រុស អាឃ្មី គឺជាពេជ្រមួយគ្រាប់ដែលនាំមកនូវសុភមង្គលយ៉ាងត្រចេះត្រចង់សម្រាប់គ្រួសារវាទាំងមូល ។

តាំងពីរៀបការរួចមក អាឃ្មី វាមានចំណុចល្អជាច្រើនដែលគួរឲ្យគោរព ចំពោះឪពុកម្តាយក្មេកវា អាឃ្មី បានស្រឡាញ់គោរពគាត់ទាំងពីរមិនឲ្យមានទាស់ វាខ្លាចកុំឲ្យដូចពាក្យចាស់ពោលថា ឈើកោងវល្លិ៍ពាត់ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត ។ ក្រៅពីពេលធ្វើការ នៅផ្ទះ អាឃ្មី បានជួយកិច្ចការប្រពន្ធវាសព្វបែបយ៉ាងទាំងអស់ ។ ពិសី បានលួចសរសើរសំណាងខ្លួនឯងមិនដាច់ពីមាត់ ដែលបានមកជួប «បុរសជាប្តី» ដូចអាឃ្មី មានចិត្តស្រឡាញ់ប្រពន្ធកូន ស្រឡាញ់គ្រួសារពិតៗ ។ ពិសី តែងតែនិយាយទាំងអំណួតថាៈ «ល្អដូចប្តីខ្ញុំកុំថាឡើយវេចអន្ទក់មួយតៅដើររក សូម្បីតែវេចមួយគោនក៏រកមិនបានផង» ។

ខ្ញុំសូមបើកវង់ក្រចកសរសើរ អាឃ្មី បន្តិចសិន តាមតែខ្ញុំធ្លាប់ដឹងការពិតគឺដូច្នោះមែន នៅផ្ទះដូតទឹកឲ្យកូនគឺ អាឃ្មី ផ្លាស់កន្ទបអាចម៍កូនក៏អាឃ្មី លួងកូនពេលយំ ឈឺស្កាត់ឃ្លានក្រោកឆុងទឹកដោះគោយប់ព្រលប់ឲ្យកូនបៅ ក៏អាឃ្មី ។ នៅមានកិច្ចការច្រើនផ្សេងទៀតដែល អាឃ្មី ពេញចិត្តនឹងជួយពិសីប្រពន្ធវាដោយមិននឹកនាដល់ការហត់នឿយឡើយ ខ្ញុំសូមបិទវង់ក្រចកមកវិញ ។

ថ្ងៃខួបកំណើត១ឆ្នាំរបស់កូនប្រុសវា គឺជាថ្ងៃដែលអាឃ្មី និងប្រពន្ធវាបានទទួលកិត្តិយសយ៉ាងឧត្តុង្គឧត្តម ដោយក្នុងគ្រួសារវាបានរៀបចំធ្វើពិធីបុណ្យកំណើតយ៉ាងធំមួយ ដែលឪពុកម្តាយក្មេកវាបានចាត់ចែង និងមានអញ្ជើញភ្ញៀវជាច្រើនមកចូលរួមផង ព្រោះជាថ្ងៃដំបូងរបស់គាត់ ។

**(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាង**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.


A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 198, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.